# ដែនកំណត់នៃកំណើន

## វិធីសាស្ត្រគ្រប់គ្រងភាពងាយរងគ្រោះ ក្នុងការស្វែងយល់អំពីនគរូបនីយកម្ម នៅកម្ពុជា


**កែសម្រួលដោយ**

Adam Saltsman

**ដោយមានការចូលរួមចំណែកពី**

Dolorès Bertrais
ប៉ក់ គឹមជឿន
Gabriel Fauveaud
Adam Saltsman
ង៉ោ ណត្ថារុន
ធួន ទ្រី




# គុណកថា


របាយការណ៍នេះត្រូវបានបោះពុម្ពផ្សាយក្នុងខែឧសភា ឆ្នាំ២០២១។ អ្នកនិពន្ធនៃអត្ថបទស្រាវជ្រាវនេះ សូមថ្លែងអំណរគុណដល់មជ្ឈមណ្ឌលខេមរសិក្សា(CKS)និងម្ចាស់ជំនួយសម្រាប់ការគាំទ្រសិក្ខាសាលាលើកដំបូង ដែលនាំឱ្យមានការផលិតឯកសារនេះ។ ព្រឹត្តិការណ៍នេះ ត្រូវបានធ្វើឡើងក្រោមកិច្ចសហការជាមួយដេប៉ាតឺម៉ង់នគរូបនីយកម្មនិងស្ថាបត្យកម្មនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ និងដោយបានចូលរួមពីតំណាងជាន់ខ្ពស់ អ្នកស្រាវជ្រាវ និងនិស្សិតមកពីសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច សាកលវិទ្យាល័យភូមិន្ទភ្នំពេញ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា សាកលវិទ្យាល័យន័រតុន សាកលវិទ្យាល័យអូតាវ៉ា( University of Ottawa ) សាកលវិទ្យាល័យឈៀងម៉ៃ ( Chiang Mai University )ព្រមទាំងតំណាងមកពីសាលារាជធានីភ្នំពេញ តំណាងជាន់ខ្ពស់មកពីអង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល រួមមាន អង្គការអុកស្វាម( Oxfam ) វិទ្យាស្ថានរីកចម្រើនបៃតងសកល ( GGGI ) សមាគមអន្តរជាតិនៃបណ្តាអភិបាលក្រុងនិយាយភាសាបារាំង( AIMF ) សហភាពអឺរ៉ុប( EU ) អង្គការពិភពកុមារនិងអភិវឌ្ឍន៍( PED ) ក្រុមការងារពង្រឹងនិងអភិវឌ្ឍន៍សហគមន៍( CEDT ) និងអង្គការសហប្រជាជាតិផ្នែកទីជម្រក( UN-Habitat )។

អ្នកនិពន្ធក៏សូមថ្លែងអំណរគុណដល់កម្មវិធីស្បៀងអាហារពិភពលោក( WFP ) ដែលបានផ្តល់ការអនុញ្ញាតឱ្យបោះពុម្ពផ្សាយផ្នែកមួយនៃរបាយការណ៍របស់កម្មវិធីស្បៀងអាហារពិភពលោកឡើងវិញ ដែលបានបញ្ចូលជាឯកសារដកស្រង់នៅក្នុងឯកសារបច្ចុប្បន្ន។

អ្នកនិពន្ធសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរដ្ឋាភិបាលអូស្ត្រាលី នាយកដ្ឋានកិច្ចការបរទេសនិងពាណិជ្ជកម្ម តាមរយៈកម្មវិធីពន្លកចំណេះរបស់មូលនិធិអាស៊ី សម្រាប់ការជួយគាំទ្រ ទាំងការធ្វើសិក្ខាសាលាសាធារណៈអនឡាញ( Webinar )មួយ ដែលអនុញ្ញាតឱ្យមានការពិភាក្សាយ៉ាងផុលផុស ជាមួយអ្នកចូលរួមនិងការបកប្រែឯកសារនេះជាភាសាខ្មែរ។

នៅទីបញ្ចប់នេះ អ្នកនិពន្ធក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់លោកស្រីបណ្ឌិត Eve Zucker ផងដែរ សម្រាប់ពេលវេលារបស់លោកស្រីដែលបានពិនិត្យនូវអត្ថបទស្រាវជ្រាវពេញលេញនិងសម្រាប់យោបល់ល្អៗរបស់លោកស្រី។



**បដិសេធន៍ :** ទស្សនៈដែលបានបង្ហាញនៅក្នុងការសិក្សានេះ គឺជាទស្សនៈផ្ទាល់របស់អ្នកនិពន្ធប៉ុណ្ណោះ និងមិនបានឆ្លុះបញ្ចាំងពីទស្សនៈរបស់រដ្ឋាភិបាលអូស្ត្រាលី មូលនិធិអាស៊ី មជ្ឈមណ្ឌលខេមរសិក្សាឬអ្នកចូលរួមដទៃទៀតឡើយ។

រូបគម្របដោយ Seb Alessandroni ។ រក្សាសិទ្ធិ។ មើលរូបភាពច្រើនផ្សេងទៀតពីអ្នកថតរូបនេះនៅលើ Instagram @seburbes។


Australian Aid · PONLOK CHOMNES · The Asia Foundation

# មាតិកា

សេចក្តីណែនាំអំពីដែនកំណត់នៃកំណើន : វិធីសាស្ត្រគ្រប់គ្រងភាពងាយរងគ្រោះក្នុងការស្វែងយល់អំពីនគរូបនីយកម្មនៅកម្ពុជា ........ 1
Adam Saltsman

កំណើនសេដ្ឋកិច្ចនិងការវិវត្តដែលផ្តោតលើភាពងាយរងគ្រោះនៅកម្ពុជា ........ 13
ង៉ោ ណត្តារុន

ផ្នែកត្រូវពិភាក្សា : ការធ្វើចំណាកស្រុកជនបទ-ទីក្រុងទៅរាជធានីភ្នំពេញ........ 21
ប៉ក់ គឹមជឿន

របៀបការកំណត់តំបន់និងផែនការប្រើប្រាស់ដីទីក្រុង ធ្វើឱ្យប៉ះពាល់ដល់ជីវភាពនិងការតាំងលំនៅក្រៅផ្លូវការ .. 24
ធួន ទ្រី

ផ្នែកត្រូវពិភាក្សា : ងាយរងគ្រោះផ្នែកសង្គមនិងបរិស្ថានដែលមានទំនាក់ទំនងទៅនឹងការអភិវឌ្ឍទីក្រុងដោយគ្មានការគ្រប់គ្រងនៅបឹងជើងឯក ........ 30
Dolorès Bertais

រាជធានីភ្នំពេញនិងការអភិវឌ្ឍអចលនទ្រព្យ : បច្ច័យថ្មីៗដើម្បីពិចារណាពីភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ច ..... 33
Gabriel Fauveaud

ឯកសារយោង ........ 38

# សេចក្តីណែនាំអំពីដែនកំណត់នៃកំណើន : វិធីសាស្រ្តគ្រប់គ្រងភាពងាយរងគ្រោះក្នុងការស្វែងយល់អំពីនគរូបនីយកម្មនៅកម្ពុជា

**បណ្ឌិត Adam Saltsman**
ដេប៉ាតឺម៉ង់សិក្សាទីក្រុង សាកលវិទ្យាល័យ Worcester State

ការស្រាវជ្រាវអំពីនគរូបនីយកម្មនិងការអភិវឌ្ឍទីក្រុង (ឬទីប្រជុំជន) នៅកម្ពុជា កំពុងតែមានការកើនឡើងនៅក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ។ នៅប្រទេសកម្ពុជាដែលប្រជាជនជិត ៧៦% នៅតែត្រូវបានគេចាត់ទុកជាប្រជាជនដែលរស់នៅតំបន់ជនបទ ការងារអភិវឌ្ឍន៍ជាច្រើនបានផ្តោតលើការកាត់បន្ថយទម្រង់អាក្រក់បំផុតនៃភាពក្រីក្រនៅជនបទ។[1] ទោះជាយ៉ាងណា ដោយសារស្ថានភាពអត្រានគរូបនីយកម្មក្នុងប្រទេសមានល្បឿនលឿននិងទំនាក់ទំនងដែលមិនអាចប្រកែកបាន រវាងបរិស្ថានជនបទនិងទីក្រុង ដែលជាលទ្ធផលនៃការធ្វើចំណាកស្រុកក្នុងស្រុក។ ការណ៍នេះជំរុញឱ្យមានកំណើនតម្រូវការ ដើម្បីមើលទីក្រុងរបស់ប្រទេសកម្ពុជាជាទីលម្ហនិងជាប្រព័ន្ធដែលភាគច្រើននៃការផ្លាស់ប្តូរសេដ្ឋកិច្ចនិងសង្គមយ៉ាងឆាប់រហ័ស កំពុងកើតមានឡើងនៅក្នុងប្រទេស។ លម្ហទីក្រុងនៃប្រទេសកម្ពុជា ជាកន្លែងដែលស្ថានភាពនៃភាពក្រីក្រត្រួតស៊ីគ្នាជាមួយនឹងកាលានុវត្តភាពនិងឧបសគ្គនៃការធ្វើនគរូបនីយកម្មយ៉ាងឆាប់រហ័ស ព្រមជាមួយនឹងដំណើរការនិងការផ្លាស់ប្តូរបរិស្ថានតំបន់និងសកលលោក សង្គមនិងសេដ្ឋកិច្ច។ ទីក្រុង គឺជាទីលម្ហស្មុគស្មាញ ដែលកម្លាំងទន្ទិចគ្នាច្រើនអនេកនិងកម្រិតផ្សេងៗនៃសង្គម នយោបាយ បរិស្ថាន និងសេដ្ឋកិច្ច។

ការស្រាវជ្រាវថ្មីមួយបានមើលទៅលើភាពក្រីក្រនិងការអភិវឌ្ឍនៅទីក្រុងក្នុងប្រទេសកម្ពុជា ដោយផ្តោតលើការខ្វះខាតឬកង្វះធនធាន ដើម្បីឆ្លើយតបនឹងតម្រូវការមូលដ្ឋាន។ បន្ថែមលើឧបករណ៍របស់អង្គការសហប្រជាជាតិ និងធនាគារពិភពលោក( ឧទាហរណ៍ អង្គការសហប្រជាជាតិឆ្នាំ២០១៤; ធនាគារពិភពលោកឆ្នាំ២០១៧) ឧបករណ៍មូលដ្ឋានគន្លឹះៗសម្រាប់វាស់ភាពក្រីក្រនៅកម្ពុជា រួមមាន វិធីសាស្រ្តវាយតម្លៃភាពក្រីក្រថ្នាក់ជាតិនិងនិយមន័យរបស់សាលារាជធានី ចំពោះទីប្រជុំក្រីក្រក្នុងទីក្រុងនៃជនចំណាកស្រុកនិងកម្មករក្រៅផ្លូវការ។ ការ

[1] នាយកដ្ឋានកិច្ចការសេដ្ឋកិច្ចរបស់អង្គការសហប្រជាជាតិនិងសង្គម " ទស្សនវិស័យនគរូបនីយកម្មពិភពលោក : ការពិនិត្យឡើងវិញឆ្នាំ២០១៨" ។ ចូលប្រើគេហទំព័រនៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ តាមរយៈតំណភ្ជាប់ https://population.un.org/wup/Country-Profiles/

សិក្សាថ្មីមួយរបស់កម្មវិធីស្បៀងអាហារពិភពលោក(២០១៩) បានប្រៀបធៀបការទទួលបានធនធាននិងកាលានុវត្តភាពក្នុងចំណោមគ្រួសារនៅកណ្តាលរាជធានីភ្នំពេញ ដែលផ្ទុយពីអ្នកដែលនៅតំបន់ឆ្ងាយៗ ទាក់ទងនឹងទ្រព្យសម្បត្តិ លទ្ធភាពទទួលបានទឹកស្អាតនិងអនាម័យ ស្ថានភាពសេដ្ឋកិច្ចនិងបំណុល សន្តិសុខស្បៀង ការទទួលបានការថែទាំសុខភាព សុខភាពនិងសុខមាលភាពរបស់កុមារ និងស្ថានភាពជនចំណាកស្រុក(ការធ្វើចំណាកស្រុក ចូល/ចេញ)។

ទោះជាយ៉ាងណា កង្វះខាតការវិភាគអំពីស្ថានភាពទីក្រុងនៅប្រទេសកម្ពុជា ដែលអាចបំភ្លឺនូវប្រភេទហានិភ័យនានា ដែលអ្នករស់នៅទីក្រុងនឹងជួបប្រទះចំពោះមុខនូវបញ្ហាប្រឈមថ្មីៗឬការភ័យខ្លាចចំពោះប្រព័ន្ធសង្គមសេដ្ឋកិច្ច បរិស្ថានឬនយោបាយ ជាពិសេស ក្នុងបរិការណ៍នៃនគរូបនីយកម្មយ៉ាងឆាប់រហ័ស។ ជាមួយគ្នាផងដែរ ក៏មានកង្វះខាតការវិភាគថាតើទីក្រុងនេះ មានលក្ខណៈល្អប៉ុណ្ណាឬថាតើអ្នករស់នៅក្នុងទីក្រុងត្រូវប្រឈមនឹងបញ្ហាទាំងនេះ។ របាយការណ៍នេះផ្តល់នូវក្របខណ្ឌទស្សនាទានសម្រាប់ការក្រឡេកមើលនគរូបនីយកម្មនៅក្នុងប្រទេសកម្ពុជា តាមរយៈទស្សនវិស័យនៃភាពងាយរងគ្រោះនិងភាពធន់នៃទីក្រុង ដែលឆ្លើយតបទៅនឹងគម្លាតនៃវិចារណនិពន្ធ(សូមមើលផងដែរ Blancot et al., ២០២០; Pierdet, ២០១២)។

ទស្សនាទាននៃភាពងាយរងគ្រោះនិងភាពធន់ គឺមានប្រយោជន៍ជាពិសេស ពីព្រោះទស្សនាទានទាំងនេះបានពិចារណាលើភាពស្មុគស្មាញនៃប្រព័ន្ធទីក្រុងនិងបានសង្កត់ធ្ងន់លើសារៈសំខាន់នៃវិធានការជាក់ស្តែងដែលអាចជួយព្យាករណ៍ពីភាពងាយទទួលរងគ្រោះចំពោះហានិភ័យនិងសមត្ថភាពក្នុងការទប់ទល់នឹងឧបសគ្គនិងការប៉ះទង្គិចនានាតាមដែលអាចធ្វើទៅបាន។

នៅក្នុងបរិការណ៍នៃការធ្វើនគរូបនីយកម្មយ៉ាងឆាប់រហ័សរបស់ប្រទេសកម្ពុជា អត្ថបទស្រាវជ្រាវនេះផ្តល់ជូននូវវិស័យគោលសំខាន់ៗចំនួនបី ដែលរួមគ្នាផ្តល់នូវក្របខណ្ឌនៃការវិភាគនិងផ្តល់កាលានុវត្តភាពសម្រាប់ការស្រាវជ្រាវនាពេលអនាគត។ វិស័យគោលទាំងបីនេះរួមមាន៖

១- របៀបជាប្រវត្តិសាស្ត្រដែលវិស័យអភិវឌ្ឍន៍នៅកម្ពុជាបានខិតខំព្យាយាមរកដំណោះស្រាយចំពោះសំណួរអំពីភាពក្រីក្រ ភាពងាយរងគ្រោះ និងភាពធន់

២- របៀបដែលការរៀបចំផែនការ ការកំណត់តំបន់ និងគោលនយោបាយ ទាក់ទងនឹងសំណួរនៃហានិភ័យនិងភាពធន់

៣- របៀបដែលការអភិវឌ្ឍទីក្រុង អចលនទ្រព្យហិរញ្ញវត្ថុលំនៅឋាននិងបំណុល ទាក់ទងទៅនឹងសន្តិសុខបុគ្គលនិងសន្តិសុខសេដ្ឋកិច្ចសមូហភាព។

លើសពីនេះទៀត យើងផ្តល់ជូន*ការផ្តោតអារម្មណ៍លើផ្នែកជំនាញ* ចំនួនពីរដែលផ្តល់នូវព័ត៌មានលម្អិតបន្ថែមទៀតលើវិស័យសំខាន់ចំនួនពីរ គឺការធ្វើចំណាកស្រុកពីជនបទ ទៅទីក្រុងនិងទំនាក់ទំនងរវាងការផ្លាស់ប្តូរចំពោះបរិស្ថានធម្មជាតិនិងការផ្លាស់លំនៅក្នុងបរិការណ៍នៃនគរូបនីយកម្ម។

ក្នុងការគ្របដណ្តប់លើផ្នែកទាំងបួននេះ អត្ថបទស្រាវជ្រាវនេះប្រកាន់ខ្ជាប់នូវទិដ្ឋភាពអេកូឡូស៊ីទីក្រុងពហុវិស័យនិងពហុទំហំ។ ជាមួយគ្នានេះផងដែរ ស្របតាម de Boer and colleagues (២០២០) អត្ថបទស្រាវជ្រាវនេះបង្ហាញឱ្យឃើញថា ភាពងាយរងគ្រោះនិងភាពធន់ មានភាពប្រទាក់ក្រឡានិងពឹងផ្អែកគ្នាទៅវិញទៅមក។ មុនពេលពិចារណាយ៉ាងហ្មត់ចត់លើផ្នែកនីមួយៗនៃប្រធានបទនេះ អត្ថបទស្រាវជ្រាវនេះនឹងបង្ហាញពីទំហំទិដ្ឋភាព

សំខាន់ៗនៃទស្សនាទានភាពងាយរងគ្រោះ រួមជាមួយនឹងទស្សនៈជាក់លាក់មួយអំពីរបៀបដែល ទស្សនាទាននេះត្រូវបានដំណើរការនៅក្នុងបរិការណ៍នៃសកលលោកខាងត្បូងនិងអាស៊ីអាគ្នេយ៍ជាពិសេស។

## ភាពងាយរងគ្រោះនិងភាពធន់ជាក្របខណ្ឌទស្សនាទានសម្រាប់វិភាគការផ្លាស់ប្តូរទីក្រុង

ភាពងាយរងគ្រោះ គឺជាវិធានការជាក់លាក់មួយ ដែលមានអត្ថប្រយោជន៍និងសមស្របនៅក្នុងទីក្រុងដែលមានការផ្លាស់ប្តូរយ៉ាងឆាប់រហ័ស ពីព្រោះវិធានការនេះ ជាគំនិតប្រកបដោយជវភាពដែលគាំទ្រការវាយតម្លៃការផ្លាស់ប្តូរទេសភាពនៃហានិភ័យ អសន្តិសុខ និងភាពធន់។ ភាពងាយរងគ្រោះជួយយើង«ឱ្យយល់ពីទម្រង់នៃការប៉ះពាល់របស់មនុស្ស ភាពងាយទទួលរងគ្រោះ និងសមត្ថភាពក្នុងការដោះស្រាយ» (Krellenberg, ២០១៧: ៤១១)។ ពហុជំនាញរួមចំណែកដល់ការយល់ដឹងរបស់យើងអំពីភាពងាយរងគ្រោះជាមួយការសាយភាយ (prevalence) ពិសេសក្នុងការស្រាវជ្រាវ អំពីភាពងាយទទួលរងគ្រោះដោយការប្រែប្រួលអាកាសធាតុនិងគ្រោះមហន្តរាយធម្មជាតិ ការកាត់បន្ថយភាពក្រីក្រ និងវិធីសាស្ត្រគ្រប់គ្រងប្រកបដោយមនុស្សធម៌ ក្នុងការធ្វើការជាមួយប្រជាជនដែលកំពុងស្តារឡើងវិញពីគ្រោះមហន្តរាយឬការផ្លាស់លំនៅ។ ខណៈពេលដែលតំបន់ជាក់លាក់នៃការអង្កេតរបស់ពួកគេមានភាពខុសគ្នា វិធីសាស្ត្រផ្សេងៗទាំងនេះផ្តោតលើការព្រួយបារម្ភរបស់ពួកគេចំពោះសំណួរនៃសមត្ថភាពបន្សាំរបស់មនុស្សនៅចំណុចប្រសព្វនៃបរិស្ថានធម្មជាតិនិងបរិស្ថានដែលបង្កើតដោយមនុស្ស (built environments)។ ដើម្បីសិក្សាពីភាពងាយរងគ្រោះ គឺត្រូវសួរជាទូទៅថាតើកត្តាត្រួតស៊ីគ្នាអ្វីខ្លះដែលនឹងនាំឱ្យមានគ្រោះមហន្តរាយឬភាពធន់ខ្ពស់ជាងសម្រាប់ប្រជាជន អាស្រ័យលើបរិការណ៍ភូមិសាស្ត្រ អេកូឡូស៊ី សេដ្ឋកិច្ចនយោបាយសង្គម និងប្រវត្តិសាស្ត្រ (Birkmann, ២០០៦)?

និន្នាការដែលព្យាករណ៍ទុកជាមុននៃសំណួរនេះ ធ្វើឱ្យការសិក្សាអំពីភាពងាយរងគ្រោះមានភាពទាក់ទាញសម្រាប់អ្នកដែលធ្វើការលើគោលនយោបាយនិងផែនការ។ ការវាស់ស្ទង់ភាពងាយរងគ្រោះផ្តល់នូវលទ្ធភាពនៃការយល់ដឹងពីវិធីការពារឬកាត់បន្ថយការរងទុក្ខវេទនានានា (Patel et al, ២០២០, Yuen and Kong,២០០៩)។

ទោះបីយ៉ាងណាក៏ដោយ ការសន្យានៃគំរូសេចក្តីសន្និដ្ឋានទំនាក់ទំនងរវាងហេតុនិងផល (causal inference model)និងគំរូព្យាករណ៍ (predictive model) អាចជាការបំភាន់។ ភាពងាយរងគ្រោះនិងចំណុចប្រឆាំងរបស់វានិងភាពធន់ ទាមទារឱ្យមានការវិភាគដ៏ស្មុគស្មាញនិងពហុទំហំនៃចំនួនប្រជាជន ទីលម្ហ និងប្រព័ន្ធសង្គម។ Simon និងមិត្តរួមការងារ (២០១៥) បានចងក្រងជាឯកសារនូវបញ្ហាប្រឈមមួយចំនួនក្នុងការផលិតការស្រាវជ្រាវប្រៀបធៀបទៅនឹងភាពងាយរងគ្រោះ ដោយរួមទាំងនៅពេលទទួលបានទិន្នន័យគ្រប់គ្រាន់នៅក្នុងតំបន់ដែលរងគ្រោះខ្លាំងបំផុតដោយភាពក្រីក្រ ការរិចរិលបរិស្ថាន និងអំពើហិង្សា។ ដោយហេតុផលនេះ យើងសង្កត់ធ្ងន់ទៅលើសារៈសំខាន់នៃការសិក្សាដែលបានធ្វើមូលដ្ឋានីយកម្មដែលបង្កើតនិយមន័យនៃភាពងាយរងគ្រោះនិងភាពធន់ដែលមានស្រាប់ជាជាងទ្រឹស្តីទូទៅ។

### និយមន័យ

នៅក្នុងឯកសារនេះ យើងពិចារណានិយមន័យរបស់ UN-Habitat នៃភាពងាយរងគ្រោះនិងភាពធន់ជាចំណុចចាប់ផ្តើម ដែលមានអត្ថប្រយោជន៍ដើម្បីពង្រឹងការយល់ដឹងពហុគោលទស្សនាទានរបស់យើង។ និយមន័យផ្លូវការរបស់រាជរដ្ឋាភិបាលកម្ពុជាមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ។[2]

### ភាពងាយរងគ្រោះ

«ទំនោរឬទិន្នាការដែលនឹងត្រូវរងឥទ្ធិពលអាក្រក់។ ភាពងាយរងគ្រោះ រួមមាន ទស្សនាទាននិងធាតុផ្សេងៗគ្នារាប់បញ្ចូលទាំងវេទយិតភាពឬភាពងាយទទួលរងគ្រោះថ្នាក់និងកង្វះសមត្ថភាពក្នុងការដោះស្រាយនិងសម្របខ្លួន»។[3]

### ភាពធន់នៅទីក្រុង

ភាពធន់នៅទីក្រុង គឺជាសមត្ថភាពដែលអាចវាស់វែងបាននៃប្រព័ន្ធទីក្រុងណាមួយ ជាមួយប្រជាជនដែលរស់នៅទីក្រុងនោះជាប្រក្រតី ដើម្បីរក្សាការនៅបន្តតាមរយៈភាពតក់ស្លុតនិងភាពតានតឹងទាំងអស់ ខណៈពេលជាមួយគ្នា ធ្វើការសម្របខ្លួនជាវិជ្ជមាននិងផ្លាស់ប្តូរឆ្ពោះទៅរកនិរន្តរភាព។[4]

មិនខុសប្លែកគ្នាទេ មនុស្សនិងកន្លែងអាចងាយទទួលរងគ្រោះថ្នាក់ច្រើនឬតិច ពួកគេក៏អាចមានធនធានហេដ្ឋារចនាសម្ព័ន្ធ ជំនាញ ការគាំទ្រ និងបណ្តាញច្រើនឬតិចដែរ ដើម្បីប្រឈមមុខនឹងប្រភេទផ្សេងៗនៃហានិភ័យឬដើម្បីស្តារឡើងវិញនាពេលបន្ទាប់។ ភាពធន់នឹងជាប់ទាក់ទងនឹងសមត្ថភាពតស៊ូឬជាយុទ្ធសាស្ត្រការពារដែលជួយកាត់បន្ថយហានិភ័យចំពោះគ្រោះថ្នាក់។ គេអាចវិភាគភាពធន់ក្នុងលក្ខន្តិកៈនៃការចៀសវាងឬការប្រឈមនឹងហានិភ័យរបស់បុគ្គល គ្រួសារឬសហគមន៍ ជាសំណុំនៃយុទ្ធសាស្ត្រឆ្លើយតបបន្ទាន់នៅលើកម្រិតមូលដ្ឋានឬរដ្ឋ ឬជាគោលនយោបាយ ដើម្បីបែងចែកធនធានឬកសាងហេដ្ឋារចនាសម្ព័ន្ធក្នុងគោលដៅកាត់បន្ថយហានិភ័យ។

---

2 រដ្ឋាភិបាលកម្ពុជាកំណត់និយមន័យភាពងាយរងគ្រោះថា «ទំនោរឬដំណើរដែលងាយឬធាប់ទទួលផលប៉ះពាល់អវិជ្ជមាន ដោយរាប់បញ្ចូលនូវសញ្ញាណខុសៗគ្នាជាច្រើន រួមទាំងភាពរស់ឬភាពងាយទទួលគ្រោះថ្នាក់និងកង្វះសមត្ថភាពដោះស្រាយនិងបន្សាំ»។ រដ្ឋាភិបាលកម្ពុជា (ក្រសួងបរិស្ថាន/ក្រុមប្រឹក្សាជាតិស្តីពីការអភិវឌ្ឍប្រកបដោយចីរភាព) កំណត់ភាពធន់ជា «ភាពធន់ទ្រាំ ជាសមត្ថភាពនៃប្រព័ន្ធសង្គម-អេកូឡូស៊ី ដើម្បីទប់ទល់នឹងព្រឹត្តការណ៍គ្រោះថ្នាក់ឬការរំខានណាមួយ ដែលអាចឆ្លើយតបឬចាត់ចែងឡើងវិញ តាមវិធីដែលអាចរក្សាបាននូវមុខងារសំខាន់ៗ អត្តសញ្ញាណ និងរចនាសម្ព័ន្ធ ហើយដែលអាចរក្សាបាននូវសមត្ថភាព បន្សាំ រៀនសូត្រ និងការច្នៃប្រឌិត»។

3 UN-Habitat (២០២០) «ភាពងាយរងគ្រោះនិងហានិភ័យនៃការប្រែប្រួលអាកាសធាតុ: មគ្គុទេសក៍សម្រាប់ការវាយតម្លៃសហគមន៍ ផែនការសកម្មភាព និងការអនុវត្ត»ទំព័រទី10៖ អាចរកបានពី [https://unhabitat.org/sites/default/files/2020/05/climatechange_vulnerabilityandriskguide.pdf]

4 UN-Habitat (២០១៨)ឧបករណ៍ទម្រង់ភាពធន់របស់ទីក្រុង : អាចរកបានពី [http://urbanresiliencehub.org/wp-content/uploads /2018/10/CRPT-GuidePages-Online.pdf]

ខណៈពេលដែលភាពងាយរងគ្រោះនិងភាពធន់ត្រូវបានគេគិតថាជាផលបូកសូន្យ(zero-sum) (ឧ. កត្តាជាច្រើនបង្ហាញចំនួនប្រជាជន ដែលមានទាំងភាពងាយរងគ្រោះឬភាពធន់) អ្នកសិក្សាជាច្រើនផ្តល់នូវការក្រើនរំឭកជាគន្លឹះថា ទីក្រុងទាំងនោះស្មុគស្មាញណាស់សម្រាប់ការតំណាងដោយគណិតវិទ្យា(Patel et al., ២០២០; de Boer et al., ០១៦; Matyas and Pelling, ២០១៤)។ ដូចដែលលោក Patel និងសហការី (២០២០: ៣) សរសេរថា «ប្រជាជនដែលងាយរងគ្រោះ...ក្នុងទីក្រុង បង្ហាញយ៉ាងច្បាស់ពីសហត្ថិភាពនៃហានិភ័យនិងភាពធន់នៅចំពោះមុខគ្រោះថ្នាក់ប្រចាំថ្ងៃដែលពួកគេប្រឈមមុខ" ។ ភាពងាយរងគ្រោះនិងភាពធន់ទ្រាំមិនត្រឹមតែមាននូវសហត្ថិភាពប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងមានលក្ខណៈជាក់លាក់ទៀតផង។ នោះគឺយុទ្ធសាស្ត្រការពារដែលត្រូវបានដាក់ពង្រាយដោយមនុស្សមួយចំនួន អាចធ្វើឱ្យកើនឡើងនូវភាពងាយរងគ្រោះរបស់អ្នកដទៃដោយផ្ទាល់ឬដោយប្រយោល តាមវិធីដែលមិនងាយរំពឹងទុកបាន។ ការយល់ដឹងអំពីកម្រិតអន្តរកម្មក្នុងចំណោមហានិភ័យនិងវិធីសាស្ត្រការពាររបស់អ្នករស់នៅទីក្រុងដែលស្ថិតក្នុងឋានានុក្រមសង្គមនិងការចែកចាយមិនស្មើគ្នានៃធនធាននិងហេដ្ឋារចនាសម្ព័ន្ធ គឺជាគន្លឹះក្នុងការវាស់ស្ទង់ភាពងាយរងគ្រោះរបស់ទីក្រុង។

ក្របខណ្ឌភាពងាយរងគ្រោះ មានអត្ថប្រយោជន៍ជាពិសេសនៅក្នុងបរិស្ថានទីក្រុង ដែលការស្រាវជ្រាវអាចជួយកំណត់ពីរបៀបបណ្តាញស្មុគស្មាញនៃទំនាក់ទំនងនិងប្រព័ន្ធរបស់សង្គម នយោបាយ និងសេដ្ឋកិច្ច ដែលប្រសព្វគ្នាក្នុងជីវិតរស់នៅរបស់អ្នករស់នៅតាមទីក្រុង តាមមធ្យោបាយដែលបង្ហាញឱ្យឃើញពីភាពងាយទទួលរងគ្រោះថ្នាក់ច្រើនជាងឬតិចជាងនេះ(Graham and Marvin, ២០០១)។ យោងតាម de Boer និងសហការី (២០១៦: ៣) ភាពងាយរងគ្រោះនៅទីក្រុង ដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធនឹងទស្សនាទាននៃភាពផុយស្រួយ ជាប់ទាក់ទងទៅនឹងសមត្ថភាពរបស់ទីក្រុងចំពោះ «ការបំពេញមុខងារស្នូលរបស់ទីក្រុងផ្ទាល់ក្នុងការបង្ហាញឱ្យឃើញពីហានិភ័យខាងក្នុងនិងខាងក្រៅ»។ ស្របពេលជាមួយគ្នាផង វាមានមូលដ្ឋានសមហេតុផលដែលការគិតអំពីទីក្រុងថាជាការទាក់ទងគ្នារបស់ពហុអង្គប្រកបដែលត្រួតគ្នានិងស្មុគស្មាញជាច្រើន។ អង្គប្រកបទាំងនេះ «ដែលទាក់ទងគ្នាយ៉ាងជវនៈនៅក្នុងទម្រង់នៃល្បឿន ទំហំវិសាលភាព និងភាពស្មុគស្មាញ» (Krellenberg et al., ២០១៧: ៤១៣) តម្រូវឱ្យមានការយល់ដឹងអំពីភាពងាយរងគ្រោះដែលពឹងផ្អែកទៅនឹងពេលវេលានិងលម្ហ។ ទីក្រុង ជាក្បាលម៉ាស៊ីននៃកំណើននិងសមាច័យទុន មជ្ឈមណ្ឌលនៃអំណាច មជ្ឈមណ្ឌលកណ្តាលនៃវិសមភាពរបាយទ្រព្យសម្បត្តិ និងលម្ហនៃលទ្ធភាពសង្គម កាលានុវត្តភាពសេដ្ឋកិច្ចនិងវិសមភាព (Pelling, ២០០៣)។ ដូចទៅនឹងទីលម្ហត្រូវបង្កើតឡើងឬសាងសង់ឡើងដែរ ទីក្រុងនានាត្រូវបានបង្កប់នៅក្នុងបរិស្ថានធម្មជាតិដែលស្ថិតក្នុងដំណើរប្រែប្រួល។ ទីក្រុង ជាកន្លែងសម្រាប់ប្រើប្រាស់ធនធាននិងការផលិតកាកសំណល់និងការបំពុលបរិស្ថាន(Sassen and Dotan, ២០១១)។ ដូច្នេះ ភាពងាយរងគ្រោះនិងភាពធន់ត្រូវតែគិតនូវអ្វីដែល Lefebvre (១៩៩១) បានសំដៅទៅលើ គឺលម្ហរូបវន្តនិងសង្គម លម្ហដែលមានមនុស្សរស់នៅនិងលម្ហដែលមានការបង្កើតនៃទំនាក់ទំនង ដំណើរការ និងការជជែកពិក្សា។

វិធីសាស្ត្រមួយដែលត្រូវបានគេស្នើឡើង ដើម្បីវាស់វែងភាពងាយរងគ្រោះនិងភាពធន់នៅក្នុងបរិស្ថានទីក្រុងជាវិធីសាស្ត្រដែលធ្វើសហមារណកម្មប្រព័ន្ធត្រួតគ្នា ចាត់ទុកភាពងាយរងគ្រោះជាទំហំគ្មានទិសដៅ(scalar) និងភាគបទពិសោធនៅកម្រិតខុសគ្នា(Bennett et al., ២០១៦)។

Campbell (២០១៦) កំណត់ប្រព័ន្ធទីក្រុងជាប្រព័ន្ធរងនានា ដែលមានការផ្សារភ្ជាប់គ្នា។ ប្រព័ន្ធរងទាំងនេះរួមបញ្ចូលនូវសេដ្ឋកិច្ចនិងការចិញ្ចឹមជីវិត នយោបាយនិងអភិបាលកិច្ច ហេដ្ឋារចនាសម្ព័ន្ធនិងសេវាកម្ម លម្ហនិងការតាំងលំនៅ ព្រមទាំងទំនាក់ទំនងនិងរចនាសម្ព័ន្ធសង្គមនិងវប្បធម៌។ កម្រិតគន្លឹះនៃការវិភាគសម្រាប់ការគិតអំពីភាពងាយរងគ្រោះ រួមមាន ប្រព័ន្ធបុគ្គលឬគ្រួសារ សហគមន៍និងទីក្រុងជាទូទៅ (Patel et al., ២០២០)។ ទំហំនៃភាពងាយទទួលរងគ្រោះ ក៏ខុសគ្នារវាងហានិភ័យបុគ្គលនិងហានិភ័យដែលប៉ះពាល់ដល់ផ្នែកធំៗនៃចំនួនប្រជាជនឬទីក្រុងទាំងមូល ប្រទេសឬតំបន់(Blaikie et al., ១៩៩៤)។

ជីវិតរស់នៅទីក្រុងមិនត្រឹមតែមានទំនាក់ទំនងកម្រិតផ្សេងៗគ្នាប៉ុណ្ណោះទេ ពួកគេថែមទាំងហ៊ុមព័ទ្ធដោយទំនាក់ទំនងដែលលាតសន្ធឹងហួសព្រំដែននៃតំបន់ទីក្រុង(metropolitan area)ទៅសហគមន៍ជនបទដែលត្រូវបានចងភ្ជាប់ទៅនឹងទីក្រុងតាមរយៈប្រព័ន្ធស្បៀងអាហារ និន្នាការបរិស្ថាន និងតាមរយៈគំរូនៃការធ្វើចំណាកស្រុកក្នុងស្រុក និងទីផ្សារការងារ (Tacoli et al., ២០១៥)។ ដោយការប្រើប្រាស់សំណុំទិន្នន័យដែលអាចរកបាន de Boer និងសហការី (២០១៦: ៤-៧) កំណត់ «កត្តាភាពផុយស្រួយ» និង«កត្តាភាពធន់» ចំនួន៧(សូមមើលតារាងនៅទំព័របន្ទាប់)។

ការវិភាគអំពីភាពងាយរងគ្រោះក្នុងបរិការណ៍នៃការធ្វើនគរូបនីយកម្មយ៉ាងឆាប់រហ័ស នៅក្នុងសកលលោកខាងត្បូងលើកឡើងនូវវិធីផងដែរ។ បរិស្ថានដែលបង្កើតដោយមនុស្ស ព្រមទាំងប្រព័ន្ធនៃការធ្វើផែនការនិងអភិបាលកិច្ច ច្រើនតែឆ្លុះបញ្ចាំងពីតថភាពអាណានិគមនិយម ក៏ដូចជាលំហូរសហសម័យនៃមូលធននៅក្នុងពិភពលោកមួយ ដែលត្រូវបានកំណត់ដោយវិសមភាពសកល។ នៅក្នុងសៀវភៅ *ពិភពលោកនៃតំបន់សំណង់មិនរៀបរយ (Planet of Slums)*របស់លោក Davis (២០០៦) បង្ហាញពីរបៀបដែលការផ្សារភ្ជាប់ទាំងនេះមានសារៈសំខាន់ចំពោះការរីកសាយនៃការតាំងលំនៅក្រៅផ្លូវការឬសំណង់មិនរៀបរយ។ បញ្ហាអសន្តិសុខនិងបញ្ហាសង្គមខ្លាំងក្រៃលែង ដែលកើតឡើងក្នុងលម្ហផ្សេងៗមានផលប៉ះពាល់ស្ទើរតែគ្រប់ផ្នែកនៃជីវិតនិងអង្គការសង្គម (UN Habitat, ២០១៦)។ ជំងឺរាតត្បាតសាកល កូវីដ-១៩ (COVID-19) បានធ្វើឱ្យមានការកាត់បន្ថយជវភាព៖ ធនាគារពិភពលោកប៉ាន់ស្មានការកើនឡើងយ៉ាងខ្លាំងនៃភាពក្រីក្រខ្លាំងបំផុតនៅលើពិភពលោក(ការកើនឡើងពី ៨៨ ទៅ ១១៥លាននាក់ឬច្រើនរហូតដល់១៥០លាននាក់) អាស្រ័យលើទំហំនៃការធ្លាក់ចុះសេដ្ឋកិច្ច។ ការណ៍នេះនឹងជះឥទ្ធិពលពិសេសដល់ប្រជាជនក្រីក្រក្នុងទីក្រុងដែលកាន់តែមានភាពលំបាកឡើង។[5]

---

5 www.worldbank.org/en/news/press-release/2020/10/07/covid-19-to-add-as-many-as-150-million-extreme-poor-by-2021

| កត្តាភាពផុយស្រួយ | កត្តាភាពធន់ |
|---|---|
| នគរូបនីយកម្មឆាប់រហ័សនិងមិនមានការគ្រប់គ្រង | ប្រាក់ចំណូលនិងសមភាពសង្គម |
| ប្រាក់ចំណូលនិងវិសមភាពសង្គម | សិទ្ធិភាពក្នុងសង្គម |
| ការប្រមូលផ្តុំភាពក្រីក្រ | ការការពារសង្គម |
| ភាពអត់ការងារធ្វើ | សន្តិសុខសេដ្ឋកិច្ច |
| ឱនភាពការល្បាតនិងយុត្តិធម៌ | ការផ្តល់សេវាកម្មមូលដ្ឋាន |
| តថាភាពនិងការយល់ឃើញថាអសន្តិសុខ | យន្តការការល្បាតនិងតុលាការប្រកបដោយប្រសិទ្ធភាព |
| ការប្រឈមនឹងគ្រោះថ្នាក់ធម្មជាតិ | កិច្ចសហប្រតិបត្តិការខ្ពស់រវាងសហគមន៍-រដ្ឋាភិបាលនិងអន្តររដ្ឋាភិបាល |

ប្រភព៖ De Boer et al., ២០១៦: ៤-៧

## ភាពងាយរងគ្រោះក្នុងទីក្រុងនៅអាស៊ីអាគ្នេយ៍និងកម្ពុជា

យោងតាមទស្សនវិស័យនៃលម្ហទីក្រុងរបស់អាស៊ីអាគ្នេយ៍ ក្របខណ្ឌងាយរងគ្រោះផ្តល់នូវផ្នែកពាក់ព័ន្ធជាច្រើន ទាក់ទងនឹងបរិការណ៍នៃបរិស្ថានដែលមានការផ្លាស់ប្តូរយ៉ាងឆាប់រហ័ស។ នៅឆ្នាំ២០១៩ ចំនួនពាក់កណ្តាលនៃចំនួនប្រជាជនអាស៊ីអាគ្នេយ៍បានកំពុងរស់នៅក្នុងតំបន់ទីក្រុង[6] ទោះបីជាអត្រាភាគរយនៅមានកម្រិតទាបនៅក្នុងប្រទេសមួយចំនួន ដូចជាប្រទេសកម្ពុជាក៏ដោយ (UN, ២០១៨)។ ទីក្រុងនានាក្នុងតំបន់ គឺជាតំបន់ដែលមានទាំងវិសមភាព ដែលកំពុងមានការកើនឡើងនិងអត្រាខ្ពស់នៃការធ្វើចំណាកស្រុកពីជនបទ ទៅទីក្រុង (Lawreniuk, ២០១៦; Kanbur & Zhuang, ២០១៣)។ ក្នុងចំណោមការផ្លាស់ប្តូរទីក្រុងនានា ដូចជា រាជធានីភ្នំពេញ សុខុមាលភាពរបស់ប្រជាជនពឹងផ្អែកទៅលើកត្តាបុគ្គល ដូចជា ស្ថានភាពសេដ្ឋកិច្ចសង្គមរបស់ពួកគេ កត្តារចនាសម្ព័ន្ធមិនអំណោយផល ដូចជាបរិយាកាសនយោបាយនិងសេដ្ឋកិច្ច កត្តារចនាសម្ព័ន្ធខាងក្រៅ ដូចជាសេដ្ឋកិច្ចពិភពលោក និងនិន្នាការបរិស្ថានក្នុងមូលដ្ឋាន តំបន់ និងពិភពលោក ដែលរួមទាំងការផ្លាស់ប្តូរអាកាសធាតុ។

[6] https://population.un.org/wup/

ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ តំបន់អាស៊ីអាគ្នេយ៍ត្រូវបានគេកំណត់ថាជាតំបន់មួយដែលងាយរងគ្រោះបំផុតក្នុងចំណោមតំបន់ដទៃទៀត ចំពោះការគំរាមកំហែងនៃការប្រែប្រួលអាកាសធាតុ ដូចជា ការកើនឡើងនូវកម្ពស់ទឹកសមុទ្រនិងអាកាសធាតុធ្ងន់ធ្ងរ រួមមាន ព្យុះស៊ីក្លូន ទឹកជំនន់ គ្រោះរាំងស្ងួត និងការបាក់ដី(World Bank ២០០៧)។ កត្តាមួយក្នុងចំណោមកត្តាជាច្រើន គឺអាកាសធាតុ ដោយសារតំបន់នេះស្ថិតនៅតំបន់អាកាសធាតុត្រូពិក ដែលប្រជាជនប្រមាណ៨០%នៃប្រជាជនក្នុងតំបន់នេះរស់នៅក្នុងចម្ងាយ១០០គីឡូម៉ែត្រនៃតំបន់ឆ្នេរ ហើយភាគច្រើននៃឆ្នេរសមុទ្រនៅអាស៊ីអាគ្នេយ៍មានកម្ពស់ទាប(ADB, ២០០៩)។ ការប្រសព្វគ្នាជាមួយកត្តាបរិស្ថានដែលហួសប្រមាណទាំងនេះ ជាការអនុវត្តនៃឧស្សាហកម្មនិស្សារណកម្មដែលនាំឱ្យមានការកាប់បំផ្លាញព្រៃឈើនិងការហូរច្រោះ។ ដូចគ្នានេះដែរ នៅក្នុងមហាអនុតំបន់ទន្លេមេគង្គដែលមានបរិស្ថានទីក្រុងជាច្រើន រួមមាន ឆ្នេរសមុទ្រ ទន្លេមេគង្គ និងបណ្តាញដៃទន្លេ អ្នករស់នៅទីក្រុងទាំងនោះ ក៏ទទួលរងនូវផលប៉ះពាល់ដោយចេតនានិងអចេតនានៃវារីអគ្គិសនីនៅក្នុងតំបន់។ វារីអគ្គិសនីដែលគួរឱ្យកត់សម្គាល់បំផុត គឺសំណង់ទំនប់វារីអគ្គិសនីរបស់ចិន នៅតំបន់មេគង្គក្រោម(Grumbine et al., ២០១២)។

នៅក្នុងបរិការណ៍ទីក្រុង និន្នាការពីរនៃការអភិវឌ្ឍទីក្រុងយ៉ាងឆាប់រហ័សនិងធ្វេសប្រហែសឬភាពយឺតយ៉ាវផ្នែកហេដ្ឋារចនាសម្ព័ន្ធ បានបណ្តាលឱ្យមានការបំផ្លាញធំធេងនៃប្រព័ន្ធធារាសាស្ត្រធម្មជាតិនិងប្រព័ន្ធសំណង់ប្រព័ន្ធធារាសាស្ត្រ និងប្រព័ន្ធបង្ហូរទឹក ដើម្បីទទួលបានអត្រាខ្ពស់នៃការរីកចម្រើននៅទីក្រុង (Nitivattananon et al., ២០១២)។ ទីក្រុង ដូចជាទីក្រុងបាងកកនិងភ្នំពេញបានជួបប្រទះនឹងទឹកជំនន់ធ្ងន់ធ្ងរក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ដែលមានការចូលរួមតិចតួចពីលទ្ធផលនៃខ្យល់មូសុង។ ប៉ុន្តែ ច្រើនជាងនេះគឺដោយសារតែការគ្រប់គ្រងមិនត្រឹមត្រូវនិងការកសាងសំណង់អាគារច្រើនហួស នៅលើប្រព័ន្ធលូបង្ហូរទឹកធម្មជាតិនៅក្នុងភូមិសាស្ត្រនៃលម្ហទីក្រុង ជាពិសេស នៅតាមជាយទីក្រុង(urban fringe)ឬនៅក្នុងការតាំងលំនៅក្រៅផ្លូវការ។ (Limthongsakul et al., ២០១៧)។ ការណ៍នេះបង្ហាញថា ភាពងាយរងគ្រោះចំពោះគ្រោះមហន្តរាយធម្មជាតិនៅក្នុងទីក្រុងនៃតំបន់អាស៊ីអាគ្នេយ៍ ដែលត្រូវតែគិតអំពីកំណើនការគំរាមកំហែងនៃការប្រែប្រួលអាកាសធាតុ ការផ្លាស់ប្តូរប្រជាសាស្ត្រ ក៏ដូចជាប្រព័ន្ធនយោបាយនិងសេដ្ឋកិច្ច ដែលគ្រប់គ្រងទីលម្ហទាំងនេះ។ ការគិតអំពីរបៀបដែលភាពធន់និងភាពងាយរងគ្រោះមានសហគ្គិភាព Limthongsakul និងសហការី (២០១៧) ក៏បានចង្អុលបង្ហាញថា វិធីសាស្ត្រការពារដែលត្រូវបានប្រើប្រាស់ដោយសហគមន៍ស្តុកស្តម្ភ(ឬដោយទីក្រុងឬរដ្ឋ ជាតំណាងរបស់ពួកគេ)ជាញឹកញាប់ អាចធ្វើឱ្យផលវិបាកនៃទឹកជំនន់កាន់តែអាក្រក់សម្រាប់ផ្នែកខ្លះនៃតំបន់ទីក្រុងដែលមានប្រាក់ចំណូលតឹងតែងនិងចំណូលទាប។ មានការលើកឡើងនូវសំណួមពរអំពីសមាយាតធម្មជាតិនៃកត្តារួមផ្សំទាំងនេះ នៅក្នុងប្រទេសដែលមានប្រាក់ចំណូលទាប ដូចជាប្រទេសកម្ពុជា។ Nitivattananon និងសហការី(២០១២: ៧៥៨) សរសេរថា«ផលប៉ះពាល់កាន់តែអាក្រក់ទៅៗ ដោយសារតែធនធានកម្រដែលអាចត្រូវបានប្រើសម្រាប់ការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ច ត្រូវបានបាត់បង់ឬត្រូវចំណាយសម្រាប់ការខិតខំប្រឹងប្រែងស្តារឡើងវិញ បន្ទាប់ពីមានគ្រោះមហន្តរាយធម្មជាតិ។

វិបត្តិសកលដែលជះឥទ្ធិពលដល់បណ្តាញផលិតកម្មនិងបណ្តាញផ្គត់ផ្គង់ មានផលប៉ះពាល់ខាងយេនឌ័រទ្រង់ទ្រាយធំសម្រាប់កម្លាំងពលកម្មស្ត្រីនៅអាស៊ីអាគ្នេយ៍ក្នុងវិស័យតម្រង់ទិសនាំចេញ រួមទាំង សម្លៀកបំពាក់ (Green et al., ២០១០; Praparpun, ២០១០)។ ដូចមាននៅក្នុងឯកសារស្រាវជ្រាវរបស់អង្គការ Oxfam ពីឆ្នាំ

២០១០ Green និងសហការី កត់សម្គាល់ថាវិបត្តិសេដ្ឋកិច្ចពិភពលោក ឆ្នាំ២០០៨-២០០៩ បានបណ្តាលឱ្យមានការបញ្ឈប់បណ្តោះអាសន្នយ៉ាងធំធេងនិងភាពមិនច្បាស់លាស់នៃកម្លាំងពលកម្មនៅអាស៊ីអាគ្នេយ៍។ ជាពិសេសស្ត្រីមានការប៉ះទង្គិចយ៉ាងខ្លាំង ដោយសារតែការសន្មតថាភេទស្ត្រីមានលក្ខណៈទន់ខ្សោយ យេនឌ័រដែលមានលក្ខណៈងាយធ្វើចំណាកស្រុកទៅជនបទនិងទីក្រុង និងដោយសារតែបន្ទុកថែទាំនិងពលកម្មទ្វេដង ដែលបានដាក់លើស្ត្រី។ ដូចគ្នានេះដែរ ទំហំយេនឌ័រនៃការធ្វើចំណាកស្រុកពីជនបទ ទៅកាន់ទីក្រុង មានការជាប់ពាក់ព័ន្ធដល់កម្លាំងពលកម្មដែលទាក់ទងនឹងការកេងប្រវ័ញ្ច អំណាច និងលទ្ធភាពនៃការចល័តសង្គម (Derks, ២០០៨)។ ជនចំណាកស្រុកពីជនបទដែលតាំងលំនៅក្នុងតំបន់ទីក្រុងមាននិន្នាការច្រើនចូលទៅក្នុងការងារក្រៅផ្លូវការនិងប្រឈមនឹងចន្លោះប្រហោងនៃការការពារកម្លាំងពលកម្មនិងសុខុមាលភាពសង្គម (Tacoli et al., ២០១៥)។ ដោយសារកម្លាំងពលកម្មក្រៅផ្លូវការតំណាងឱ្យ ៥០-៦០% នៃកម្លាំងពលកម្មនៅក្នុងទីក្រុងជាច្រើននៅអាស៊ីអាគ្នេយ៍ ដូចនេះ Jamil (២០១៣) ស្នើរឡើងថា ពួកគេគឺជាប្រជាជនសំខាន់ដែលត្រូវបានដាក់បញ្ចូលក្នុងការវិភាគភាពងាយរងគ្រោះនៅទីក្រុង។ និន្នាការខាងលើចង្អុលបង្ហាញពីមធ្យោបាយដែលការប៉ះទង្គិច ដូចជាការធ្លាក់សេដ្ឋកិច្ចឬគ្រោះថ្នាក់បរិស្ថាន ទាំងក្នុងតំបន់និងពិភពលោក។ ការប៉ះទង្គិចត្រួតស៊ីគ្នាជាមួយនឹងភាពងាយរងគ្រោះដែលជាប់ទាក់ទងនឹងយេនឌ័រ ភាពក្រីក្រ កម្លាំងពលកម្ម និងការធ្វើចំណាកស្រុកដែលត្រូវបានផលិតជាប្រវត្តិសាស្ត្រនិងជាចំណែកនៃសង្គមនិងនយោបាយផងដែរ។ ការកសាងសមត្ថភាពសម្របខ្លួនមានភាពចាំបាច់ណាស់ដើម្បីអាចដោះស្រាយបញ្ហាសង្គមទាំងនេះ ហើយទីក្រុងនានាកាន់តែមានភាពធន់នឹងបញ្ហាប្រឈមផ្សេងៗ។ ដូចគ្នានេះដែរ យើងត្រូវយកចិត្តទុកដាក់ចំពោះយុទ្ធសាស្ត្រការពារដែលមានស្រាប់និងដែលបានដាក់ឱ្យប្រើប្រាស់ក្នុងមូលដ្ឋាន ដូចជា ទម្រង់នៃការគាំទ្រសហគមន៍ ការខិតខំប្រឹងប្រែងក្នុងការរៀបចំការងារ និងបណ្តាញសង្គម។ មធ្យោបាយទាំងនេះ ត្រូវបានធ្វើនិងបន្តធ្វើជាឧបករណ៍សម្រាប់ភាពធន់របស់កម្មករដែលមិនទៀងទាត់នៅក្នុងតំបន់ទីក្រុងនៅអាស៊ីអាគ្នេយ៍ រួមទាំងជនចំណាកស្រុកនៅតាមជនបទ(Green et al., ២០១០)។

ភ្នំពេញដែលជាទីក្រុងធំបំផុតរបស់ប្រទេសកម្ពុជា តម្រូវឱ្យមានការចងក្រងឯកសារកត្តាប្រសព្វគ្នាទាំងនេះដែលបង្កើតឱ្យមានភាពងាយរងគ្រោះនិងជាយុទ្ធសាស្ត្រការពារដែលអាចធ្វើឱ្យមានការសម្រេចបាននូវកម្រិតមួយចំនួននៃភាពធន់។

យោងតាមធនាគារពិភពលោក(២០១៧) បានបង្ហាញថា ស្របពេលដែលក្របខណ្ឌបទប្បញ្ញត្តិនិងការធ្វើផែនការទៅប្រជុំជនរបស់ប្រទេសកម្ពុជា បានចង្អុលបង្ហាញនូវផ្លូវដែលអាចធ្វើទៅបាន ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព ដែលលទ្ធភាពនេះត្រូវបានបន្ធូរបន្ថយនៅពេលលទ្ធផលវិនិយោគផ្ទាល់ពីបរទេសទទួលបានផលចំណេញក្នុងរយៈពេលខ្លី តាមរយៈគម្រោងសាងសង់ធំៗនិងចន្លោះប្រហោងនៃហេដ្ឋារចនាសម្ព័ន្ធទាក់ទងនឹងការដឹកជញ្ជូន ប្រព័ន្ធលូទឹកកខ្វក់ ប្រព័ន្ធលូបង្ហូរទឹក និងការផ្គត់ផ្គង់ទឹក។ របាយការណ៍ថ្មីៗនេះរបស់កម្មវិធីស្បៀងអាហារពិភពលោក(២០១៩) បានកត់សម្គាល់ថាបញ្ហាប្រឈមសំខាន់ៗសម្រាប់អ្នករស់នៅទីក្រុងក្នុងរាជធានីភ្នំពេញ រួមមាន វិសមភាពប្រាក់ចំណូល បំណុល ការទទួលបានសេវាកម្មទឹកស្អាតនិងការគ្រប់គ្រងកាកសំណល់ និងលទ្ធភាពក្នុងការទទួលបានអត្ថប្រយោជន៍សំខាន់ៗ។ របាយការណ៍នេះ បង្ហាញពីវិសមភាពគួរឱ្យកត់សម្គាល់ក្នុងការបែងចែកនូវបញ្ហាប្រឈមទាំងនេះជាមួយអ្នករស់នៅតំបន់ជាច់ស្រយាលនៃទីក្រុងដែលជួបការលំបាកខ្លាំងជាងអ្នករស់នៅកណ្តាលទីក្រុង។ របាយការណ៍នេះក៏បង្ហាញពីស្ថានភាពបញ្ហាប្រឈមទាំងនេះនៅក្នុងបរិការណ៍

នៃការធ្វើចំណាកស្រុកពីជនបទ ទៅទីក្រុងយ៉ាងឆាប់រហ័សនិងការអភិវឌ្ឍទីក្រុងដោយមិនមានការគ្រប់គ្រង ដែលបណ្តាលឱ្យមានការកកស្ទះធ្ងន់ធ្ងរនិងសេវាកម្មសាធារណៈមិនគ្រប់គ្រាន់ផងដែរ។

## ភាពងាយរងគ្រោះនិងនគរូបនីយកម្មក្នុងរាជធានីភ្នំពេញ : គម្រោងនៃឯកសារស្រាវជ្រាវនៅក្នុងសម្ងួហកម្មនេះ

ឯកសារស្រាវជ្រាវនេះ ផ្តោតលើទិដ្ឋភាពជាច្រើននៃជីវិតនៅទីក្រុងនៅក្នុងប្រទេសកម្ពុជានិងទិដ្ឋភាពជាច្រើនទៀត។ ការចូលរួមវិភាគទានខាងក្រោម ផ្តល់នូវការវិភាគយ៉ាងសំបូរបែបអំពីរបៀបដែលទិដ្ឋភាពផ្សេងគ្នានៃនគរូបនីយកម្មរបស់រាជធានីភ្នំពេញទាក់ទងទៅនឹងសំណួរផ្សេងៗអំពីភាពងាយរងគ្រោះនិងភាពធន់។ នៅក្នុងផ្នែកខាងក្រោម លោក ង៉ោ ណត្ថារុន ផ្តល់នូវទិដ្ឋភាពទូទៅនៃការជជែកអំពីភាពក្រីក្រក្នុងចំណោមក្រសួងពាក់ព័ន្ធរបស់រាជរដ្ឋាភិបាលកម្ពុជានិងទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិនានា ដែលបានវិវត្តពីការផ្តោតជាសំខាន់លើជនបទទៅទិដ្ឋភាពមួយដែលយល់ដឹងអំពីអន្តរទំនាក់ទំនងរវាងសេដ្ឋកិច្ចជនបទនិងទីក្រុងនិងជីវភាពសង្គម។ លោកង៉ោ ណត្ថារុន ភ្ជាប់ទស្សនវិស័យផ្លាស់ប្តូរនេះ នៅក្នុងបរិការណ៍នៃការរីកចម្រើននិងនគរូបនីយកម្មយ៉ាងឆាប់រហ័សរបស់ប្រទេសកម្ពុជានិងស្នើរយោបល់ថា ភាពងាយរងគ្រោះជាទស្សនាទានមួយលេចចេញមកនៅក្នុងការជជែកពិភាក្សារបស់វិស័យអភិវឌ្ឍន៍និងជាមធ្យោបាយមួយ ដើម្បីស្វែងយល់ពីអសន្តិសុខរបស់ប្រជាជនកម្ពុជារាប់សែននាក់ដែលលេចចេញពីក្រុមប្រភេទនៃ«ភាពក្រីក្រ» នៅក្នុងរយៈពេលពីរទសវត្សចុងក្រោយនេះ។ ប៉ុន្តែ អ្នកដែលធ្លាប់ជា«អ្នកដែលជិតធ្លាក់ខ្លួនក្នុងភាពក្រីក្រ» ហើយ ដូច្នេះ ពួកអាចធ្លាក់ក្រោមភាពក្រីក្រយ៉ាងងាយស្រួល។ លោក ង៉ោ ណត្ថារុនបានក្រើនរំឭកថា ភាគច្រើននៃវិចារណនិពន្ធភាពងាយរងគ្រោះនិងភាពធន់នៅតាមទីក្រុងនៅប្រទេសកម្ពុជា មាននិន្នាការផ្តោតលើហានិភ័យនៃការប្រែប្រួលអាកាសធាតុឬប្រជាជនក្រីក្រ(ឬ «អ្នកដែលជិតធ្លាក់ខ្លួនក្នុងភាពក្រីក្រ»)។ វិធីសាស្ត្រគ្រប់គ្រងភាពងាយរងគ្រោះបែបពហុជំនាញ អាចជំរុញឱ្យរដ្ឋាភិបាលកំណត់ឫសគល់បញ្ហានៃហានិភ័យ ភាពអសន្តិសុខ និងភាពងាយទទួលរងគ្រោះ ដោយជំនួសឱ្យការកំណត់យុទ្ធសាស្ត្ររយៈពេលខ្លី ដែលសំដៅកាត់បន្ថយទម្រង់អាក្រក់បំផុតនៃភាពក្រីក្រ។

បណ្ឌិត ប៉ក់ គឹមជឿន បានអនុលោមតាមឯកសារស្រាវជ្រាវរបស់លោក ង៉ោ ណត្ថារុននិងផ្តល់នូវ*ផ្នែកត្រូវពិភាក្សា* លើការធ្វើចំណាកស្រុកពីជនបទ ទៅទីក្រុងនៅកម្ពុជា ដែលឯកសារនេះបានដកស្រង់ចេញពីរបាយការណ៍របស់លោក ជាមួយកម្មវិធីស្បៀងអាហារពិភពលោក(២០១៩)។ បណ្ឌិត ប៉ក់ គឹមជឿន ផ្តល់នូវការក្រឡេកមើលទំហំនៃការធ្វើចំណាកស្រុកនៅក្នុងស្រុក ក្នុងប្រទេសកម្ពុជា ដោយកត់សម្គាល់ថា៣៥%នៃគ្រួសារនៅជនបទមានសមាជិកយ៉ាងតិច១នាក់ដែលបានផ្លាស់លំនៅ ទៅតំបន់ទីក្រុង។ លោកក៏បានផ្តល់នូវការវិភាគមួយចំនួននៃកត្តាជំរុញនិងកត្តាទាក់ទាញនៃការធ្វើចំណាកស្រុកនេះនិងពិចារណាពីផលប៉ះពាល់នៃការធ្វើចំណាកស្រុកនេះ ទៅលើគ្រួសារនៅជនបទ ទាក់ទងនឹងខ្សែចង្វាក់ថែរក្សានិងការគាំទ្រផ្នែកហិរញ្ញវត្ថុ។ *ផ្នែកត្រូវពិភាក្សា* របស់បណ្ឌិត ប៉ក់ គឹមជឿន បានធ្វើឱ្យកាន់តែស៊ីជម្រៅដល់ការវិភាគរបស់លោក ង៉ោ ណត្ថារុន ជាមួយនឹងទិន្នន័យពិសោធន៍ ដែលបង្ហាញពីរបៀបដែលភាពងាយរងគ្រោះនៅជនបទនិងទីក្រុងមានទំនាក់ទំនងខ្លាំងទៅនឹងចំនួន

ប្រជាជននៅទីក្រុងភ្នំពេញ ដែលត្រូវបានផ្សារភ្ជាប់តាមរយៈញាតិសន្តាននិងគន្លងចំណាកស្រុក ទៅកាន់ទីលម្ហជនបទ។

ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ការយកចិត្តទុកដាក់ជាពិសេស ត្រូវបានផ្តោតទៅលើការតាំងទីលំនៅក្រៅផ្លូវការរបស់រាជធានីភ្នំពេញ ពីព្រោះជាកន្លែងពោរពេញដោយហានិភ័យត្រួតជាន់គ្នាជាច្រើន ដែលធ្វើឱ្យអ្នករស់នៅទីនោះងាយរងទទួលគ្រោះថ្នាក់យ៉ាងខ្លាំង។ យោងតាមការវាយតម្លៃភាពក្រីក្រផ្ទាល់ខ្លួនរបស់ក្រុង(ក្រសួងផែនការឆ្នាំ២០១២) គិតត្រឹមឆ្នាំ២០១១ ប្រមាណ១៥ភាគរយនៃប្រជាជនសរុប១,៨លាននាក់របស់ទីក្រុង កំពុងរស់នៅក្នុងការតាំងលំនៅក្រៅផ្លូវការ។ ការតាំងលំនៅក្រៅផ្លូវការជាច្រើននៅទីក្រុងភ្នំពេញ ស្ថិតនៅលើដាយទីក្រុងក្នុងវាលភក់ងាយរងគ្រោះដោយទឹកជំនន់ ហើយពួកគេងាយទទួលរងគ្រោះដោយទឹកជំនន់ធ្ងន់ធ្ងរនិងការជាំទឹកក្នុងរយៈពេលជាច្រើនខែក្នុងមួយឆ្នាំៗ ដែលអាចបណ្តាលឱ្យមានផលប៉ះពាល់អវិជ្ជមានចំពោះសុខភាពជាច្រើន (Flower et al., ២០១៨)។ ការចូលរួមវិភាគទានរបស់បណ្ឌិត ធួន ទ្រី ក្នុងសមូហកម្មនេះ ពិចារណាលើទំនោរនេះ ដោយពិនិត្យមើលទំនាក់ទំនងរវាងទិដ្ឋភាពនៃនគរូបនីយកម្មនិងការផ្លាស់ប្តូរចំពោះច្បាប់ផ្សេងៗនៃការកំណត់តំបន់ប្រើប្រាស់ដីនិងការធ្វើផែនការនៅក្នុងប្រទេសកម្ពុជា។ បណ្ឌិត ធួន ទ្រី បានចង្អុលបង្ហាញថានៅក្នុងការធ្វើផែនការកន្លងមក បានគិតគូរពីទេសភាពធម្មជាតិដែលទីក្រុងស្ថិតនៅ។ ប៉ុន្តែ ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ រាជរដ្ឋាភិបាលកម្ពុជាបានប្រតិបត្តិនយោបាយថ្មីលើគម្រោង ដើម្បីបង្កើតតំបន់ដែនសមត្ថកិច្ចប្រកបដោយប្រសិទ្ធភាពដោយពិចារណាឡើងវិញនូវរបៀបដែលបរិស្ថានធម្មជាតិនិងការសាងសង់បរិស្ថានឡើងវិញដោយមនុស្ស មានទំនាក់ទំនងរវាងគ្នានិងមានទំនាក់ទំនងជាមួយអ្នករស់នៅទីក្រុង។ បណ្ឌិត ធួន ទ្រី បានចង្អុលបង្ហាញពីផលវិបាកដ៏មហន្តរាយសម្រាប់សហគមន៍ក្រីក្រក្នុងទីក្រុងនិងផ្តល់នូវសំណើជាច្រើនសម្រាប់មធ្យោបាយ ដើម្បីសម្រេចបាននូវទម្រង់នៃការអភិវឌ្ឍទីក្រុងប្រកបដោយចីរភាព បរិយាបន្ន និងប្រជាធិបតេយ្យបន្ថែមទៀត។

*ក្នុងផ្នែកត្រូវពិភាក្សា* Dolorès Bertrais ផ្តល់ការវិភាគយ៉ាងលម្អិត អំពីថាតើការផ្លាស់ប្តូរបរិស្ថានបានជះឥទ្ធិពលយ៉ាងដូចម្តេចទៅដល់ទាំងទេសភាពធម្មជាតិនិងសហគមន៍នៅទីក្រុង ក្នុងតំបន់បឹងជើងឯកដែលបានផ្លាស់ប្តូរពីជនបទ ទៅជាតំបន់ជាយទីក្រុង(peri-urban)ហើយបច្ចុប្បន្នកំពុងអភិវឌ្ឍបន្ថែមទៀត។ Bertrais បង្ហាញថាការស្ថាបនាផ្លូវថ្នល់និងលំនៅឋានថ្មី ការចាក់បំពេញបឹង និងការបូមខ្សាច់ចេញពីទន្លេមេគង្គនិងទន្លេបាសាក់ សុទ្ធតែរួមចំណែកដល់ការបាត់បង់ការអនុវត្តកសិកម្មដែលផ្អែកលើអាងស្តុកទឹកនិងសហគមន៍ដែលពឹងផ្អែកយ៉ាងខ្លាំងលើការអនុវត្តកសិកម្មទាំងនេះ។ Bertrais និងបណ្ឌិត ធួន ទ្រី រួមគ្នាបង្ហាញថា ការជជែកពិភាក្សានិងគោលនយោបាយជុំវិញការធ្វើផែនការនិងការធ្វើឱ្យមានការផ្លាស់ប្តូរទេសភាពធម្មជាតិ តាមរយៈការពង្រីកទីក្រុងបានបង្កើតភាពងាយរងគ្រោះក្នុងរយៈពេលខ្លី សម្រាប់សហគមន៍ក្រីក្រនៅតាមទីក្រុងនិងតំបន់ជុំវិញ ទីក្រុងឬតំបន់ជាយប្រជុំជនខាងក្រៅ។ ប៉ុន្តែ ពួកគេទាំងពីរក៏បានប្រមើលមើលនិងបង្ហាញថាការធ្វើផែនការដែលអាចប្រមើលមើលឃើញតែក្នុងរយៈពេលខ្លីនេះ អាចបង្កើនភាពងាយរងគ្រោះនៃផ្នែកធំទូលាយនៃប្រជាជន ទីក្រុងទៅនឹងទឹកជំនន់ និងការបរាជ័យហេដ្ឋារចនាសម្ព័នដទៃទៀត ដែលបណ្តាលមកពីតថភាពនៃការប្រែប្រួលអាកាសធាតុ។

ស្របពេលការស្រាវជ្រាវជាច្រើនស្តីពីអសន្តិសុខនៅទីក្រុងក្នុងទីក្រុងភ្នំពេញ មានទំនោរផ្តោតសំខាន់ទៅលើអ្នកក្រីក្រនៅទីក្រុងនិងការតាំងលំនៅក្រៅផ្លូវការ ការចូលរួមចំណែករបស់ Gabriel Fauveaud ក្នុងសមូហកម្ម នេះ

គ្រើនរំឮកយើងថា ភាពងាយរងគ្រោះ ជាពហុទំហំនិងសមាយាត។ សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា បានភ្ជាប់យ៉ាងពេញលេញទៅនឹងលំហូរមូលធនសកល។ ភាគច្រើនការអភិវឌ្ឍថ្មីៗនៃទីក្រុងត្រូវបានផ្តល់ហិរញ្ញប្បទាននិងស្ថិតក្រោមការរំពឹងទុកយ៉ាងខ្លាំង។ ផលប៉ះពាល់និន្នាការនេះជះឥទ្ធិពលលើថ្លៃផ្ទះ រួមជាមួយការកើនឡើងបំណុលរបស់អ្នករស់នៅទីក្រុងត្រូវសង ដែលធ្វើឱ្យម្ចាស់ផ្ទះមានវណ្ណៈកណ្តាលងាយរងគ្រោះចំពោះការធ្លាក់ចុះសេដ្ឋកិច្ចដែលជាទិដ្ឋភាពជៀសមិនរួចនៃមូលធននិយម។ អត្ថបទស្រាវជ្រាវរបស់ Fauveaud ចង្អុលបង្ហាញថា ការវិភាគនៃភាពងាយរងគ្រោះក្នុងទីក្រុងណាមួយត្រូវតែមានច្រើនស្រទាប់ ដូច Fauveaud បានស្នើរថា ការប៉ះទង្គិចណាមួយដល់វិស័យលំនៅឋាននឹងប៉ះពាល់មិនត្រឹមតែម្ចាស់ផ្ទះប៉ុណ្ណោះទេ។ ប៉ុន្តែ ក៏មានវិស័យការងារជាច្រើនទៀតដែលពឹងផ្អែកលើការធ្វើនគរូបនីយកម្មយ៉ាងឆាប់រហ័ស ចាប់តាំងពីកម្មករសំណង់ អ្នកផលិតឡូតជ្ជ  រហូតដល់ថ្នាក់ជំនាញគណនេយ្យករ មេធាវី អ្នកជំនាញខាងធនាគារ និងអ្នកដទៃទៀត ដែលជាផ្នែកមួយនៃការប្រមូលផ្តុំដែល Saskia Sassen (២០០៦) សំដៅទៅលើ «ក្រុមហ៊ុនសេវាកម្មជំនាញ»។ ចុងបញ្ចប់សមូហកម្មរបស់យើងជាមួយនឹងវិភាគទាននេះ ជំរុញឱ្យមានសារៈសំខាន់នៃវិធីសាស្រ្តមួយដែលត្រូវបានផ្តោតលើចំណុចប្រទាក់ក្រឡាគ្នា ដែលកម្លាំងពិភពលោកជួបប្រទះនៅក្នុងជីវិតប្រចាំថ្ងៃរបស់អ្នករស់នៅទីក្រុង ដូចជា ភាពសមហេតុផលនៃការរីកចម្រើននិងការអភិវឌ្ឍន៍ និងការអនុវត្តមូលដ្ឋាន។

# កំណើនសេដ្ឋកិច្ចនិងការវិវត្តដែលផ្តោតលើភាពងាយរងគ្រោះនៅកម្ពុជា

**ង៉ោ ណត្ថារុន**
មជ្ឈមណ្ឌលខេមរសិក្សា

**សេចក្តីផ្តើម**

អត្ថបទស្រាវជ្រាវនេះ ពិចារណាអំពីរបៀបដែលទស្សនាទាននៃភាពងាយរងគ្រោះបានវិវត្តនៅក្នុងបរិការណ៍អភិវឌ្ឍន៍នៅកម្ពុជានិងចង្អុលបង្ហាញរបៀបដែលក្របខណ្ឌភាពងាយរងគ្រោះអន្តរវិស័យ អាចធ្វើឱ្យការវិភាគរបស់យើងកាន់តែស៊ីជម្រៅឡើង អំពីភាពធន់និងភាពងាយទទួលរងគ្រោះថ្នាក់នៅក្នុងប្រព័ន្ធទីក្រុងដែលមានភាពស្មុគស្មាញនិងពហុស្រទាប់។

## ការយល់ដឹងពីទស្សនាទាននៃភាពងាយរងគ្រោះ : ការអភិវឌ្ឍសេដ្ឋកិច្ចនិងការផ្លាស់ប្តូរសេដ្ឋកិច្ច

៩០ភាគរយនៃប្រជាជនក្រីក្ររបស់ប្រទេសកម្ពុជា រស់នៅក្នុងតំបន់ជនបទរបស់ប្រទេស(ធនាគារពិភពលោក ២០២០)។ ជាលទ្ធផល ទីភ្នាក់ងារអភិវឌ្ឍន៍ភាគច្រើនដឹកនាំជំនួយអន្តរជាតិនិងគាំទ្រដល់តំបន់ទាំងនេះ។

ក្នុងឆ្នាំ២០០០ បញ្ហាបន្ទាន់ជាច្រើន រួមមាន ការចូលទីផ្សារមានកំណត់ សមត្ថភាពកសិកម្មដែលកំពុងអភិវឌ្ឍនិងបញ្ហាប្រឈមចំពោះភាពជាម្ចាស់ដីធ្លី បានទាមទារការវិនិយោគសំខាន់ៗពីមូលនិធិសាធារណៈក្នុងស្រុកនិងប្រភពជំនួយអភិវឌ្ឍន៍អន្តរជាតិ។ ហិរញ្ញប្បទាននេះបានគាំទ្រដល់ការអភិវឌ្ឍប្រព័ន្ធថែទាំសុខភាព ការអប់រំ ប្រព័ន្ធទឹកនិងអនាម័យ និងហេដ្ឋារចនាសម្ព័ន្ធកស្តុភារនៅតាមទីជនបទក្នុងប្រទេសកម្ពុជា។ ក្នុងចំណោមកម្មវិធីអាទិភាពផ្សេងៗទាំងនេះ គឺជាអ្វីដែលវិស័យអភិវឌ្ឍន៍ត្រូវបានចាត់ទុកថាមានសារៈសំខាន់បំផុតក្នុងការដោះស្រាយតម្រូវការអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គមរបស់ប្រទេស។

វាក្យសព្ទ«ភាពងាយរងគ្រោះ» ដំបូងត្រូវបានអនុវត្ត ដើម្បីគាំទ្រដល់ការងារអភិវឌ្ឍន៍លើបញ្ហាសំខាន់ៗ (ដូចជា ការចិញ្ចឹមជីវិតនៅជនបទ សុខភាព ការការពារបរិស្ថាន ការប្រែប្រួលអាកាសធាតុ និងប្រព័ន្ធអភិបាលកិច្ច។ល។)។ នៅឆ្នាំ២០០៦ ធនាគារពិភពលោកបានចាប់ផ្តើមអនុវត្តទស្សនាទាននេះចំពោះសេដ្ឋកិច្ចកម្ពុជាដែលជាផ្នែកមួយនៃគម្រោងវាយតម្លៃភាពក្រីក្រថ្នាក់ជាតិ។ ធនាគារពិភពលោកបានលើកសរសើរចំពោះកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័សរបស់ប្រទេសកម្ពុជា ក្នុងរយៈពេលពីរទសវត្សចុងក្រោយនេះ។ និន្នាការនៃកំណើននេះបានធ្វើឱ្យប្រទេសកម្ពុជាស្ថិតនៅលើគន្លងឆ្ពោះទៅរកការកាត់បន្ថយពាក់កណ្តាលនៅត្រឹមឆ្នាំ២០១៥ តាមរយៈការបង្កើតការងារនិងប្រាក់ចំណូល ដោយសារការវិនិយោគផ្ទាល់ពីបរទេសនិងមូលធនហូរចូលក្នុងប្រទេស និង

កិច្ចព្រមព្រៀងអនុគ្រោះពាណិជ្ជកម្មដែលកំពុងបង្កើនបរិមាណនិងចំនួនកិច្ចការជំនួញឆ្លងកាត់ព្រំដែន ជាពិសេសការនាំចេញទៅសហរដ្ឋអាមេរិកនិងសហភាពអឺរ៉ុប ក្នុងវិស័យដែលពឹងផ្អែកលើកម្លាំងពលកម្ម ដូចជាឧស្សាហកម្មកាត់ដេរ។ កំណើននេះបានធ្វើឱ្យអត្រាភាពក្រីក្រថ្នាក់ជាតិរបស់កម្ពុជាធ្លាក់ចុះក្រោម២០% ហើយនៅចុងឆ្នាំ២០២១ អត្រាភាពក្រីក្រនៅកន្លែងខ្លះអាចនៅចន្លោះពី១១% ទៅ ១៩% អាស្រ័យលើប្រភពនិងវិធីសាស្ត្រវាស់វែង។ ទោះយ៉ាងណាក៏ដោយ វិធានការនៃភាពក្រីក្រអាចផ្តល់នូវរូបភាពក្នុងពេលវេលាខ្លីប៉ុណ្ណោះ។ វិធានការទាំងនេះ ពេលខ្លះក៏មិនអាចតាមដានការប្រែប្រួលយ៉ាងឆាប់រហ័សនៃស្ថានភាពសេដ្ឋកិច្ច ដែលជួបប្រទះភ្លាមៗដោយប្រជាជនកម្ពុជានៅតាមជនបទ។ ម្យ៉ាងទៀត ពួកគេភាគច្រើនមានការឆ្លាស់គ្នារវាងភាពក្រីក្រកម្រិតមធ្យមនិងភាពក្រីក្រខ្លាំង ដោយមិនត្រូវបានផ្តល់ព័ត៌មានលម្អិត។

ទស្សនាទាននៃភាពងាយរងគ្រោះត្រូវបានគេប្រើប្រាស់យ៉ាងទូលំទូលាយនៅក្នុងឆ្នាំ២០១៣ ពីព្រោះរាជរដ្ឋាភិបាលកម្ពុជាបានអនុម័តជាផ្លូវការនូវវិធីសាស្ត្រថ្មីក្នុងការវាស់វែងភាពក្រីក្រ(ក្រសួងផែនការឆ្នាំ, ២០១៣)។ ទោះបីជាមានភាពខុសគ្នានៃវិធីសាស្ត្រនិងនិយមន័យក៏ដោយ ក៏និន្នាការជារួមបានចង្អុលបង្ហាញថាប្រទេសកម្ពុជាបានសម្រេចនូវការកាត់បន្ថយភាពក្រីក្រគួរឱ្យកត់សម្គាល់ ដូចដែលបានវាស់វែងដោយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ។

ដោយមើលឃើញពីការកាត់បន្ថយភាពក្រីក្រនៅទូទាំងប្រទេសប្រកបដោយជោគជ័យ ទស្សនាទាននៃភាពងាយរងគ្រោះក៏បានក្លាយជាចំណុចសំខាន់មួយ។ វាបានបង្ហាញសញ្ញាគួរឱ្យកត់សម្គាល់ថាប្រជាជនក្រីក្ររបស់ប្រទេសកម្ពុជាជាច្រើនបានរួចផុតពីភាពក្រីក្រ។ ប៉ុន្តែ ពួកគេមួយចំនួនធំស្ថិតនៅលើខ្សែបន្ទាត់នៃភាពក្រីក្របន្តិចប៉ុណ្ណោះ។ ប្រសិនបើពួកគេមាន«ការប៉ះទង្គិច(shock)» តូចណាមួយ ដូចជា ជំងឺឬសម្ពាធផ្នែកហិរញ្ញវត្ថុភ្លាមៗ អាចធ្វើឱ្យប្រជាជនកម្ពុជាជាច្រើនត្រឡប់មករកភាពក្រីក្រខ្លាំងយ៉ាងខ្លាំង។

ក្នុងឆ្នាំ២០០៤ ការបរិច្ឆាករបស់ធនាគារពិភពលោកលើការប្រើប្រាស់សម្រាប់មនុស្សម្នាក់ទាក់ទងទៅនឹងការវាស់វែងបន្ទាត់ភាពក្រីក្រថ្នាក់ជាតិរបស់ប្រទេសកម្ពុជា(ធនាគារពិភពលោក, ២០០៦)និងសន្ទស្សន៍ពហុវិស័យភាពក្រីក្រអង្គការ UNDP ដែលបានរកឃើញប៉ុន្មានឆ្នាំក្រោយ(OPHI, ២០១៣) បានរៀបរាប់លម្អិតអំពីបញ្ហាប្រឈមមួយចំនួនដែលប្រជាជនក្រីក្រនៅជនបទនិងទីក្រុងរបស់ប្រទេស និងភាពងាយរងគ្រោះរបស់មនុស្សមួយក្រុមធំ(ប៉ាន់ស្មាន មានអត្រាខ្ពស់ជាង២ ទៅ ៣ដង ខ្ពស់ជាង ប្រសិនបើប្រៀបធៀបទៅនឹងវិធានការវាស់វែងភាពក្រីក្រថ្នាក់ជាតិចុងក្រោយ)។ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ក៏បានបង្កើតនូវសូចនាករសង្គមពាក់ព័ន្ធមួយចំនួនទៀត ដូចជា ពលកម្មកុមារ អត្រាចូលរៀន អត្រាបញ្ចប់ការសិក្សា និងសមាមាត្រសមភាពយេនឌ័រ។ ខណៈពេលដែលទិន្នន័យបង្ហាញពីភាពខុសគ្នាខ្លាំងក្នុងវិធានការទាំងនេះ រវាងតំបន់ជនបទនិងតំបន់ទីក្រុងនៃប្រទេសកម្ពុជា។ ប៉ុន្តែ គម្លាតទាំងនេះបានថយចុះជាលំដាប់លើសូចនាករមួយចំនួន ដើម្បីបង្ហាញពីការបិទបញ្ចប់គម្លាតជវភាពនេះក្នុងឆ្នាំ២០១០ អត្រាប្រេវ៉ាឡង់កម្លាំងពលកម្មកុមារបានថយចុះដល់១៦,១% នៅតំបន់ជនបទទល់នឹង១២,៥% នៅតំបន់ទីក្រុង(CMDG, ២០១១)។ តាមរយៈការសង្កេតមើលសូចនាករសុខភាពនិងការអប់រំ(ដោយការពិនិត្យមើលទាំងលទ្ធភាពទទួលបាននិងគុណភាព) អត្រាចាក់វ៉ាក់សាំងបានឈានដល់៨៦% នៅតំបន់ទីក្រុងនិង៧៧% នៅតំបន់ជនបទ។ ទោះយ៉ាងណាក៏ដោយ សូចនាករមួយចំនួនបានបង្ហាញពីភាពខុសគ្នាធំធេង ដូចជា អត្រាមិនបញ្ចប់បឋមសិក្សានៅតាមតំបន់ជនបទ(ដែលមានចំនួនទ្វេដងធៀបទៅនឹងអត្រានៅទី

ក្រុង) ឬការទទួលបានទឹកស្អាតនិងបង្គន់អនាម័យ។ តួលេខផ្សេងៗគ្នាទាំងនេះ គឺ៤២,៧% និង៣៣,៤% នៅតំបន់ជនបទ និង៨១,១% និង៨៧,៨% នៅតំបន់ទីក្រុង(តួលេខទាំងអស់ត្រូវបានគណនាផ្អែកលើទិន្នន័យការស្ទង់មតិសេដ្ឋកិច្ចសង្គមកម្ពុជា-CSES, ២០១០)។

នៅចុងឆ្នាំ២០១៥ វង្វង់នៃការវិភាគបានផ្លាស់ប្តូរបន្តិចម្តងៗពីការបែងចែកជនបទ/ទីក្រុងជាពីរ ដើម្បីយកវិធីសាស្ត្រគ្រប់គ្រងដែនដីឱ្យកាន់តែទូលំទូលាយ ដោយប្រៀបធៀបភាពខុសគ្នានៅតាមព្រំដែនក្នុងតំបន់ ផ្សេងៗ។ ភាពអាស្រ័យគ្នាទៅវិញទៅមករវាងតំបន់ជនបទនិងទីក្រុង ក៏កាន់តែខ្លាំងជាងមុន។ កម្រិតប្រាក់ចំណូលនៅតែជាកត្តាជំរុញដ៏សំខាន់សម្រាប់ការធ្វើចំណាកស្រុក ទៅកាន់ទីក្រុង ដោយសារប្រាក់ចំណូលគ្រួសារនៅជនបទជាមធ្យម គឺ៤០% តិចជាងប្រាក់ចំណូលគ្រួសារនៅតំបន់ទីក្រុង។ អនុបាតនៃប្រជាជននៅទីក្រុងនិងប្រជាជននៅជនបទរបស់ប្រទេសកម្ពុជា ក៏បានកើនឡើងជាលំដាប់ក្នុងរយៈពេល២០ឆ្នាំចុងក្រោយនេះ។ ការកើនឡើងជាប្រចាំនៃកំណើនប្រជាជននៅទីក្រុងបានចាប់ផ្តើមតាំងពីឆ្នាំ២០១០។ ទិន្នន័យរបស់ធនាគារពិភពលោកបង្ហាញថាប្រជាជននៅទីក្រុងមានចំនួន២៣,៨% នៃប្រជាជនសរុបរបស់ប្រទេសកម្ពុជាក្នុងឆ្នាំ២០១៩ ដែលកើនឡើងពី ២៣,៤% នៅក្នុងឆ្នាំ២០១៨។ និន្នាការនេះត្រូវបានពន្យល់ដោយមូលដ្ឋាន ស្ថិរភាពអ្នករស់នៅទីក្រុងដែលជំរុញជវភាពកំណើនប្រជាសាស្ត្រ ដែលត្រូវបានវាស់វែងដោយចំនួនប្រជាជន ជាយុវជន ការកើនឡើងចំនួនជនចំណាកស្រុកពីជនបទ មកតំបន់ទីក្រុងនិងការពង្រីកដែនដីទីក្រុង។ ចំនួនប្រជាជននៅទីក្រុងបណ្តោះអាសន្នភាគច្រើន ពិសេសពលករចំណាកស្រុក អាចត្រូវបានបន្ថែមជាកម្រិតលំហូរមួយដែលបង្កើនចំនួនប្រជាជនទីក្រុងទាំងនេះ។ និយមន័យមូលដ្ឋាននៃ«ប្រជាជននៅទីក្រុង» របស់ប្រទេសកម្ពុជា ដែលត្រូវបានបញ្ជាក់យ៉ាងច្បាស់ដោយវិទ្យាស្ថានស្ថិតិជាតិ ត្រូវបានគណនាដោយប្រើការប៉ាន់ស្មានចំនួនប្រជាជនរបស់ធនាគារពិភពលោកនិងអនុបាតទីក្រុងពីទស្សនវិស័យនគរូបនីយកម្មពិភពលោករបស់ អង្គការសហប្រជាជាតិ។ ទោះយ៉ាងណាក៏ដោយ គួរកត់សំគាល់ថានិយមន័យខុសគ្នា ដូចជា និយមន័យមុខងារតំបន់ទីក្រុងនៃអង្គការសម្រាប់ការអភិវឌ្ឍនិងសហប្រតិបត្តិការសេដ្ឋកិច្ច(OECD)នឹងអាចនាំទៅរកការកើនឡើងគួរឱ្យកត់សម្គាល់នូវចំនួនប្រជាជននៅក្នុងតំបន់ទីក្រុងរបស់ប្រទេសកម្ពុជា។

## ការវិវត្តនៃការផ្តោតលើភាពក្រីកនៅទីក្រុង

ជាការពិតណាស់ បញ្ហាអភិវឌ្ឍន៍ទីក្រុងមិនមានអ្វីថ្មីទេ។ ប៉ុន្តែ បញ្ហាទាំងនេះបានទទួលការយកចិត្តទុកដាក់កាន់តែកើនឡើងក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ។ ខណៈពេលដែលការផ្តោតការយកចិត្តទុកដាក់លើការអភិវឌ្ឍនៅក្នុងប្រទេសកម្ពុជាពីរទសវត្សចុងក្រោយនេះ បានក្លាយជាវិស័យមួយនៅក្នុងការកំណែទម្រង់ជាតិ សំខាន់ៗ រួមមាន កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ វិមជ្ឈការនិងវិសហមជ្ឈការ ព្រមទាំងពាណិជ្ជកម្ម វិស័យឯកជន និងកំណែទម្រង់ដីធ្លី។ បញ្ហាទីក្រុងថ្មីៗនេះកាន់តែមានសារៈសំខាន់ខ្លាំងឡើងនៅក្នុងឯកសារកម្រិតខ្ពស់ ដូចជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិថ្មីរបស់កម្ពុជា (NSDP, ២០១៩) និងក្របខណ្ឌជំនួយអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិនៅកម្ពុជាជាលើកដំបូង(UNDAF, ២០១៩)។

កម្មវិធីអភិវឌ្ឍន៍ទីក្រុងកន្លងមកនិងបច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជា គាំទ្រដល់ការកសាងសមត្ថភាពកម្រិតខ្ពស់(ការរៀបចំផែនការយុទ្ធសាស្ត្រនិងការអភិវឌ្ឍគោលនយោបាយ)និង/ឬផ្តោតការយកចិត្តទុកដោយផ្ទាល់ទៅលើការលើកកម្ពស់ជីវភាពរស់នៅរបស់អ្នករស់នៅតំបន់នៃការតាំងលំនៅក្នុងទីក្រុងក្រៅផ្លូវការ ហេដ្ឋារចនាសម្ព័ន្ធនិងការទទួលបានសេវាកម្មផ្សេងៗរបស់រដ្ឋាភិបាល(រួមមាន ការទទួលបានទឹកនិងអនាម័យ លំនៅឋានប្រសើរជាងមុន ការថែទាំសុខភាពឬហេដ្ឋារចនាសម្ព័ន្ធជាក់លាក់ ដូចជា ប្រព័ន្ធលូទឹកកខ្វក់ ការប្រមូលសំរាម និងការធ្វើប្រព្រឹត្តកម្មសំណល់ ជាដើម)។

ការវាយតម្លៃគោលដៅមួយចំនួន ត្រូវបានធ្វើឡើងជាមួយសហគមន៍ក្រីក្រនៅតាមទីក្រុងនិងរបាយការណ៍លម្អិតមួយ ស្តីពីចំនួនប្រជាជននេះត្រូវបានធ្វើឡើងដោយអង្គការ People In Need និងមូលនិធិបន្ទាន់ អង្គការសហប្រជាជាតិដើម្បីកុមារ ក្នុងឆ្នាំ២០១៤(UNICEF, ២០១៥) បានបង្ហាញពីប្រកពសក្តានុពលជាច្រើនរបស់ភាពងាយរងគ្រោះ បន្ថែមលើដំណោះស្រាយដែលអាចកើតមាន។ ការសិក្សាអំពីលំនៅដ្ឋានតម្លៃសមរម្យថ្មីៗនេះក៏ត្រូវបានផ្តួចផ្តើមឡើងក្នុងឆ្នាំ២០២០ ដោយអង្គការពិភពកុមារនិងអភិវឌ្ឍន៍(PED) អង្គការ People in Need និងអង្គការសហប្រជាជាតិផ្នែកទីជម្រក(UN-Habitat) ដោយសហការជាមួយអគ្គនាយកដ្ឋានលំនៅដ្ឋាននៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ សព្វថ្ងៃមិនទាន់មានការវាយតម្លៃជាប្រព័ន្ធឬការស្រាវជ្រាវទូទៅដែលអាចផ្តល់នូវការយល់ដឹងទូលំទូលាយអំពីបរិការណ៍និងធម្មជាតិ នូវអ្វីដែលភាពងាយរងគ្រោះរបស់ទីក្រុងតំណាងនិងរបៀបដែលភាពងាយរងគ្រោះអាចត្រូវបានកំណត់បរិមាណនិងវាស់វែងបានយ៉ាងជាក់លាក់។

ការសិក្សាដំបូងជាច្រើនអំពីធម្មជាតិនេះ មាននិន្នាការផ្តោតលើរាជធានីភ្នំពេញ។ ប៉ុន្តែ ការស្រាវជ្រាវទីក្រុងនានានៃប្រទេសកម្ពុជានៅតែមានកម្រិត។ កិច្ចខិតខំប្រឹងប្រែងដើម្បីវាស់វែងភាពក្រីក្រនៅទីក្រុងនៅទីក្រុងភ្នំពេញដោយប្រើការស្ទង់មតិសេដ្ឋកិច្ចសង្គមកម្ពុជា ក្នុងឆ្នាំ២០០៤(CSES, ២០០៤) បានបង្ហាញថា ១,៣% នៃប្រជាជនសរុបដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្របានរស់នៅក្នុងរាជធានីភ្នំពេញ ហើយបានធ្លាក់ចុះដល់ ០,៣% ក្នុងឆ្នាំ២០០៧(ឬ ច្រើនជាង១០ ០០០នាក់)។ អ្នកស្រាវជ្រាវភាគច្រើនបានទទួលស្គាល់ដែនកំណត់របស់ CSES ពីព្រោះការស្ទង់មតិគ្រួសារនេះផ្តល់នូវភេវនីយភាពខ្ពស់ ដោយមិនបានរាប់បញ្ចូលអ្នកតាំងលំនៅក្រៅផ្លូវការមួយចំនួនធំ។ ជាលទ្ធផល ប្រជាជនកម្ពុជាដែលគ្មានផ្ទះសម្បែងដែលកំពុងរស់នៅក្នុងជម្រកសាធារណៈឬ ប្រជាជនមិនមានលទ្ធភាពប្រើប្រាស់សេវាកម្មទាំងនោះ។ បញ្ហានៃភាពជាម្ចាស់ដីបានក្លាយជាចំណុចកណ្តាលនៃការពិភាក្សាអំពីភាពងាយរងគ្រោះនិងអ្នកក្រីក្រនៅទីក្រុង។ ភាគច្រើននៃអ្នកក្រីក្រនៅទីក្រុងមិនមានលទ្ធភាពទទួលបានសិទ្ធិកាន់កាប់ដីធ្លីទេ។ ការណ៍នេះកាន់តែធ្ងន់ធ្ងរដោយសារការកើនឡើងនូវចំនួនពលករចំណាកស្រុកដែលអាចមានបំណងចង់តាំងលំនៅនៅក្នុងទីក្រុងមួយ ប៉ុន្តែ ខ្វះមធ្យោបាយក្នុងការកាន់កាប់ដីធ្លីឬសម្បត្តិអចលនៈទ្រព្យផ្សេងទៀត ដែលធ្វើឱ្យពួកគេស្ថិតក្នុងស្ថានភាពអចិន្ត្រៃយ៍នៃ«អន្តរកាលនៃការផ្លាស់ប្តូរ»។

ការយកចិត្តទុកដាក់បន្ថែមទៀតបច្ចុប្បន្ន ត្រូវបានផ្តល់ដល់យន្តការកំណត់គោលដៅនិងវិធីសាស្ត្រវាយតម្លៃ។ ក្រៅពីនេះ ការព្យាករណ៍ផ្សេងៗនៃកម្រិតផលប៉ះពាល់និងភាពងាយរងគ្រោះ គឺអាស្រ័យលើអ្វីដែលម៉ូដែលនិងធម៉ែត្រសាស្ត្រដែលត្រូវបានយកមកប្រើប្រាស់។ ជាឧទាហរណ៍ ប្រព័ន្ធអត្តសញ្ញាណកម្មគ្រួសារក្រីក្ររបស់ប្រទេសកម្ពុជាថ្មីៗនេះ បានចាប់ផ្តើមរៀបចំប្រព័ន្ធវាស់ស្ទង់ថ្មីមួយ ដើម្បីកំណត់ទិសដៅភាពក្រីក្រក្នុងវិធានការទីក្រុង(OECD, ២០១៨)។ អ្នកពាក់ព័ន្ធបានស្នើសុំឱ្យមានប្រទានកម្មការវាស់វែង ដោយប្រើប្រាស់វិធីសាស្ត្រកំណត់

អត្តសញ្ញាណគ្រួសារក្រីក្រដែលត្រូវបានកែសម្រួលឱ្យសមស្របពីតំបន់ជនបទ ទៅតំបន់ទីក្រុង។ ប៉ុន្តែ វិធីសាស្ត្រកំពុងតែត្រូវបានកែសម្រួល ដើម្បីឱ្យកាន់តែត្រឹមត្រូវទៅនឹងសូចនាករផ្សេងៗដែលមាននៅក្នុងវិធីសាស្ត្រយន្តការកំណត់គោលដៅ។

## ការស្វែងយល់ពីភាពងាយរងគ្រោះនៅចំណុចស្នូលនៃប្រព័ន្ធទីក្រុងដែលមានភាពស្មុគស្មាញនិងពហុស្រទាប់

ទំហំដែលអាចមើលឃើញនិងមានភាពច្បាស់បំផុតនៃភាពងាយរងគ្រោះនៅតាមទីក្រុងធំៗរបស់ប្រទេសកម្ពុជា គឺភាពងាយរងគ្រោះទាក់ទងនឹងហេដ្ឋារចនាសម្ព័ន្ធ ដែលដាក់សម្ពាធលើផែនការហិរញ្ញវត្ថុសាធារណៈនិងការរារាំងដោយផ្ទាល់ចំពោះប្រសិទ្ធភាពនៃការផ្តល់សេវានិងភាពងាយគ្រោះដែលទាក់ទងនឹងមនុស្ស។ ការរួមបញ្ចូលគ្នានៃកម្សោយហេដ្ឋារចនាសម្ព័ន្ធដែលទាក់ទងនឹងភាពផុយស្រួយនៃស្ថានភាពសេដ្ឋកិច្ចសង្គម បង្កើនកត្តាភាពងាយរងគ្រោះជាច្រើន។ ការគំរាមកំហែងផ្នែកអាកាសធាតុ ដូចជា ទឹកជំនន់ ក៏ដូចជាប្រជាជនដែលរស់នៅក្នុងការតាំងលំនៅក្រៅផ្លូវការ គឺជាតំបន់ដែលត្រូវបានសិក្សាច្រើនបំផុត។ ការវិភាគថ្មីៗបន្ថែមទៀតនៅក្នុងរាជធានីភ្នំពេញបានផ្តោតលើការយល់ដឹងអំពីទឹកជំនន់ដែលកាន់តែញឹកញាប់និងខ្លាំងជាងមុន បន្ថែមលើកង្វះខាតបរិក្ខារប្រព្រឹត្តកម្មសំណល់រាវនិងអសន្តិសុខ សិទ្ធិកាន់កាប់ដីធ្លីរបស់ទីក្រុង(GGGI, ២០១៨)។ ការស្ទង់មតិថ្មីៗនេះ (មិនផ្តោតលើសហគមន៍ក្រីក្របំផុត) ក៏បង្ហាញពីការវាយតម្លៃភាពងាយរងគ្រោះនៃគ្រួសារ(ផ្លូវការនិងមិនក្រីក្រ) នៅតំបន់ខាងក្នុងនិងខាងក្រៅនៃរាជធានីភ្នំពេញ(WFP, ២០១៩)។ ការចូលរួមវិភាគទានពីបណ្ឌិត ធួន ទ្រី និង Bertrais នៅក្នុងសមូហកម្មនេះ ពិភាក្សាយ៉ាងស៊ីជម្រៅ។

ការយល់ដឹងកាន់តែស៊ីជម្រៅអំពីជីវភាពនៅពីក្រោយការផ្លាស់ប្តូរទីក្រុង នឹងអនុញ្ញាតឱ្យកម្មវិធីផ្សេងៗរបស់រដ្ឋាភិបាលប្តូរការផ្តោតអារម្មណ៍របស់ពួកគេពីការកាត់បន្ថយជាបណ្តោះអាសន្ននូវផលប៉ះពាល់អវិជ្ជមានដែលអាចកើតមាននៃការអភិវឌ្ឍទីក្រុងលើសហគមន៍ងាយរងគ្រោះ ដើម្បីដោះស្រាយដោយផ្ទាល់នូវបុព្វហេតុនៃភាពងាយរងគ្រោះ។ ការវិភាគស៊ីជម្រៅជាលក្ខណៈប្រព័ន្ធ(ដោយប្រើវិធីគិតតាមប្រព័ន្ធ) អាចឱ្យមានការវាយតម្លៃដែលពិចារណាគ្រប់ជ្រុងជ្រោយអំពីភាពស្មុគស្មាញនៃប្រព័ន្ធទីក្រុងរបស់ប្រទេសកម្ពុជា ដែលមានលក្ខណៈខុសគ្នាពីទីក្រុងមួយទៅទីក្រុងមួយ ដោយសារភាពជាក់លាក់នៃកម្លាំងសេដ្ឋកិច្ច សមត្ថភាពអភិបាលកិច្ចមូលដ្ឋាន និងការអនុវត្តច្បាប់មូលដ្ឋានសម្រាប់ការវិនិយោគឯកជន។

របាយទីតាំងភូមិសាស្ត្រនៃមូលធនឆ្លងកាត់ច្រករបៀងសេដ្ឋកិច្ចនិងមជ្ឈមណ្ឌលរីកចម្រើន ដូចជាសៀមរាប ភ្នំពេញ និងក្រុងព្រះសីហនុ ជាដើម ត្រូវបានប្រមូលផ្តុំនៅក្នុងតំបន់ទីក្រុងនិងតំបន់ជាយទីក្រុង។ ក្នុងអត្ថន័យនៃ« បណ្តុំសេដ្ឋកិច្ច» (agglomeration economies) តំបន់ទាំងនេះគួរឱ្យកត់សម្គាល់សម្រាប់ការប្រមូលផ្តុំមីក្រូសហគ្រាស សហគ្រាសធុនតូចនិងមធ្យម (MSMEs) និងក្រុមហ៊ុនខ្នាតធំ និងកន្លែងឧស្សាហកម្ម ដូចជា រោងចក្រកាត់ដេរ រោងចក្រកែច្នៃ និងគម្រោងអចលនទ្រព្យធំៗ។ ការអភិវឌ្ឍទាំងនេះត្រូវបានបំពេញបន្ថែមដោយវត្តមាននៃតំបន់សេដ្ឋកិច្ចពិសេស កំពង់ផែ និងតំបន់ពាណិជ្ជកម្មដទៃទៀត។ ការណ៍នេះបង្កើតសកម្មភាពផ្សេងៗ ពឹងផ្អែកលើកម្លាំងពលកម្មនិងសកម្មភាពពឹងផ្អែកលើធនធានមនុស្សដែលបង្កើនផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្ស

ម្នាក់ៗ។ ទោះជាយ៉ាងណា គំរូនេះក្នុងពេលដំណាលគ្នាបង្កើតភាពខុសគ្នាទាំងស្រុងនៃភូមិសាស្ត្ររវាងតំបន់ទាំងនេះនិងតំបន់ជនបទ។ គំរូនេះធ្វើឱ្យមានកំណើននៃការថយចុះវិស័យកសិកម្ម(ជាមួយនឹងទិន្នផលទាបក្នុងមួយហិកតា ដែលបណ្តាលមកពីព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរ) លើកម្ពស់យន្តកម្មនៃកិច្ចការដែលពឹងផ្អែកលើកម្លាំងពលកម្មក្នុងលក្ខណៈមួយដែលបង្កើនភាពអត់ការងារធ្វើ និងជំរុញការធ្វើចំណាកស្រុករបស់យុវជន ដើម្បីរកការងារធ្វើនៅតំបន់ទីក្រុងនានា នៅក្នុងប្រទេសកម្ពុជានិងនៅក្នុងប្រទេសជិតខាង ដែលផ្តល់ខ្ពស់ប្រាក់ចំណូលប្រចាំថ្ងៃខ្ពស់ជាង។

ជាមួយនឹងការវិនិយោគផ្ទាល់ពីបរទេសដែលមាននិរន្តរភាពនិងកំពុងរីកចម្រើនយ៉ាងឆាប់រហ័សពីប្រទេសចិន ក្រុងព្រះសីហនុអាចឆ្លុះបញ្ចាំងយ៉ាងល្អបំផុតពីវិសមភាពដែនដីនិងភាពតានតឹងផ្សេងៗដែលទាក់ទងនឹងកំណើនទីក្រុងនិងការប្រមូលផ្តុំសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស។ ការណ៍នេះបានធ្វើឱ្យមានភាពកាន់តែធ្ងន់ធ្ងរឡើងនូវវិសមភាពភូមិសាស្ត្រនិងសង្គមដែលមានពីមុនមកស្រាប់នៅក្នុងខេត្ត(Po and Heng, ២០១៩)។ ទោះបីជាវាអាចផ្តល់នូវកាលានុវត្តភាពដល់ប្រជាជនក្រីក្រមួយចំនួនរបស់កម្ពុជា ក្នុងការរកប្រាក់ចំណូលទៀងទាត់ខ្ពស់ជាងមុន។ ប៉ុន្តែ សំណួរបន្ទាប់គឺថា តើបរិការណ៍ថ្មីនេះកំពុងបង្កើនកម្រិតនៃការប្រឈមមុខរបស់អ្នកក្រីក្រនៅប្រទេសកម្ពុជាចំពោះការប៉ះទង្គិច ដែលអាចមានសមត្ថភាពបង្អាក់ការចល័តផ្នែកសេដ្ឋកិច្ចទាំងកម្រិតបុគ្គលនិងគ្រួសារដោយរបៀបណា?

ការយល់ដឹងកាន់តែច្បាស់អំពីភាពងាយរងគ្រោះនៅទីក្រុងរបស់ប្រទេសកម្ពុជា ទាមទារឱ្យយើងទទួលយកថាកម្លាំងនិងប្រព័ន្ធសេដ្ឋកិច្ចដែលជំរុញការអភិវឌ្ឍទីក្រុង គឺមិនមែនល្អឥតខ្ចោះ។ នគរូបនីយកម្មដោយខ្លួនឯងផ្ទាល់មិនអាចត្រូវបានអនុវត្តជាវិធានការល្អឯកតែមួយ ដែលមានលទ្ធផលល្អដែលបង្ហាញសញ្ញាពីភាពប្រសើរឡើងជាវិជ្ជមានដែលជៀសមិនរួចនៅក្នុងជីវភាពរស់នៅរបស់ប្រជាជន។ វិស័យសេដ្ឋកិច្ចដែលជួលកម្មករដែលមានប្រាក់ចំណូលទាប ពិតជាសំខាន់ណាស់ ពីព្រោះពួកគេតំណាងឱ្យជម្រើសល្អបំផុតទាក់ទងនឹងការផ្តល់ការងារដែលមានជំនាញនិងយូរអង្វែងនិងការផ្តល់នូវប្រាក់ចំណូល។ ប៉ុន្តែ វិស័យទាំងនេះក៏អាចក្លាយជាប្រភពនៃភាពងាយរងគ្រោះដែរ ប្រសិនបើមានកង្វះខាតនូវបទប្បញ្ញត្តិឬស្ថិតក្រោមការអនុវត្តតាមច្បាប់មិនបានសមស្រប។ ករណីថ្មីៗនៅក្នុងវិស័យសំណង់ទីក្រុងដែលកំពុងរីកចម្រើនយ៉ាងលឿន បានបង្ហាញពីបញ្ហាមួយចំនួន ដូចជា ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ពលកម្មកុមារ និងលក្ខខណ្ឌការងារដែលមិនពេញចិត្តនិងបទប្បញ្ញត្តិដែលត្រូវការការកែលម្អបន្ថែមទៀត(សូមមើលការចូលរួមចំណែករបស់ Gabriel Fauveaud នៅក្នុងសហមូកម្មនេះ)។ វិស័យកាត់ដេរទើបតែចាប់ផ្តើមផ្តល់លក្ខខណ្ឌការងារសមរម្យដល់អ្នកទាំងនោះ វាផ្តល់ការងារដោយសារតែចលនាពិភពលោកឆ្ពោះទៅរកការទទួលខុសត្រូវខាងសង្គមរបស់សាជីវកម្ម នៅក្នុងម៉ាកយីហោវាយនភណ្ឌនិងសម្លៀកបំពាក់អន្តរជាតិ ក៏ដូចជា កម្មវិធីគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា(BFC)របស់អង្គការពលកម្មអន្តរជាតិ ដែលទទួលបានជោគជ័យនិងយូរអង្វែង(Wetterberg, ២០១១)។ វិស័យនេះបានឃ្លាតឆ្ងាយពីលក្ខខណ្ឌការងារគ្មានសុវត្ថិភាព ដែលលក្ខខណ្ឌការងារខ្លះនាំឱ្យមានបាតុភូតដួលសន្លប់ក្នុងចំណោមកម្មករ ក្នុងចំណោមផលវិបាកផ្សេងៗទៀត(Eisenbruch, ២០១៧)។ បច្ចុប្បន្នឧស្សាហកម្មកាត់ដេរនៅកម្ពុជាមានភាពផុយស្រួយជាងពេលមុន ពីព្រោះការធ្វើឱ្យលែងមានបន្តិចម្តងៗនៃកិច្ចព្រមព្រៀងអនុគ្រោះពាណិជ្ជកម្មជាមួយបណ្តាប្រទេសលោកខាងលិច ដោយសារតែភាពមិនចុះសម្រុងផ្នែកនយោបាយនិងការប្រមូលយកអតីតកម្មករកាត់ដេរដែលអត់ការងារធ្វើ

រាប់ពាន់នាក់ចូលក្នុងវិស័យផ្សេងៗឬវិស័យឧស្សាហកម្ម។ ការចំណាយលើការរស់នៅទីក្រុងកំពុងកើនឡើង ហើយកម្រិតនៃបំណុលកើនឡើងស្របគ្នានឹងការបាត់បង់ប្រាក់ចំណូល(Res, ២០២១)។ ការណ៍នេះអាចបង្កើតវដ្តដ៏អាក្រក់មួយដែលវិស័យសាធារណៈ ម្ចាស់ជំនួយ និងទីភ្នាក់ងារអភិវឌ្ឍន៍កំពុងធ្វើការរួមគ្នា ដើម្បីបន្ទូរបន្ថយស្ថានភាពជាមួយការងារថ្មីៗរបស់ពួកគេ ដើម្បីពង្រីកកម្មវិធីគាំពារសង្គមដល់កម្មករនៅក្នុងសេដ្ឋកិច្ចក្រៅផ្លូវការ។

ភាពស្មុគស្មាញនៃការពឹងពាក់គ្នាទៅវិញទៅមករវាងតំបន់ទីក្រុងនិងតំបន់ជនបទ ក៏ទាមទារឱ្យមានការស្រាវជ្រាវនិងការវិភាគបន្ថែមទៀត ដែលមើលលើទិដ្ឋភាពទាំងពីរក្នុងពេលតែមួយ។ ការសិក្សាថ្មីៗអំពីគំរូនៃការធ្វើចំណាកស្រុកពីជនបទ ទៅទីក្រុងនិងខ្សែចង្វាក់តម្លៃមូលដ្ឋានមានភាពល្អប្រសើរ ហើយត្រូវការធ្វើបន្តទៀត (សូមមើលការចូលរួមចំណែករបស់បណ្ឌិត ប៉ក់ គឹមជឿន នៅក្នុងសមូហកម្មនេះ)។ ប៉ុន្តែ មិនមានន័យថា«លទ្ធផល» ខ្ពស់នៃផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់ៗក្លាយជាសូចនាករស្នូលដែលត្រូវបានប្រើដើម្បីពន្យល់បង្ហាញអំពីភាពត្រឹមត្រូវឬត្រូវតាមប្រភេទជាក់លាក់ស្របច្បាប់នៃវឌ្ឍភាពសេដ្ឋកិច្ចតាមការចំណាយរបស់អ្នកដទៃឡើយ។

ការយល់ដឹងអំពីភាពងាយរងគ្រោះក្នុងទីក្រុង ក៏ទាមទារឱ្យយើងទទួលស្គាល់ផងដែរថា ការធ្វើទំនើបកម្មទីក្រុងនៅលក្ខខណ្ឌនៃបច្ចេកវិទ្យា កិត្យានុភាពសង្គម ជវភាពទីផ្សារការងារ សេវាសុខភាពនិងអប់រំមានគុណភាពខ្ពស់ ចល័តភាពផ្នែកសេដ្ឋកិច្ច លំនៅឋានប្រកបដោយផាសុកភាព និងសង្កាត់មានសុវត្ថិភាពមានភ្ជាប់មកជាមួយនូវតម្លៃដ៏ច្រើន។ ការអភិវឌ្ឍទីក្រុងអាចបង្កើនលទ្ធភាពទទួលបានសេវាកម្មដែលមានគុណភាពខ្ពស់សម្រាប់ក្រុមមនុស្សវណ្ណៈកណ្តាលនិងវណ្ណៈខ្ពស់ ខណៈពេលដែលការអភិវឌ្ឍនេះ កំពុងបន្តរុញច្រានប្រជាជន កម្ពុជាដែលក្រីក្រជាង ទៅតំបន់ជាយៗផងដែរ។ ទីក្រុងនានា ដូចជា រាជធានីភ្នំពេញ បង្ហាញពីនិន្នាការនៃកម្រិតមិនគ្រប់គ្រាន់នៃការវិនិយោគក្នុងសេវាសាធារណៈនិងការកើនឡើងនូវការធ្វើឯកជនភាវូបនីយកម្មរបស់សេវាកម្មមូលដ្ឋាន ដូចជា ការអប់រំ និងថែទាំសុខភាព។ សេវាសាធារណៈដែលមានស្រាប់ ដូចជា ប្រព័ន្ធរថយន្តក្រុងសាធា រណៈឬប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតក្នុងរាជធានីភ្នំពេញ គួរតែត្រូវបានអភិវឌ្ឍនិងវិនិយោគបន្ថែមទៀត។ ដូចគ្នាផងដែរ ការអភិវឌ្ឍនិងការវិនិយោគនេះ គួរតែត្រូវបានពង្រីកទៅដែនផ្សេងៗទៀត ដូចជា ការធានារ៉ាប់រងផ្ទះសម្បែងនិងសង្គម។

ប្រទេសកម្ពុជា កំពុងទទួលរងនូវការផ្លាស់ប្តូរសេដ្ឋកិច្ចដែលបានចាប់ផ្តើមនៅដើមទសវត្សឆ្នាំ២០០០។ ដូចដែលយើងបានឃើញកន្លងមក ប្រភេទនៃការផ្លាស់ប្តូរនេះបានលាតត្រដាងឱ្យដឹងកាន់តែលឿននៅក្នុងតំបន់ទីក្រុងដែលជួយបង្កើនល្បឿននៃការពង្រីកលម្ហទីក្រុងនិងប្រមូលផ្តុំប្រជាជននៅទីក្រុង ឱ្យកាន់តែណែនណាន់។ ប្រទេសកម្ពុជាកំពុងធ្វើដំណើរនៅលើវិថីស្រដៀងគ្នាទៅនឹងប្រទេសជិតខាង ដែលបានសម្រេចបាននូវសេដ្ឋកិច្ចជឿនលឿនជាងមុន។ ការពឹងផ្អែករបស់កំណើនសេដ្ឋកិច្ចបែបនេះ លើប្រេង ឧស្ម័នធម្មជាតិ និងធ្យូងថ្ម គឺខ្ពស់ណាស់ ហើយកាន់តែបង្ហាញឱ្យឃើញកាន់តែច្បាស់នូវការរីកចម្រើនយ៉ាងឆាប់រហ័ស។ ប្រភេទឥន្ធនៈហ្វូស៊ីលទាំងបី ត្រូវបានគេទទួលស្គាល់ថាជាប្រភពផ្ទាល់និងប្រយោលនៃការបំពុលខ្យល់និងការរិចរិលបរិស្ថាន ដែលផលប៉ះពាល់ទាំងនេះត្រូវបានគេយកមកបង្ហាញយ៉ាងច្បាស់នៅក្នុងបរិស្ថានទីក្រុង។

ពួកគេរួមគ្នាបង្កើតជាបុព្វហេតុផ្ទាល់នៃភាពងាយរងគ្រោះជាក់ស្តែងមួយចំនួននៅក្នុងទីក្រុង ដែលរួមមានបញ្ហាថ្មីៗនិងក្រោមការស្រាវជ្រាវ ដូចជា កោះកម្តៅតំបន់ទីក្រុង(urban heat islands) ដែលបានកើតនៅផ្នែកណាមួយនិងប្រមូលផ្តុំ(បេក្ខជនបណ្ឌិត Bunleng Se កំពុងធ្វើការស្រាវជ្រាវលើប្រធានបទនេះនៅក្នុងទីក្រុងមួយ

ចំនួន)។ ការកើនឡើងនៃផលិតផលក្នុងស្រុកសរុបនិងការបំភាយឧស្ម័នកាបូនឌីអុកស៊ីត មានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ។ តម្រូវការចាំបាច់សម្រាប់ការផ្លាស់ប្តូរអេកូឡូស៊ីនិងថាមពល មានគោលបំណងដើម្បីជំរុញសេដ្ឋកិច្ចកម្ពុជាដែលផ្អែកលើប្រភពថាមពលកាបូនទាប(decarbonizing) ស្របតាមកិច្ចព្រមព្រៀងទីក្រុងប៉ារីសនិងរបៀបវារៈការចូលរួមចំណែកដែលកំណត់ដោយថ្នាក់ជាតិ(NDC) គឺជារឿងស្មុគស្មាញមួយដែលត្រូវបំពេញ។ មិនទាន់មានគំរូសេដ្ឋកិច្ចណាមួយត្រូវបានអភិវឌ្ឍឡើងនៅឡើយ ដែលជាគំរូមួយអាចថ្លឹងថ្លែងរវាងការចំណាយដើមទុននិងផលិតភាព និងការដោះដូរភាពប្រកួតប្រជែងដែលការផ្លាស់ប្តូរបែបនេះនឹងត្រូវការ។

## សេចក្តីសន្និដ្ឋាន

វិបត្តិជំងឺរាតត្បាតសាកល កូវីដ-១៩ ធ្វើឱ្យលេចឡើងនូវបញ្ហាប្រឈមទាំងនោះ ដែលប្រជាជនកម្ពុជាកំពុងរស់នៅក្នុងការតាំងលំនៅក្រៅផ្លូវការនៅទីក្រុង។ វាបានផ្តោតការយកចិត្តទុកដាក់ជាសាធារណៈទៅលើប្រព័ន្ធទឹកនិងអនាម័យ និងដង់ស៊ីតេទីក្រុង។ ប៉ុន្តែ បញ្ហាទាំងនេះមិនមែនជាបញ្ហាថ្មីនោះទេ។ ការតាំងលំនៅណែនណាន់ជាច្រើនខ្វះការទទួលបានទឹកស្អាតនិងមានប្រព័ន្ធថែទាំសុខភាពបឋមនិងឯកទេសទាបខ្លាំង។ រោគរាតត្បាតកំពុងបន្ថែមភាពងាយរងគ្រោះថ្មីក្នុងទីក្រុង នៅលើកំពូលនៃភាពងាយរងគ្រោះដែលមានពីមុនមកស្រាប់។ វាក៏បានផ្តល់នូវព័ត៌មានបន្ថែមថ្មីៗអំពីសារៈសំខាន់នៃសិទ្ធិរបស់កម្មករនៅក្នុងវិស័យការងារផ្លូវការនិងក្រៅផ្លូវការ ក៏ដូចជាតម្រូវការសម្រាប់ប្រទេសកម្ពុជាក្នុងការកសាងបណ្តាញសុវត្ថិភាពសង្គមឱ្យកាន់តែរឹងមាំ ជាពិសេសនៅតាមតំបន់ទីក្រុងទាំងនោះ(ដោយប្រយោល) ដែលត្រូវបានរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរបំផុតដោយជំងឺរាតត្បាតសាកល កូវីដ-១៩។

ប្រសិនបើការងារផលិតកម្មនិងប្រាក់ចំណូល សុទ្ធតែជាលទ្ធផលនិងជាកត្តាជំរុញកំណើនសេដ្ឋកិច្ចទីក្រុងដូច្នេះ ភាពងាយរងគ្រោះនៅតាមទីក្រុងអាចត្រូវបានគេយល់ច្បាស់ថាជាផលប៉ះពាល់អវិជ្ជមានមកពីក្រៅដោយផ្ទាល់និងដោយប្រយោល ដែលបង្កើតដោយគំរូកំណើនបច្ចុប្បន្នរបស់ប្រទេសកម្ពុជា។ ផលប៉ះពាល់មកពីក្រៅទាំងនេះ អាចត្រូវបានគ្រប់គ្រងដោយការអនុវត្តគោលនយោបាយសង្គមប្រកបដោយបរិយាបន្នយ៉ាងសមរម្យ ជាមួយនឹងសមត្ថភាព ដើម្បីសម្រេចនិងការពារផ្នែកអន់បំផុតនៃចំនួនប្រជាជនទីក្រុងនិងជនបទរបស់ប្រទេសកម្ពុជា។ ពួកគេក៏អាចត្រូវបានគ្រប់គ្រងកាន់តែមានប្រសិទ្ធភាព ប្រសិនបើតួអង្គសាធារណៈនិងពលរដ្ឋទទួលស្គាល់ថាការផ្លាស់ប្តូរគំរូសេដ្ឋកិច្ចអាចជាការចាំបាច់ ដើម្បីគិតត្រិះរិះពីដំណោះស្រាយប្រសើរជាងមុនចំពោះបញ្ហាគន្លឹះទាំងនេះ។ ប្រភពនវានុវត្តន៍នៃការវិនិយោគក្នុងវិស័យឯកជននិងគំរូហិរញ្ញវត្ថុ រួមបញ្ចូលគ្នាដែលគាំទ្រដោយការ វិនិយោគដែលមានឥទ្ធិពលនិងគំនិតផ្តួចផ្តើមហិរញ្ញវត្ថុប្រកបដោយនិរន្តរភាព ក៏មានតួនាទីសំខាន់ផងដែរ។

# ផ្នែកត្រូវពិភាក្សា : ការធ្វើចំណាកស្រុកជនបទ-ទីក្រុងទៅរាជធានីភ្នំពេញ[7]

**បណ្ឌិត ប៉ក់ គឹមជឿន**
អ្នកស្រាវជ្រាវឯករាជ្យ

ជាមួយនឹងចំនួនប្រជាជនវ័យក្មេងនិងកំណើនសេដ្ឋកិច្ចឆាប់រហ័ស ប្រទេសកម្ពុជាបានឆ្លងកាត់នូវលក ចំណាកស្រុកដ៏ធំនិងកំពុងកើនឡើងទាំងនៅក្នុងនិងក្រៅប្រទេស។ ដូច្នេះ វាមានសារៈសំខាន់ណាស់ដើម្បីឱ្យមាន ការយល់ដឹងកាន់តែប្រសើរនិងធ្វើបច្ចុប្បន្នភាពថ្មីៗអំពីនិន្នាការ កត្តាជំរុញនិងផលប៉ះពាល់ផ្សេងៗ ដែលការធ្វើ ចំណាកស្រុកបានបង្កើតឡើងមក តាមរយៈការផ្តោតលើភាពងាយរងគ្រោះ។

របាយការណ៍ឆ្នាំ២០១៩ របស់កម្មវិធីស្បៀងអាហារពិភពលោក(WFP, ២០១៩) ដែលបានដកស្រង់ ចេញពីការស្ទង់មតិជាមួយគ្រួសារចំនួន២ ៣៤១គ្រួសារ ក្នុងខែធ្នូ ឆ្នាំ២០១៦ បានរកឃើញថាប្រហែលជា៣៥% នៃគ្រួសារនៅតំបន់ជនបទ មានសមាជិកយ៉ាងតិចម្នាក់ធ្វើចំណាកស្រុក។ របាយការណ៍ក៏បង្ហាញដែរថា ការធ្វើ ចំណាកស្រុករយៈពេលខ្លីឬតាមរដូវកាល(ប្រាំមួយខែឬខ្លីជាងនេះ)មានប្រហែល៣៣% រយៈពេលវែង(៦ខែ ទៅ ៣ឆ្នាំ) មាន៤៣% និងការធ្វើចំណាកស្រុកជាអចិន្ត្រៃយ៍(យូរជាងបីឆ្នាំ)មាន២៤%។

ការធ្វើចំណាកស្រុកពីជនបទ ទៅជនបទមានចំនួន១៣% ទីជនបទ-ទីក្រុងមាន៥៧% និងការធ្វើចំណាក ស្រុកឆ្លងកាត់ព្រំដែន(ភាគច្រើននៅប្រទេសថៃ) មាន៣១%។ លំនាំនេះហាក់គ្មានការផ្លាស់ប្តូរអស់ពេលជាច្រើន ឆ្នាំ។ ប្រហែល៧៩ភាគរយនៃជនចំណាកស្រុកមានអាយុចន្លោះពី១៧ ទៅ ៣៥ឆ្នាំ និងច្រើនជាង ៥០ ភាគរយនៃ ជនចំណាកស្រុកគឺជាបុរស(ភាគច្រើនជាកូនប្រុសនៃមេគ្រួសារ)។

ភាពក្រីក្រ(ផ្នែកខ្លះដែលបណ្តាលមកពីគ្រោះមហន្តរាយធម្មជាតិ) ប្រហែលជាបានជំរុញឱ្យប្រជាជនធ្វើ ចំណាកស្រុកចេញក្រៅ ជាពិសេសនៅពេលគ្រួសារចំណាកស្រុកទាំងនោះមានដីតិចតួចពេកក្នុងការធ្វើកសិកម្ម និងការចំណាយខ្ពស់ ដែលប្រាក់ចំណូលរបស់ពួកគេមិនអាចទ្រទ្រង់បាន។ ការថ្លែងនេះត្រូវបានគាំទ្រដោយ ទិន្នន័យដែលបង្ហាញថាគ្រួសារចំណាកស្រុកមានដីជាមធ្យមប្រមាណ១,៧ហិកតា ប្រសិនបើប្រៀបធៀបទៅនឹង គ្រួសារដែលមិនធ្វើចំណាកស្រុកមានដីជាមធ្យម ៣,៥ហិកតា។ ភាពខុសគ្នានេះត្រូវបានបង្ហាញឱ្យឃើញកាន់តែ ច្បាស់បន្ថែមទៀតនូវតំបន់បឹងទន្លេសាបនិងតំបន់វាលទំនាប។ ទោះជាយ៉ាងណា ទិន្នន័យក៏បានស្នើរផងដែរថា យ៉ាងហោចណាស់ ភាពក្រីក្រតាមពេលវេលាអាចក្លាយជាកត្តាចូលរួមតិចតួច ប្រសិនបើប្រៀបធៀបនឹងបណ្តុំគ្នា

---

7 បានដកស្រង់ដោយមានការអនុញ្ញាតពីកម្មវិធីស្បៀងអាហារពិភពលោក(ឆ្នាំ២០១៩)។ ភាពងាយរងគ្រោះនិងការធ្វើចំណាកស្រុកនៅ កម្ពុជា។ ភ្នំពេញ កម្ពុជា។

នៃកត្តាទាក់ទាញនិងកត្តាសម្របសម្រួល ដូចជា ការរំពឹងទុកនៃកាលានុវត្តភាពក្នុងការបង្កើតប្រាក់ចំណូលខ្ពស់ជាងមុន ការតភ្ជាប់កាន់តែប្រសើរ ចល័តភាព និងសេចក្តីប្រាថ្នាជាទូទៅរបស់យុវជន ដើម្បីរស់នៅជាជីវិតមួយនៅខាងក្រៅភូមិរបស់ពួកគេ។

ទាំងផលប៉ះពាល់ ទាំងវិជ្ជមាននិងអវិជ្ជមាននៃការធ្វើចំណាកស្រុកត្រូវបានកំណត់។ ភាពវិជ្ជមានសម្រាប់ជនសំណាកស្រុក គឺការធ្វើចំណាកស្រុកបានជួយយុវជនវ័យក្មេងឱ្យទទួលបានការងារដែលមានប្រាក់ខែខ្ពស់នៅតាមទីក្រុងនិងក្រៅប្រទេស ដើម្បីផ្គត់ផ្គង់ខ្លួនឯងនិងភាគច្រើនដើម្បីផ្គត់ផ្គង់គ្រួសាររបស់ពួកគេនៅក្នុងខេត្តវិញ។ អ្នកធ្វើចំណាកស្រុក ទៅនៅទីដទៃជាច្រើន អាចទាក់ទងគ្រួសាររបស់ពួកគេជាទៀងទាត់នៅឯស្រុកកំណើត តាមរយៈទូរសព្ទចល័តនិងទម្រង់នៃការទំនាក់ទំនងផ្សេងៗទៀត។ ទោះយ៉ាងណាក៏ដោយ ការព្រួយបារម្ភសំខាន់ៗមួយចំនួន គឺគួរឱ្យកត់សម្គាល់។ ការព្រួយបារម្ភ ទី១ គឺផលប៉ះពាល់ដែលការធ្វើចំណាកស្រុកបានធ្វើឡើងលើការអភិវឌ្ឍជំនាញរបស់ជនចំណាកស្រុកនៅមានកម្រិត។ ទី២ គឺការធ្វើចំណាកស្រុកមានសក្តានុពលនាំឱ្យមានការបោះបង់ចោលសាលារៀននិងផលប៉ះពាល់អវិជ្ជមានលើកុមារដែលពួកគេបាននាំមកជាមួយ។ ទី៣ គឺស្ថានភាពសុវត្ថិភាពនិងភាពងាយរងគ្រោះរបស់ជនចំណាកស្រុក ទាំងអ្នកដែលកំពុងធ្វើដំណើរទៅទីក្រុងនិងទៅប្រទេសមួយផ្សេងទៀត។

ផលប៉ះពាល់ដែលបានកំណត់ខាងលើ អាចនឹងត្រូវបានរួមបញ្ចូលគ្នាសម្រាប់គ្រួសារដែលគិតគូមិនបានដិតដល់។ ប្រហែលជា៨០% នៃគ្រួសារចំណាកស្រុករាយការណ៍អំពីការទទួលការផ្ទេរប្រាក់ផ្ញើទៅ ពីអ្នកដែលបានធ្វើចំណាកស្រុក។ ការផ្ទេរប្រាក់នេះត្រូវបានគេរាយការណ៍ថាត្រូវបានប្រើប្រាស់ ដើម្បីផ្គត់ផ្គង់ផ្នែកខ្លះនៃតម្រូវការប្រចាំថ្ងៃរបស់គ្រួសារ។ ទោះយ៉ាងណាក៏ដោយ ជនធ្វើចំណាកស្រុកនិងជនមិនធ្វើចំណាកស្រុកទាក់ទងនឹងការប្រើប្រាស់ចំណីអាហារ ប្រភពចំណីអាហារ និងយុទ្ធសាស្ត្រដោះស្រាយ មិនមានភាពខុសគ្នាគួរឱ្យកត់សម្គាល់ឡើយ។ សរុបមក ភាពចម្រុះនៃរបបអាហារមិនគ្រប់គ្រាន់និងភាពអត់ឃ្លាន នៅតែជាបញ្ហាសម្រាប់ក្រុមទាំងពីរនេះនិងនៅទូទាំងតំបន់។ ទិន្នន័យនេះផ្តល់នូវការយល់ដឹងដែលមានកម្រិតចំពោះទំនាក់ទំនងរវាងការផ្ទេរប្រាក់( និង/ដោយការបន្តការធ្វើចំណាកស្រុក)និងបំណុលគ្រួសារ។ ការសិក្សាផ្សេងទៀត បានបង្ហាញថា មានទំនាក់ទំនងវិជ្ជមានយ៉ាងខ្លាំង(ឬសូម្បីតែសហេតុកម្មទៅវិញទៅមក) រវាងការធ្វើចំណាកស្រុកនិងប្រាក់កម្ចីពីស្ថាប័នមីក្រូហិរញ្ញវត្ថុ (MFIs)។ ប៉ុន្តែ លទ្ធផលនៃការសិក្សានេះមិនមានការបង្ហាញពីសុពលភាពទេ។

ស្ទើរតែ៤០ភាគរយនៃគ្រួសារចំណាកស្រុកបានរាយការណ៍ថាកុមារអាយុក្រោម ៥ឆ្នាំត្រូវបានស្ថិតក្រោមការថែទាំរបស់ជីដូនជីតាដែលអាចត្រូវបានគេមើលឃើញថាមានលក្ខណៈវិជ្ជមាន ពីព្រោះ ពួកគេនៅតែរស់នៅក្នុងស្ថានភាពគ្រួសារ ដែលប្រសើរជាងបញ្ជូនពួកគេទៅស្ថាប័នថែទាំលំនៅឋាន។ ប៉ុន្តែ ការថែទាំរបស់ជីដូនជីតា ក៏មានការព្រួយបារម្ភផងដែរ ពីព្រោះជីដូនជីតាទាំងនោះប្រហែលជាមិនអាចផ្តល់ការថែទាំល្អសម្រាប់កុមារ ជាពិសេសទាក់ទងនឹងអាហារូបត្ថម្ភ។ អ្វីដែលគេមិនបានដឹងនោះ គឺឥទ្ធិពលផ្លូវចិត្តនៃការធ្វើចំណាកស្រុកទៅលើកុមារតូចៗទាំងនោះដែលរស់នៅដោយគ្មានការមើលថែពីឪពុកម្តាយ។ ការស្រាវជ្រាវអំពីផលប៉ះពាល់នៃការធ្វើចំណាកស្រុកទៅលើប្រពន្ធនិងមនុស្សចាស់ដែលជាក្រុមងាយរងគ្រោះ នៅមានកម្រិតតិចតួចនៅឡើយ។

ដូចដែលបានរៀបរាប់រួចខាងលើ ដោយសារតែការធ្វើចំណាកស្រុកមួយភាគធំ គឺការធ្វើចំណាកស្រុកពីជនបទទៅទីក្រុង។ ជាលទ្ធផល និន្នាការនេះមាននៅក្នុងទសវត្សចុងក្រោយនេះ ដែលបានបង្កើតសម្ពាធបន្ថែម

ទៀតទៅលើនគរូបនីយកម្មនិងការអភិវឌ្ឍទីក្រុង។ កំណើនប្រជាជនដែលជំរុញដោយការធ្វើចំណាកស្រុក បានបង្កើតសម្ពាធបន្ថែមទៀតទៅលើការផ្តល់សេវាសាធារណៈដែលមិនសូវមានការអភិវឌ្ឍនៅក្នុងតំបន់ទីក្រុង ក៏ដូចជាតម្រូវការលំនៅឋាននិងការកសាងផែនការរៀបចំដែនដីទីក្រុង។ ស្រដៀងគ្នានេះដែរ ដោយសារការផ្ញើប្រាក់ពីពលករចំណាកស្រុកដើរតួនាទីសំខាន់ក្នុងគ្រួសារនៅជនបទ ការប៉ះទង្គិចសេដ្ឋកិច្ចណាមួយដែលកើតមានឡើងនៅតាមទីក្រុងនានា( ជាពិសេសនៅភ្នំពេញ ) អាចបង្កើតរលកនៃផលប៉ះពាល់ដែលមិនអាចប៉ាន់ស្មានទុកជាមុនបានទៅលើជីវភាពរបស់គ្រួសាររាប់លានគ្រួសារដែលរស់នៅតំបន់ជនបទ។

អត្រាខ្ពស់នៃការធ្វើចំណាកស្រុករបស់ប្រជាជនកម្ពុជាទាំងក្នុងប្រទេសនិងអន្តរជាតិ មានសារៈសំខាន់ណាស់និងទាមទាឱ្យមានការវិភាគពីភាពងាយរងគ្រោះនិងភាពធន់នៅទីក្រុងនៅក្នុងប្រទេសកម្ពុជា ដែលលាតសន្ធឹងហួសពីព្រំដែនទីក្រុងនិងរួមបញ្ចូលការពិចារណានៃការតភ្ជាប់ទំនាក់ទំនងរវាងជនបទនិងទីក្រុង ព្រមទាំងគោលនយោបាយចំណាកស្រុក នៅក្នុងបណ្តាប្រទេសគោលដៅដែលពេញនិយមសម្រាប់ការធ្វើចំណាកស្រុក។ កត្តាជាច្រើនដែលបានគូសបញ្ជាក់នៅក្នុងផ្នែកនេះ ដូចជា សុខុមាលភាពកុមារ សិទ្ធិកាន់កាប់ដីធ្លីនិង ទីផ្សារការងារ មានទំនាក់ទំនងគ្នាទៅវិញទៅមកនិងធ្វើសមាយាតលើបទពិសោធរបស់ពលករចំណាកស្រុក រួមទាំងកាលានុវត្តភាពដែលអាចរកបានសម្រាប់ពួកគេនិងបញ្ហាប្រឈមដែលពួកគេជួបប្រទះ។

សព្វថ្ងៃនេះ ស្ថិរភាពនៃគ្រួសារនៅជនបទក្នុងប្រទេសកម្ពុជា មិនអាចត្រូវបានកាត់ផ្តាច់ពីកម្រិតប្រាក់ឈ្នួលពលកម្មនៅវិស័យឧស្សាហកម្មនិងថ្លៃឈ្នួលផ្ទះនៅតាមលម្ហទីក្រុងឡើយ។ នៅក្នុងមធ្យោបាយដូចគ្នា គ្រួសារមួយមិនអាចពិចារណាអំពីការយល់ឃើញអំពីសុវត្ថិភាពរបស់អ្នករស់នៅទីក្រុង ពេលត្រូវបានផ្តាច់ចេញពី លក្ខខណ្ឌជីវិតសម្រាប់សមាជិកគ្រួសារនៅតាមជនបទ។ ការប៉ះទង្គិចនៃប្រភេទណាមួយចំពោះបរិស្ថានជនបទឬទីក្រុងមានឥទ្ធិពលលើលម្ហទាំងពីរ តាមរយៈផ្នែកខ្លះនៃការភ្ជាប់ទំនាក់ទំនងទាំងនេះ។ ទន្ទឹមនឹងនេះដែរ ការធ្វើចំណាកស្រុកដ៏ធំបែបនេះ បានបង្ហាញនូវឧបករណ៍ដ៏មានឥទ្ធិពលសម្រាប់ភាពធន់របស់សហគមន៍ទាំងនៅទីក្រុងនិងជនបទ។

# របៀបការកំណត់តំបន់និងផែនការប្រើប្រាស់ដីទីក្រុង ធ្វើឱ្យប៉ះពាល់ដល់ជីវភាពនិងការតាំងលំនៅក្រៅផ្លូវការ

**បណ្ឌិត ជួន ទ្រី**
មជ្ឈមណ្ឌលខេមរសិក្សា

## សេចក្តីណែនាំ

ដូចទៅនឹងទីក្រុងជាច្រើនទៀតនៅអាស៊ីអាគ្នេយ៍ រាជធានីភ្នំពេញកំពុងមានការរីកចម្រើនយ៉ាងឆាប់រហ័ស ប៉ុន្តែ ក៏ងាយរងគ្រោះទាំងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនិងភាពក្រីក្រនៅក្នុងសហគមន៍ទីក្រុង។ ការធ្វើផែនការរៀបចំដែនដីនិងការកំណត់តំបន់ប្រើប្រាស់ដី ជាទស្សនាទានសំខាន់ក្នុងការបង្កើតការអនុវត្តសម្រាប់ការគ្រប់គ្រងដែនដី។ ប៉ុន្តែ ទំនាក់ទំនងរបស់ពួកគេជាមួយនឹងទម្រង់នៃអបរិយាបន្ននៅតែត្រូវបានសិក្សាតិចតួចក្នុងចំណោមអ្នកសិក្សាទីក្រុងនៅក្នុងតំបន់។ រលកនៃការធ្វើនគរូបនីយកម្មនាពេលបច្ចុប្បន្នកំពុងកើតឡើងស្របជាមួយនឹងការផ្លាស់ប្តូររបស់រដ្ឋាភិបាលនូវវិធីសាស្ត្រក្នុងការចាត់ថ្នាក់ លម្អអេកូឡូស៊ីសង្គមនិងមុខងារនៃតំបន់ដែលបានស្នើឡើង។ ស្របពេលជាមួយគ្នា ការពង្រីកទីក្រុងនេះ ជារឿយៗមើលរំលងប្រព័ន្ធដីសើមដែលមានស្រាប់ ដែលដីនិងទឹកមានទំនាក់ទំនងគ្នាទៅវិញទៅមក។ ទស្សនៈនៃការអភិវឌ្ឍបែបនេះក៏មើលរំលងនូវ យន្តការដែលមានស្រាប់ដែលសហគមន៍មូលដ្ឋានពឹងផ្អែកលើ ដែលអាចមានផលប៉ះពាល់ដល់ទម្រង់នៃការអនុវត្តភាពធន់នៅទីក្រុង។ ការជន់លិចនៃទឹកជំនន់នៅក្នុងតំបន់ទីក្រុងក៏ធ្វើឱ្យកាន់តែធ្ងន់ធ្ងរឡើងនូវភាពមិនទៀងទាត់និងភាពងាយរងគ្រោះក្នុងចំណោមប្រជាជនក្រីក្រក្នុងទីក្រុង( Friend & Moench, ២០១៥ )។

បន្ទាប់ពីត្រូវបានបណ្តេញចេញដោយបង្ខំនៅក្នុងទសវត្សឆ្នាំ១៩៧០ ភ្នំពេញបានទទួលប្រជាជនរបស់ខ្លួនវិញនៅដើមទសវត្សឆ្នាំ១៩៨០ ( Nam, ២០១១ )។ ប្រជាជនទីក្រុងបានកើនឡើងដល់១,២លាននាក់នៅឆ្នាំ១៩៩៨ ១,៥លាននាក់ក្នុងឆ្នាំ២០០៨ និង១,៨៥លាននាក់ក្នុងឆ្នាំ២០១២។ នៅឆ្នាំ២០៣៥ ចំនួនប្រជាជនត្រូវបានគេប៉ាន់ស្មានថាមានចំនួន២,៨៦លាននាក់( World Bank Group, ២០១៧ )។ ព្រំប្រទល់និងរដ្ឋបាលរបស់ទីក្រុងក៏កំពុងពង្រីកយ៉ាងឆាប់រហ័សផងដែរ ដើម្បីឱ្យស្របតាមកំណើននេះ។ បច្ចុប្បន្ននេះ រាជធានីភ្នំពេញមានខណ្ឌចំនួន១២ ចែកជា ៦៦សង្កាត់ និង៩០៩ភូមិដែលបានគ្របដណ្តប់លើផ្ទៃដីចំនួន៦៧៦គីឡូម៉ែត្រក្រឡានិងមាននិន្នាការក្នុងការពង្រីកបន្ថែមទៀត។ ការពង្រីកទៅតំបន់បឹងនៃទីក្រុងនិងតំបន់ដីសើមនៅតំបន់ជាយទីក្រុងខាងក្រៅ តាមបណ្តោយប្រព័ន្ធទន្លេបានក្លាយជាយុទ្ធសាស្ត្រដ៏សំខាន់ក្នុងការត្រួសត្រាយផ្លូវសម្រាប់គម្រោងអចលនទ្រព្យ ដូចជា បុរី ( gated communities )និងទីក្រុងរណបដែលបានក្លាយជាក្តីសុបិន្តទំនើបក្នុងចំណោម

ក្រុមមនុស្សវណ្ណៈកណ្ដាល វណ្ណៈខ្ពស់ និងអ្នកវិនិយោគដែលកំពុងលេចធ្លោ និងអ្នកអភិវឌ្ឍន៍មកពីប្រទេសដែលមានប្រាក់ចំណូលខ្ពស់។ ដោយមានតម្រូវការកាន់តែច្រើនឡើងៗ សម្រាប់តំបន់(ដី) ដើម្បីអភិវឌ្ឍ វិនិយោគិនមាននិន្នាការគាំទ្រដល់យុទ្ធសាស្ត្ររបស់រដ្ឋដើម្បី«បង្កើត»លម្ហប្រជុំជន តាមរយៈការផ្លាស់លំនៅរបស់ប្រជាជនក្រីក្រ ដោយបង្ខំកាន់តែខ្លាំងឡើងក្នុងទីក្រុង។ ផ្នែកនេះមានគោលបំណងដើម្បីបង្ហាញពីទិដ្ឋភាពទូទៅនៃនិន្នាការអភិវឌ្ឍន៍ទីក្រុងតាមរយៈការពិនិត្យមើលលើការពិភាក្សានិងគោលនយោបាយទាក់ទងនឹងការធ្វើផែនការនិងការកំណត់តំបន់ប្រើប្រាស់ដី ដែលជាផលវិបាកនៃបទប្បញ្ញត្តិបែបនេះសម្រាប់សហគមន៍ទីក្រុងនិងនិន្នាការរយៈពេលយូរនៃការតាំងលំនៅក្រៅផ្លូវការ។ ដូច្នេះ អត្ថបទស្រាវជ្រាវនេះ ពិភាក្សាអំពីមធ្យោបាយដែលអាចកើតមាន ដើម្បីលើកកម្ពស់ភាពធន់តាមរយៈការធ្វើផែនការទីក្រុង។

## កិច្ចសន្ទនានិងគោលនយោបាយជុំវិញការធ្វើផែនការនិងការកំណត់តំបន់

ការពង្រីកតំបន់ទីក្រុងទៅលើតំបន់ដីសើមនិងតំបន់ទំនាបលិចទឹក នៅតែជាគោលដៅសំខាន់សម្រាប់ការធ្វើលម្ហឯកជនភាវូបនីយកម្មនៅក្នុងប្រទេសកម្ពុជា។ ទម្រង់នៃការពង្រីកទាំងនេះ រួមមាន ការចាក់ដីបំពេញបឹងនៅទីក្រុងនិងការផ្លាស់ប្តូរតំបន់លិចទឹក ទៅជាតំបន់អគារខ្ពស់ៗចម្រុះដែលគេស្គាល់ថាជាទីក្រុងរណប (Percival, ២០១៦)។ ការអភិវឌ្ឍប្រភេទនេះ កំពុងកើនឡើងដែលដឹកនាំដោយតួអង្គសំខាន់ៗ ជាពិសេសអ្នកអភិវឌ្ឍន៍និងវិនិយោគិន។ ចក្ខុវិស័យទីក្រុងភ្នំពេញសម្រាប់ឆ្នាំ២០៣៥ រួមបញ្ចូលទាំងគំនិតនៃទីក្រុងប្រកបដោយមេត្រីភាពធុរកិច្ច ដែលការប្រកួតប្រជែងសេដ្ឋកិច្ចមានការរីកចម្រើននិងជាមជ្ឈមណ្ឌលនយោបាយនិងវប្បធម៌នៃប្រទេសកម្ពុជា ជាមួយនឹងការអភិវឌ្ឍប្រកបដោយចីរភាពនិងសមធម៌។ ប៉ុន្តែ មាតិកាខ្លឹមសារនៃផែនការនេះសន្យាបម្រើផលប្រយោជន៍ជាចម្បងរបស់សហគ្រាសឯកជននិងទីភ្នាក់ងារពហុភាគី(Paling, ២០១២)។ ផែនការនេះអនុគ្រោះដល់ក្រុមអ្នកយុទ្ធសាស្ត្រទីក្រុងដែលកំពុងរីកចម្រើន អ្នកជំនាញទីក្រុងនិងឥស្សរជនក្នុងតំបន់។ ភាគច្រើននៃការសម្រេចបាននៃផែនការ អាស្រ័យលើការធ្វើឱ្យសមស្របនូវដីធ្លីទីក្រុងពីជនក្រីក្រ (Fauveaud, ២០១៤)។ ភាគច្រើននៃការសម្រេចបាននូវផែនការ គឺសមាយាតលើការដកយកនូវដីទីក្រុងពីប្រជាជនក្រីក្រ(Fauveaud, ២០១៤)។

ចាប់តាំងពីសម័យអាណានិគម ការកំណត់តំបន់ប្រើប្រាស់ដីត្រូវបានប្រើជាឧបករណ៍ផែនការរៀបចំដែនដីទីក្រុង ដើម្បីបង្កើតលម្ហថ្មីៗដើម្បីជំរុញសណ្តាប់ធ្នាប់សង្គម ដើម្បីផលិតនិងថែរក្សារចនាសម្ព័ន្ធសង្គម(រួមទាំងប្រព័ន្ធនៃការធ្វើចំណាត់ថ្នាក់ក្រុមជនជាតិភាគតិច)និងដើម្បីបែងចែកតំបន់មជ្ឈមណ្ឌលពាណិជ្ជកម្មនិងតំបន់រដ្ឋបាល។ អ្នកធ្វើផែនការនៅសម័យអាណានិគមបានឃើញការកំណត់តំបន់ប្រើប្រាស់ដីជាគោលការណ៍គ្រឹះសម្រាប់ទីក្រុង ដែលគម្រោងរួមបញ្ចូលទាំងមុខងាររបស់តំបន់លំនៅឋាន តំបន់ពាណិជ្ជកម្ម តំបន់ឧស្សាហកម្ម និងតំបន់រដ្ឋបាល។ ក្នុងនាមជាផ្នែកមួយនៃអតីតប្រព័ន្ធអាណានិគមបារាំង(ជាអាណាព្យាបាល) រាជធានីភ្នំពេញចង្អុលបង្ហាញពីវិធីដែលការអនុវត្តន៍ការកំណត់តំបន់ប្រើប្រាស់ដី បានជំពាក់ជំពិនជាមួយវិជានសង្គម ស្របពេលជាមួយគ្នាការអនុវត្តន៍ទាំងនេះចូលរួមចំណែកដល់ទស្សនៈពិភពលោកយ៉ាងពិសេស ថ្នាក់ជំនាញនិងមានទំនាក់ទំនងជាមួយគំនិតលោកខាងលិចនៃការធ្វើផែនការទំនើប។ ការកំណត់តំបន់ប្រើប្រាស់ដីបានក្លាយជាទម្រង់សំខាន់មួយនៃ

នគរូបនីយកម្មនៅក្នុងប្រទេសជាច្រើន រួមមាន របៀបដែលវាជូនដំណឹងដល់គោលនយោបាយទីក្រុង របៀបដែលវាភ្ជាប់ទៅនឹងគំនិតអំពីការអភិវឌ្ឍនៃទីក្រុងល្អ គួឱ្យរស់នៅនិងទំនើប និងរបៀបដែលវាអាចជួយដល់ការព្យាករណ៍នៃចំនួនប្រជាជននិងកំណើនសេដ្ឋកិច្ច(Esposito, ២០១៨)។ នៅក្នុងអតីតកាល ការរៀបចំទឹកនិងដីដែលត្រូវបានគេស្គាល់ថាទឹកដី(territory) បានជះឥទ្ធិពលយ៉ាងខ្លាំងដល់ទស្សនាទានខ្មែរនៃប្លង់ទីក្រុង។ ការតាំងលំនៅរបស់មនុស្សត្រូវបានផ្សារភ្ជាប់ជាមួយនឹងប្រភពទឹកដែលអាចត្រូវបានប្រើសម្រាប់សាងសង់ផ្លូវទឹក ប្រព័ន្ធទឹក បឹង និងព្រែក ដើម្បីទ្រទ្រង់ការដឹកជញ្ជូន ការចិញ្ចឹមជីវិត និងការអនុវត្តវប្បធម៌ (Esposito, ២០១៨)។ ការរចនាប្លង់នេះត្រូវបានធ្វើផែនការយ៉ាងល្អជាមួយនឹងប្រព័ន្ធទឹកដែលតំណាងឱ្យអន្តរកម្មរវាងមនុស្សនិងបរិស្ថាន (Molyvann, ២០០៣)។

ក្នុងប៉ុន្មានទសវត្សថ្មីៗនេះ រដ្ឋាភិបាលបានធ្វើចំណាត់ថ្នាក់ឡើងវិញនូវការកំណត់តំបន់ប្រើប្រាស់ដីនិងទ្រព្យសម្បត្តិរដ្ឋ។ តំបន់ដីសើមនិងបឹង ជាទីលម្ហមួយក្នុងចំណោមទីលម្ហដ៏ធំបំផុត ដែលត្រូវបានគេចាត់ទុកថាជាទ្រព្យសម្បត្តិរដ្ឋនៅក្នុងតំបន់ទីក្រុង។ នៅក្នុងនិងជុំវិញរាជធានីភ្នំពេញ បច្ចុប្បន្នមានបឹងចំនួន២៦ ដែលមានទំហំច្រើនជាង១០០គីឡូម៉ែត្រការ៉េ។ អ្នកអភិវឌ្ឍន៍បានចាក់បំពេញឬកំពុងដំណើរការចាក់បំពេញ១៦បឹងក្នុងចំណោមបឹងទាំងនេះ ដែលមានផ្ទៃសរុបស្មើនឹង៤០%ឬ៤១គីឡូម៉ែត្រការ៉េ។ យោងតាមវិធាននិងនីតិវិធីនៃព្រះរាជក្រឹត្យលេខ ៣៣៩ ចុះថ្ងៃទី ឆ្នាំ២០០៦ ទ្រព្យសម្បត្តិរដ្ឋ ដូចជា បឹងនៅទីក្រុង តំបន់ដីសើម និងដីផ្សេងទៀត អាចត្រូវបានធ្វើអនុប្រយោគទៅជាទ្រព្យសម្បត្តិនីតិបុគ្គលសាធារណៈនិងទ្រព្យសម្បិត្តសាធារណៈរបស់រដ្ឋ។ លក្ខខណ្ឌចំនួនបីចាំបាច់ត្រូវវាយតម្លៃនិងចាត់ថ្នាក់ ដើម្បីប្រែក្លាយបឹងនៅទីក្រុងទាំងនេះជាកម្មសិទ្ធិឯកជន។ ទី១- ទ្រព្យសម្បត្តិឬទ្រព្យសកម្មមិនត្រូវបានប្រើប្រាស់ ដើម្បីផលប្រយោជន៍សាធារណៈទៀតទេ។ ទី២- ទ្រព្យសម្បត្តិឬទ្រព្យសកម្មទាំងនេះ បានបាត់បង់តម្លៃនិងមុខងាររបស់ពួកគេក្នុងការផ្តល់សេវាសាធារណៈឬផ្តល់ផលប្រយោជន៍សាធារណៈ។ ចុងក្រោយ បឹងទាំងនេះមិនត្រូវប្រើប្រាស់ដោយផ្ទាល់ជាសាធារណៈទៀតទេ(STT, ២០១៩)។

ស្ថិតក្នុងចំណោមបទប្បញ្ញត្តិទាំងនេះ ភាពតានតឹងកើតមានឡើងរវាងផែនការអភិវឌ្ឍបច្ចុប្បន្ននិងប្រព័ន្ធធ្វើផែនការយ៉ាងល្អសម្រាប់ការគ្រប់គ្រងទឹក តាមរយៈបណ្តាញតំបន់លិចទឹកនៅទូទាំងទីក្រុង ដែលគេស្គាល់ថាជាព្រែកនិងបឹងដែលបានបង្កើតឡើងតាំងពីទសវត្សឆ្នាំ១៩៦០។ ប្រព័ន្ធទាំងនេះ មិនអាចស្ថិតស្ថេរបានឡើយ ដោយសារឥទ្ធិពលពីតម្លៃផ្លាស់ប្តូរនៃតម្លៃដីធ្លីនៅទីក្រុង។ សព្វថ្ងៃនេះ អ្នកអភិវឌ្ឍន៍បានបម្លែងបឹងនិងប្រឡាយទាំងអស់ដែលភ្ជាប់ទៅនឹងប្រព័ន្ធបូមទឹកនិងប្រព័ន្ធបង្ហូរទឹកពីអតីតកាលទៅជាអាគារខ្ពស់ៗ មជ្ឈមណ្ឌលពាណិជ្ជកម្ម និងលម្ហការិយាល័យទំនើប(Molyvann, ២០០៣)។ ភាពតានតឹងរវាងការអភិវឌ្ឍទីក្រុងនិងការគ្រប់គ្រងទឹកប្រកបដោយប្រសិទ្ធភាពនៅក្នុងទីក្រុង ត្រូវបានធ្វើឱ្យកាន់តែធ្ងន់ធ្ងរឡើងថែមទៀត ស្ថិតក្រោមឥទ្ធិពលនៃគំនិតផ្តួចផ្តើមផ្លូវមួយខ្សែក្រវ៉ាត់មួយរបស់ប្រទេសចិន(Yamada, ២០១៩)។ បរិយាកាសនៃការអភិវឌ្ឍនាពេលបច្ចុប្បន្នបាននាំឱ្យមានការគាំទ្រដោយគ្មានលក្ខខណ្ឌនិងការវិនិយោគក្នុងផលិតកម្មនៃលម្ហដែលយកចិត្តទុកដាក់លើពាណិជ្ជកម្ម ឧស្សាហកម្មកម្មន្តសាល និងគម្រោងលំនៅឋាននៅក្នុងទីតាំងយុទ្ធសាស្ត្ររបស់ប្រទេស។

នៅក្នុងការអនុវត្តជាក់ស្តែង ការបង្កើតបទប្បញ្ញត្តិ ការកំណត់តំបន់ប្រើប្រាស់ដីតាមរយៈច្បាប់ភូមិបាលបម្រើផលប្រយោជន៍ចម្បងដល់វិស័យឯកជននិងផ្តល់អាទិភាពដល់ការរស់រានមានជីវិតនិងជោគជ័យនៃវណ្ណៈមូលធននិយម(Brenner and Elden, ២០០៩)។ ដំណើរការនេះ ឆ្លុះបញ្ចាំងពីផលិតកម្មនៃលម្ហទីក្រុងតាមរយៈ

យុទ្ធសាស្ត្រការគ្រប់គ្រងរបស់រដ្ឋលើគោលនយោបាយរៀបចំដែនដី(Lefebvre, ២០១៦)។ គោលនយោបាយបែបនេះ អាចត្រូវបានប្រើដើម្បីរៀបចំឡើងវិញនូវភូមិសាស្ត្រនៃការតាំងលំនៅរបស់ប្រជាជននិងតម្រង់ទិសឡើងវិញនូវការវិនិយោគហេដ្ឋារចនាសម្ព័ន្ធដែលមានលក្ខណៈអនុគ្រោះកាន់តែប្រសើរឡើង ដើម្បីពង្រីកមូលធន។ នយោបាយរៀបចំដែនដីបែបនេះ ច្រើនតែផ្ទុយនឹងការប្តេជ្ញាចិត្តជាផ្លូវការរបស់រដ្ឋ ចំពោះសុខុមាលភាពសាធារណៈ។ នៅពេលអនុវត្តជាក់ស្តែង ផែនការប្រើប្រាស់ដីនៅតាមទីក្រុងជាញឹកញាប់បង្ហាញពីតួនាទីផ្ទុយគ្នា ដែលរដ្ឋដើរតួនាទីសំខាន់ក្នុងការសម្រេចបាននូវគោលបំណងប្រកបដោយប្រសិទ្ធភាពនិងកំណើនសេដ្ឋកិច្ចសង្គមប្រកបដោយចីរភាពនិងសមភាព ព្រមទាំងការប្តេជ្ញាចិត្តចំពោះសន្តិសុខស្បៀងនិងបរិស្ថានធម្មជាតិ ប្រកបដោយសុខុមាលភាព(MOE and GGGI, ២០១៩)។

## តថភាពជាក់ស្តែងសម្រាប់សហគមន៍ក្រីក្រនៅទីក្រុង

សហគមន៍ក្រីក្រនៅក្នុងទីក្រុងភាគច្រើន(UPC) រស់នៅលើដីសាធារណៈ ជាមួយការទទួលបានតិចតួចនូវសិទ្ធិកាន់កាប់ដីធ្លី។ ភាគច្រើននៃតំបន់ទាំងនោះស្ថិតនៅលើឬជាប់នឹងបឹងនិងតំបន់ដីសើមនៅទីក្រុង។ ទីក្រុងបានក្លាយជាតំណាងនៃការតស៊ូប្រចាំថ្ងៃ ដើម្បីសិទ្ធិរស់រានមានជីវិតនិងសេចក្តីថ្លៃថ្នូរសម្រាប់សហគមន៍ទាំងនេះ(Stavrides, ២០១៦)។ ដូចនៅក្នុងផ្នែកត្រូវពិភាក្សា ការចូលរួមវិភាគទាននៅក្នុងសមូហកម្មរបស់ Bertrais ពិភាក្សាអំពីបឹងនៅទីក្រុងនានាក្នុងរាជធានីភ្នំពេញ ដែលជាយន្តការដ៏សំខាន់មួយក្នុងការរក្សាទុកសំណល់រាវចេញពីមជ្ឈមណ្ឌលទីក្រុងនិងទឹកភ្លៀង(ជាមធ្យម ទឹកចំនួន៣៧០ ០០០ម៉ែត្រគូបក្នុងមួយថ្ងៃ ត្រូវបានបូមពីរាជធានីភ្នំពេញចូលទៅក្នុងតំបន់ដីសើម មុនពេលបង្ហូរពេងចក្រប្រព្រឹត្តកម្ម)។ ដូច Bertrais បានពិភាក្សា ទីក្រុងកំពុងដំណើរការចាក់បំពេញបឹងទាំងនេះ ដោយមានការប៉ូមខ្សាច់យ៉ាងច្រើនពីទន្លេមេគង្គនិងទន្លេបាសាក់។ ការណ៍នេះនឹងជះឥទ្ធិពលអវិជ្ជមានដល់ប្រជាជនប្រមាណជា១,២លាននាក់ តាមរយៈការកើនឡើងនៃទឹកជំនន់នៅទីក្រុងនិងការបាក់ច្រាំងទន្លេដោយអចេតនា(LICADHO et al., ២០២០)។ នេះគឺស្ថិតនៅលើកំពូលនៃការកើនឡើងជាបន្តបន្ទាប់នៃទឹកជំនន់ដែលជះឥទ្ធិពលដល់បូរីមួយចំនួន។ លើសពីនេះទៅទៀត ការណ៍នេះបង្ហាញពីការបាត់បង់នៃផលិតកម្មចំណីត្រីដែលពឹងផ្អែកលើដីសើមនិងបឹង។ ប្រការនេះបានជំរុញឱ្យមានការពឹងផ្អែកកាន់តែខ្លាំងលើការខ្ចីប្រាក់ពីប្រភពឥណទានខ្នាតតូចនិងផលវិបាកនៃជីវិតមិនខាន នៅពេលប្រភពនៃជីវភាពរបស់ពួកគេត្រូវបានបាត់បង់។ ប្រការនេះបានជំរុញឱ្យមានការពឹងផ្អែកកាន់តែខ្លាំងលើការខ្ចីប្រាក់ពីប្រភពផ្សេងៗរបស់ឥណទានខ្នាតតូច(មីក្រូក្រេឌីត) និងផលវិបាកនៃជីវិតមិនទៀងទាត់ នៅពេលប្រភពនៃជីវភាពរបស់ពួកគេត្រូវបានបាត់បង់។

ប្រសិនបើរួមបញ្ចូលបញ្ហាទាំងនេះ យើងឃើញមានឧបសគ្គយ៉ាងធ្ងន់ធ្ងរដល់លទ្ធភាពទទួលបានសិទ្ធិរបស់ប្រជាជនទាំងនេះចំពោះទីក្រុងនេះ។ សិទ្ធិទាំងនេះ រួមមាន សិទ្ធិលំនៅឋាន អាហារ ការងារ អនាម័យ និងទឹក។ ការកំណត់និងការបែងចែកតំបន់ប្រើប្រាស់ដីនឹងអាចបង្កើតការទទួលស្គាល់កាន់តែប្រសើរឡើងសម្រាប់សហគមន៍ក្រីក្រនៅទីក្រុង ប្រសិនបើមានការរៀបចំផែនការត្រឹមត្រូវនិងការចូលរួមរបស់សហគមន៍មូលដ្ឋាន។ ស្ថានភាពនេះត្រូវបានបញ្ចូលទៅក្នុងកម្មវិធីកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រដែលអាចនាំឱ្យមានការធ្វើនិងការទទួលបានសេវាសង្គមកាន់តែប្រសើរ(World Bank, ២០១៧)។

## វិធីលើកកម្ពស់ភាពធន់តាមរយៈការធ្វើផែនការទីក្រុង

បទពិសោធពីទីក្រុងផ្សេងៗក្នុងតំបន់បង្ហាញថា ភាពងាយរងគ្រោះនៅទីក្រុងជាញឹកញាប់ត្រូវបានផ្សារភ្ជាប់ទៅនឹងការទទួលបាននិងអារម្មណ៍នៃភាពជាម្ចាស់សាធារណៈនៃប្រព័ន្ធនិងសេវាកម្មទីក្រុង។ ប្រព័ន្ធអេកូឡូស៊ីធនធានក្នុងតំបន់ និងសមត្ថភាពបន្សាំ ទាំងពីររបស់ស្ថាប័ននិងភ្នាក់ងារ ពាក់ព័ន្ធផ្សេងៗនៅតែជាវិស័យជាប់ទាក់ទងសម្រាប់យុទ្ធសាស្ត្រដោះស្រាយ(Friend & Thinphanga, ២០១៦)។ ប្រជាជនក្រីក្រនិងអ្នករស់នៅទីក្រុងថ្មីភាគច្រើន មកតាំងលំនៅនៅលើបរិស្ថានបង្កើតដោយមនុស្ស ដែលងាយរងគ្រោះដោយសារទឹកជំនន់និងការផ្លាស់ប្តូរ(Bulkerley, ២០១៣)។ ដូច្នេះ តម្រូវការសម្រាប់ការគិតកម្រិតជាប្រព័ន្ធគួរមានកាន់តែច្រើននៅពេលការរៀបចំនៃទីក្រុងត្រូវបានធ្វើឡើង (Bébé, *et al.*, ២០១៨)។ ដូចគ្នានេះដែរ ដំណើរការនៃការចូលរួមយុទ្ធសាស្ត្ររៀនសូត្ររួមគ្នាក្នុងចំណោមតួអង្គឬក្រុមសង្គមដែលពាក់ព័ន្ធ មិនគួរត្រូវបានគេមើលរំលងក្នុងការកសាងសមត្ថភាពសម្របខ្លួនទេ(Tyler & Moench, ២០១២) និងចៀសវាងអន្ទាក់ស្ថាប័ន(Lebel, Manuta, & Garden, ២០១១)។ ភាពធន់ត្រូវបានគេមើលឃើញថា ជាសមត្ថភាពក្នុងការរស់រានឬដោះស្រាយនៅពេលទទួលរងនូវផលប៉ះពាល់ខាងក្រៅ ដូចជា ទឹកជំនន់ ការដួលរលំនៃប្រព័ន្ធទីក្រុង និងពហុទម្រង់នៃការផ្លាស់ប្តូរទីក្រុង ខណៈពេលជាមួយគ្នាផងដែរ ក៏មានការខ្វះការយល់ដឹងជារួមក្នុងចំណោមតួអង្គនិងស្ថាប័នសំខាន់ៗនៅថ្នាក់ជាតិនិងថ្នាក់មូលដ្ឋាន។

នៅក្នុងទីក្រុងភ្នំពេញ ភាពធន់នៅទីក្រុងអាចត្រូវបានកសាងឡើងតាម៤វិធី។ ទី១- គឺតម្រូវការសម្រាប់ក្រសួងដើម្បីទទួលបាននូវចំណេះដឹងកាន់តែស៊ីជម្រៅរបស់អត្ថន័យនៃភាពធន់។ទី២- ក្នុងចំណោមស្ថាប័នរៀបចំផែនការនិងក្រុមការងារបច្ចេកទេស ចាំបាច់ត្រូវទទួលបានជោគជ័យលើបំណែងចែកស្ថាប័ននានានៅក្នុងការសម្របសម្រួលរវាងរដ្ឋ ឯកជន សហគមន៍មូលដ្ឋាន និងស្ថាប័នសង្គមស៊ីវិល។ អនុសាសន៍ទី៣និងទី៤- ទាក់ទងទៅនឹងតម្រូវការសម្រាប់ការត្រួតពិនិត្យនិងតុល្យភាព ដែលមានប្រសិទ្ធិភាពជាងឥទ្ធិពលរបស់អ្នកអភិវឌ្ឍន៍ឯកជន និងតម្រូវការក្នុងការបង្កើតដំណើរការរៀនសូត្ររួមគ្នា ក្នុងចំណោមតួអង្គពាក់ព័ន្ធនិងយន្តការការងារប្រកបដោយប្រសិទ្ធភាពក្នុងចំណោមតួអង្គរបស់រដ្ឋ។ ម្យ៉ាងទៀត ប្រព័ន្ធផ្អែកលើគុណសម្បត្តិ គួរតែត្រូវបានពង្រឹងដើម្បីលើកកម្ពស់វិជ្ជាជីវៈរបស់បុគ្គលិកនៅក្នុងទីភ្នាក់ងារសាធារណៈ(Beckwith and Keo, ២០២០)។

ការផ្សាភ្ជាប់ការចូលរួមនិងចំណេះដឹងមូលដ្ឋានពីកសិករនៅតាមទីក្រុងនិងសហគមន៍ជុំវិញ ក៏ពាក់ព័ន្ធនឹងការកសាងភាពធន់របស់សហគមន៍ប្រឆាំងនឹងភាពងាយរងគ្រោះនិងការផ្លាស់ប្តូរទីក្រុង។ អ្នកធ្វើគោលនយោបាយមិនគួរព្រងើយកន្តើយចំពោះកិច្ចខិតខំប្រឹងប្រែងបច្ចុប្បន្ន ដែលគាំទ្រដោយសង្គមស៊ីវិលក្នុងការកៀរគរនិងសហការផលិតនូវដំណើរការរៀនសូត្រនេះ។ ឧបករណ៍ទាំងនេះរួមមានការធ្វើផែនទីសហគមន៍ជាមួយនឹង ការបណ្តុះបណ្តាលជាបន្តបន្ទាប់ទាក់ទងនឹងចក្ខុវិស័យសហគមន៍ ការគ្រប់គ្រងជីឡូតិ៍ រចនាសម្ព័ន្ធសំណង់លំនៅឋាន បញ្ជីទ្រព្យសម្បត្តិ និងបញ្ជីទ្រព្យសកម្ម និងសារពើភណ្ឌនិងទិន្នន័យមូលដ្ឋាន។ ឧបករណ៍ទាំងនេះផ្តល់នូវការលើកចិត្តឱ្យមានការចូលរួមកាន់តែច្រើន ក្នុងចំណោមតួអង្គក្នុងស្រុកនិងធ្វើឱ្យមានអារម្មណ៍នៃភាពជាម្ចាស់របស់សហគមន៍ក្នុងការលើកកម្ពស់ទីក្រុងរួម។ យុទ្ធសាស្ត្រទាំងនេះ ភាគច្រើនអនុវត្តចំពោះប្រជាជនក្រីក្រនៅទីក្រុងនិងប្រជាជនដែលរស់នៅក្នុងការតាំងលំនៅក្រៅផ្លូវការនិងការអភិវឌ្ឍលំនៅឋានដែលមានតម្លៃទាប (COHRE and CMDP,

២០០៩ ) ( Brugman, ២០១៤ ) ( Garnock and Choeun, ២០១៦ )។ ការសិក្សាថ្មីមួយរបស់ Beckwith and Keo ( ២០២០ )គាំទ្រវិធីសាស្រ្តនេះ។ ដំណើរការទាំងនេះមិនគួរត្រូវបានគេចាត់ទុកថាជាការគំរាមកំហែងដល់ការផ្លាស់ប្តូរទីក្រុងទេ។ ប៉ុន្តែ ជាមធ្យោបាយមួយដើម្បីចែករំលែកលម្ហទីក្រុងនិង ចក្ខុវិស័យសម្រាប់អនាគតប្រកបដោយនិរន្តរភាព។

## សេចក្តីសន្និដ្ឋាននិងគោលនយោបាយពាក់ព័ន្ធ

ការស្រាវជ្រាវថ្មីមួយនៅក្នុងទីក្រុងអាស៊ីអាគ្នេយ៍ បានបង្ហាញថា ដើម្បីសម្រេចបាននូវទម្រង់ថ្មីៗនៃអភិបាលកិច្ចដែលដោះស្រាយសិទ្ធិរបស់ពលរដ្ឋ( អនុវត្តតាមគោលការណ៍ផ្អែកលើសិទ្ធិ )។ ដូច្នេះ ស្ថាប័ននានានឹងត្រូវផ្លាស់ប្តូរឆ្ពោះទៅរកដំណើរការគោលនយោបាយដែលតម្រង់ទិសការសិក្សា អាចបត់បែនបាននិងគោលនយោបាយបន្សាំ។ ដំណើរការទាំងនេះក៏នឹងត្រូវដោះស្រាយហានិភ័យនិងភាពមិនច្បាស់លាស់ទាក់ទងនឹងការប្រែប្រួលអាកាសធាតុ។ តម្រូវការសម្រាប់ការធ្វើផែនការជំរុញសហគមន៍ជាមួយការចូលរួមពីសង្គមស៊ីវិលដែលជឿទុកចិត្តបាន នៅតែមានសារៈសំខាន់។ ផ្អែកលើបទពិសោធពីអាស៊ីអាគ្នេយ៍ ក៏ដូចជាកន្លែងផ្សេងទៀត មានចលនាយុត្តិធម៌នៅតាមទីក្រុងដែលទាមទារឱ្យមានការចូលរួមពីអ្នករស់នៅទីក្រុង ក្នុងដំណើរការរៀបចំផែនការ។ ចលនាទាំងនេះ បង្ហាញនូវអារម្មណ៍ដែលឥស្សរជននិងអ្នកជំនាញមិនត្រូវបានជឿទុកចិត្តថាអាចបានធ្វើការតែម្នាក់ឯង ដើម្បីផ្តល់នូវអ្វីដែលល្អបំផុតសម្រាប់សាធារណៈជននិងសហគមន៍ចម្រុះរបស់ខ្លួន ( Healey, ២០១០ )។ គម្រោងការកសាង ធ្វើផែនការ ចាំបាច់ត្រូវលើកកម្ពស់ជីវភាពរស់នៅនៅទីក្រុង តាមរយៈការទទួលស្គាល់ភាពចម្រុះនិងតម្រូវការរបស់មនុស្សនិងការគោរពលក្ខខណ្ឌបរិស្ថានដែលអាចទ្រទ្រង់ប្រព័ន្ធទីក្រុងនិងអនុញ្ញាតឱ្យមនុស្សលូតលាស់បានយ៉ាងល្អនៅកន្លែងជាក់លាក់។ ផ្លាស់ប្តូរដែនដីនិងគម្រោងផែនការនៅក្នុងតំបន់ទីក្រុងចាំបាច់ត្រូវគិតពិចារណាពីភាពរស់រវើក និរន្តរភាព ភាពអាចចូលដល់បាន និងការចូលរួម។

រាជធានីភ្នំពេញ ជាទីក្រុងដែលកំពុងលេចធ្លោក្នុងចំណោមទីក្រុងនានានៅអាស៊ីអាគ្នេយ៍ នៅតែមានឱកាសធ្វើដំណើរឆ្ពោះទៅរកនិរន្តរភាពនិងដើម្បីដោះស្រាយភាពងាយរងគ្រោះនៅទីក្រុង តាមរយៈការកសាងភាពធន់កាន់តែខ្លាំងឡើងនៅចំពោះមុខនៃប្រកពសក្តានុពលនៃគ្រោះថ្នាក់និងការផ្លាស់ប្តូរមុនពេលវាយឺតពេល។ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ទី១១ ស្តីពីការ «ធ្វើឱ្យទីក្រុងនិងទីកន្លែងតាំងលំនៅថ្មីសម្រាប់ប្រជាជនប្រកបដោយបរិយាបន្ន សុវត្ថិភាព ធន់ និងចីរភាព» និងទី១៣ ដែលទាក់ទងទៅនឹងសកម្មភាពបន្ទាន់ ដើម្បីដោះស្រាយការប្រែប្រួលអាកាសធាតុ នៅតែជាគោលការណ៍សំខាន់ៗដែលគួរតែជាចំណុចកណ្តាល សម្រាប់ការធ្វើផែនការទីក្រុងដែលបានកែលម្អ( RGC, ២០១៨ )។ មានតម្រូវការដើម្បីប្រតិបត្តិនិងស្វែងយល់ឱ្យកាន់តែប្រសើរឡើងនូវទស្សនាទាននៃការអភិវឌ្ឍភាពធន់និងសមត្ថភាព ការអភិវឌ្ឍស្ថាប័ននិងការចូលរួមនៅមូលដ្ឋាន។ រាជធានីភ្នំពេញនៅតែមានឱកាស ដើម្បីបញ្ចៀសអន្ទាក់នៃភាពក្រីក្រនិងភាពងាយរងគ្រោះនៅទីក្រុង ប្រសិនបើប្រៀបធៀបទៅនឹងទីក្រុងដែលបានបង្កើតឡើងយ៉ាងល្អនៅអាស៊ីអាគ្នេយ៍។

# ផ្នែកត្រូវពិភាក្សា ៖ ងាយរងគ្រោះផ្នែកសង្គមនិងបរិស្ថានដែលមានទំនាក់ទំនងទៅនឹងការអភិវឌ្ឍទីក្រុងដោយគ្មានការគ្រប់គ្រងនៅបឹងជើងឯក

Dolorès Bertrais
វិទ្យាស្ថាន The Environmental Governance and Territorial Development
សាកលវិទ្យាល័យ Geneva

## រាជធានីភ្នំពេញ ៖ ទីក្រុងនៃលំហូរចូល

នាពេលថ្មីៗនេះ ទម្រង់ដែលពឹងផ្អែកពិសេសនៃការអភិវឌ្ឍទីក្រុង កំពុងកើតឡើងនៅភាគខាងត្បូងនៃរាជធានីភ្នំពេញឆ្ពោះទៅតំបន់បឹងជើងឯកនិងកំពុងសាយភាយបន្តិចម្តងៗ នៅលើតំបន់ដីទំនាបដែលធ្លាប់ត្រូវបានការពារតិចតួចពីការអភិវឌ្ឍផ្សេងៗ។ ទេសភាពធម្មជាតិដែលលាតសន្ធឹងលើផ្ទៃរាបកំពុងបាត់បង់ ដោយជំនួសមកវិញនូវទេសភាពទីក្រុងបញ្ឈរ។ ការបង្កើតមហាវិថីហ៊ុនសែននៅកណ្តាលបឹងជើងឯកបានជំរុញនូវការផ្តួចផ្តើមនូវការផ្លាស់ប្តូរទ្រង់ទ្រាយធំនេះ។ ជម្រើសទាក់ទងនឹងការអភិវឌ្ឍទីក្រុងនេះមិនពាក់ព័ន្ធនឹងការការស្តារឡើងវិញនូវសំណង់អគារនិងជង់ស៊ីតេនៃខណ្ឌប្រវត្តិសាស្ត្រទេ។ ប៉ុន្តែ គឺជាការពង្រីកទីក្រុងទៅក្នុងតំបន់ជនបទឬលម្ហ ដែលមិនទាន់បានអភិវឌ្ឍកន្លងមក។ ដូចដែលបណ្ឌិត ធួន ទ្រី បានលើកឡើងនៅក្នុងការចូលរួមចំណែករបស់គាត់ថា យុទ្ធសាស្ត្រអភិវឌ្ឍន៍ទីក្រុងទាំងនេះពាក់ព័ន្ធនឹងការធ្វើឱ្យមានភាពសមស្របនៃធនធានធម្មជាតិ ដើម្បី បម្លែងដែនផ្ទៃទឹកនិងដីជុំវិញ ទៅជាទម្រង់នៃទ្រព្យសម្បត្តិដែលមានតម្លៃ។ ធម្មជាតិនៃការផ្លាស់ប្តូរនេះធ្វើឱ្យអ្នករស់នៅក្នុងលម្ហនេះប្រឈមនឹងហានិភ័យ ហើយក៏មានផលប៉ះពាល់ផងដែរនូវរបៀបដែលបរិស្ថាននឹងឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុនិងប្រភពនៃគ្រោះថ្នាក់ផ្សេងទៀត ដែលអត្ថបទស្រាវជ្រាវនេះមានលម្អិតដូចខាងក្រោមនេះ។

## ការអភិវឌ្ឍទីក្រុងនិងការជកហូតក្នុងបឹងជើងឯក

បឹងជើងឯកបានបំពេញមុខងារចាំបាច់ពីរយ៉ាង ដោយសារផ្ទៃទឹកបឹងនេះមានទំហំធំ( ប្រហែល២៨០០ ហិកតា )។ តួនាទីទី១ បឹងនេះជួយទឹកស្អាតសំណល់រាវចេញពីទីក្រុងភ្នំពេញ ដែលហូរឆ្លងកាត់បឹង មុនពេលសំណល់រាវនេះត្រូវបានបញ្ចេញទៅក្នុងទន្លេមេគង្គ( APUR, ២០១៩ )។ ម្យ៉ាងទៀត បឹងនេះមានសមត្ថភាពក្នុងការរក្សាទឹកក្នុងរដូវវស្សានិងការរក្សាទឹកក្នុងរយៈពេលជាច្រើនសប្តាហ៍ ខណៈពេលរង់ចាំដល់កម្រិតទឹកទន្លេមេគង្គ

ធ្លាក់ចុះ។ ក្នុងពេលមានទឹកជំនន់ ក្រឡាផ្ទៃបឹង២៨០០ហិកតាទាំងនេះ រួមបញ្ចូលទាំងបរិមាណទឹកសន្ទឹកសន្ទាប់ (APUR, ២០១៩)។ បឹងជើងឯកមានមុខងារជាធារាសាស្ត្រសំខាន់ៗដើម្បីឱ្យផ្នែកខ្លះនៃរាជធានីត្រូវបានការពារពីទឹកជំនន់។ ទោះយ៉ាងណាក៏ដោយ តុល្យភាពនេះហាក់ដូចជាត្រូវបានបែកបាក់ចាប់តាំងពីការអនុវត្តគម្រោង ING City។ អន្តរជានជាបណ្តើរៗនៃបឹងជើងឯក មានន័យថាមុខងារធម្មជាតិនៃការគ្រប់គ្រងសំណល់រាវនិងការការពារទីក្រុង ប្រឆាំងនឹងទឹកជំនន់នឹងរលាយបាត់បង់ ដោយជំនួសមកវិញ ដោយដំណោះស្រាយបច្ចេកទេសសុទ្ធសាធ និងមានតម្លៃថ្លៃបំផុត។ ម្យ៉ាងទៀត បរិស្ថានអាងស្តុកទឹកនិងកសិកម្មដែលកំពុងអន្តរជានទៅវិញ នៅពេលដែលការអភិវឌ្ឍជឿនលឿននៃលម្ហទីក្រុង ដូចជា បឹងជើងឯកឬបឹងកក់ដែលត្រូវបានប្រើប្រាស់(APUR, ២០១៩)។ អ្នកភូមិជាច្រើនបានតាំងលំនៅនៅទីនោះ បន្ថែមពីលើពពួកសត្វនិងរុក្ខជាតិដែលផ្តល់ជីវចម្រុះពិសេស។ ការអនុវត្តកសិកម្មនិងការនេសាទ នៅតែកើតមានជាធម្មតា ហើយប្រជាជននៅតំបន់ជនបទទាំងនេះខិតខំដាំដុះដំណាំលើដីនិងទឹកដោយគ្មានពេលសម្រាក។ ទោះយ៉ាងណាក៏ដោយ ប្រតិបត្តិការកិច្ចការជំនួញដីធ្លីដែលទាក់ទងនឹងការពន្លាតការអភិវឌ្ឍ បានធ្វើឱ្យមានផលវិបាកក្នុងទម្រង់នៃការផ្លាស់លំនៅ ដែលជំរុញឱ្យប្រជាជនដែលតាំងលំនៅបម្លាស់ទីចេញពីទីក្រុង។ ក្នុងករណីជាច្រើន គម្រោងទាំងនេះលេចចេញជាមូលដ្ឋានក្នុងរយៈពេលកំណត់និងដំណើរការតាំងលំនៅថ្មីដែលជាប់ទាក់ទងនឹងដំណើរការនៃការតាំងលំនៅថ្មី ដោយប្រថុយប្រថាន ជំរុញឱ្យមានការបណ្តេញប្រជាជនដោយបង្ខំនិងភាពអយុត្តិធម៌នៃការបណ្តេញចេញ ដូចដែលបានលើកឡើងក្នុងករណីរបស់បឹងកក់ ដែលអសន្តិសុខសិទ្ធិកាន់កាប់កម្មសិទ្ធិ បានជួយសម្រួលដល់រដ្ឋាភិបាលក្នុងការដកយកចេញនូវគ្រួសារចំនួនបីភាគបួននៃគ្រួសារដើម(Schneider, ២០១១; Brickell, ២០១៤)។

បន្ថែមលើផលវិបាកសង្គមនៃការអភិវឌ្ឍទីក្រុង ការផ្លាស់ប្តូរបឹងជើងឯកឬបឹងកក់គំរាមកំហែងដល់តុល្យភាពបរិស្ថានដ៏ប្រណីតនៃលម្ហធម្មជាតិ ជីវចម្រុះរបស់បឹង និងវិធីដែលប្រជាជនបានធ្វើអន្តរកម្មជាមួយបឹងនិងវាលទំនាប។ បឹងជើងឯកត្រូវបានចាត់ទុកថាជាបឹងមួយក្នុងចំណោមបឹងដ៏អស្ចារ្យចុងក្រោយនៅក្នុងរាជធានីភ្នំពេញ ដែលមានលក្ខណៈអេកូឡូស៊ីល្អឯក(APUR, ២០១៩)។

ទោះជាដូចនេះក្តី ខឿនឬទំនប់ការពារទឹកបន្តគ្នាមិនដាច់ ដែលសាងសង់ពីការបូមយកដីខ្សាច់ពីបាតទន្លេមេគង្គនិងទន្លេបាសាក់ មិនត្រឹមតែមានតម្លៃថ្លៃជាងមុនប៉ុណ្ណោះទេ។ ប៉ុន្តែ ក៏មានផលប៉ះពាល់គួរឱ្យព្រួយបារម្ភដល់បរិស្ថាននិងជាពិសេសទៅលើច្រាំងទន្លេ ដែលកំពុងរអិលបាក់ចូលទៅក្នុងទន្លេ។ ការបាក់ច្រាំងទន្លេនេះ បានធ្វើឱ្យមនុស្សជាច្រើនប្រឈមនឹងការបាត់បង់ផ្ទះនៅតាមមាត់ទន្លេរបស់ពួកគេ។ អ្នកអភិវឌ្ឍន៍ទាញយកដីខ្សាច់ដ៏ច្រើននៃទន្លេមេគង្គនិងទន្លេបាសាក់ ដើម្បីចាក់លុបបំពេញបឹងនិងយកដីខ្សាច់ ដើម្បីធ្វើបេតុងសម្រាប់ការដ្ឋានសំណង់។ ការទាញយកខ្សាច់ទាំងនេះ(តែងតែមិនស្របច្បាប់)មានផលវិបាកយ៉ាងខ្លាំងទៅលើប្រព័ន្ធអេកូឡូស៊ី។ ខ្សាច់កំពុងដើរតួយ៉ាងសំខាន់នៅក្នុងប្រព័ន្ធអេកូឡូស៊ី ហើយខ្សាច់នេះកំពុងក្លាយជាធនធានដែលអាចបង្កគ្រោះថ្នាក់មួយដែលអាចជះឥទ្ធិពលដល់ជីវចម្រុះនិងការហូរច្រោះនិងបង្កើនជាតិប្រៃនីយកម្ម(Peduzzi, ២០១៤)។

ម្យ៉ាងទៀត ការផ្លាស់ប្តូរបរិស្ថាន ដែលបង្កឡើងដោយតួអង្គខាងក្រៅមួយចំនួន ដូចជា អ្នកអភិវឌ្ឍន៍ធ្វើឱ្យលម្ហជាច្រើនមានអន្តរាយដល់ជីវភាពរស់នៅដែលចាំបាច់សម្រាប់ការរស់រានមានជីវិតរបស់ប្រជាជន(Blanchon et al., ២០០៩)។ ការវិចវិលនៃបរិស្ថានធម្មជាតិភ្លាមៗរបស់ប្រជាជនក្រីក្របំផុត ដែលនៅតែពឹងផ្អែកយ៉ាងខ្លាំងលើធនធានធម្មជាតិ ហាក់ដូចជាបង្កើតឬធ្វើឱ្យវិសមភាពបរិស្ថាននិងសង្គមកាន់តែធ្ងន់ធ្ងរ(Duru-Bellat,

២០១៤)។ ការវិចវិលនេះ រាប់បញ្ចូលទាំងការផ្លាស់ប្តូរទៅជា «បឹងទឹកប្រៃ- lagooning» ដែលជាបច្ចេកទេសធម្មជាតិសម្រាប់ការធ្វើប្រព្រឹត្តកម្មសំណល់ ដែលរួមមានការប្រមូលផ្តុំនៃសំណល់រាវនៅក្នុងបឹង។ ស្របពេលដែលបច្ចេកទេសធម្មជាតិនេះបានចូលរួមចំណែកយ៉ាងសំខាន់ជាប្រវត្តិសាស្ត្រ ដល់ការបន្សុទ្ធទឹកប្រកបដោយនិរន្តរភាពអេកូឡូស៊ីនិងមានតម្លៃថោកនៃសំណល់រាវពីភាគខាងត្បូងនៃរាជធានីភ្នំពេញ ដែលហូរចូលទៅបឹងដោយផ្ទាល់ ការចាក់បំពេញបឹងដែលជាផ្នែកមួយនៃគម្រោងសាងសង់ ធ្វើឱ្យលែងមានទៀតនូវការអនុវត្តបែបនេះនិងមានផលប៉ះពាល់ដល់របៀបដែលសហគមន៍ដោះស្រាយជាមួយសំណល់។ វាអាចចំណាយពេលច្រើនឆ្នាំ មុនពេលសហគមន៍ដែលរងផលប៉ះពាល់ជួបប្រទះការធ្លាក់ចុះនៃបរិស្ថានទាំងមូលនៃការផ្លាស់ប្តូរទាំងនេះ។ លើសពីនេះទៅទៀត សហគមន៍នានានឹងមិនមានសមត្ថភាពដូចគ្នា ដើម្បីសម្របខ្លួន អាស្រ័យទៅលើភេទ អាយុ និងឋានៈសង្គមរបស់ពួកគេឡើយ( Becerra, ២០១២ )។ នេះបង្ហាញពីចំណុចដែលងាយរងគ្រោះខាងបរិស្ថានមានលក្ខណៈសង្គមមួយយ៉ាងលេចធ្លោ ពីព្រោះសកម្មភាពរបស់មនុស្ស ជាលទ្ធផលគួរឱ្យកត់សម្គាល់នៃដំណើរការសង្គម។

## លើសពីការសម្រេចចិត្តនៅថ្នាក់មូលដ្ឋាន

ការអភិវឌ្ឍឥតឈប់ឈរ ដែលកំណត់លក្ខណៈរាជធានីរបស់ប្រទេសកម្ពុជាក្នុងរយៈពេល២០ឆ្នាំចុងក្រោយនេះ បានបង្កើតឱ្យមានភាពមិនប្រក្រតីនៃបរិស្ថាននិងសង្គម។ វាក៏បង្ហាញពីការរំលោភបំពានលើសម្បត្តិរួម (commons) ពោលគឺ ធនធានធម្មជាតិ ដូចជា ទឹកដែលរួមចំណែកដល់សុខុមាលភាពសាធារណៈ។ ដូចដែលត្រូវបានកត់សម្គាល់នៅកន្លែងផ្សេងទៀតដែរ ការសម្រេចចិត្តនៅក្នុងប្រទេសកម្ពុជាទាក់ទងនឹងផ្លូវទឹករបស់ប្រទេស អាចមានឥទ្ធិពលក្នុងតំបន់ឬជាសកលទៅលើធនធាននេះ ពិសេសនៅក្នុងតំបន់ដែលទឹកហូរជាលក្ខណៈប្រពៃណីធម្មតានៅក្នុងភាពសម្បូណ៌។ ជាក់ស្តែង ការសាងសង់ឬការធ្វើផែនការនៃទំនប់វារីអគ្គិសនីនៅតាមដងទន្លេមេគង្គ បង្ហាញនូវអនាគតមិនច្បាស់លាស់មួយសម្រាប់ផ្លូវទឹកក្នុងតំបន់( Räsänen et al., ២០១២ )។ ភាពមិនច្បាស់លាស់នេះ ត្រូវបានបង្ហាញរួចហើយតាមរយៈទឹកជំនន់តាមរដូវកាលកាន់តែកើនឡើងខ្លាំងនាពេលថ្មីៗ។ ក្នុងរយៈពេលវែង ការណ៍នេះអាចធ្វើឱ្យប្រទេសមានអស្ថិរភាពនិងបង្កើតឱ្យមានជម្លោះភូមិសាស្ត្រនយោបាយនិងសេដ្ឋកិច្ចសង្គមជាច្រើននៅក្នុងតំបន់ ដែលត្រូវបានផ្គត់ផ្គង់ដោយទន្លេមេគង្គ។ រឿងរ៉ាវនៃការអភិវឌ្ឍទីក្រុងនិងការបំផ្លិចបំផ្លាញបរិស្ថាននៅបឹងជើងឯក ជាការបង្ហាញឱ្យឃើញមួយនៃគន្លងការអភិវឌ្ឍទីក្រុងនាពេលបច្ចុប្បន្នរបស់ប្រទេសកម្ពុជា ដែលនាំឱ្យប្រជាជនរបស់ខ្លួនកាន់តែងាយរងគ្រោះជាងមុនពីគ្រោះថ្នាក់នៃការប្រែប្រួលអាកាសធាតុ។

# រាជធានីភ្នំពេញនិងការអភិវឌ្ឍអចលនទ្រព្យ : បច្ច័យថ្មីៗដើម្បីពិចារណាពីភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ច

**បណ្ឌិត Gabriel Fauveaud**
ដេប៉ាតឺម៉ង់ភូមិវិទ្យា សាកលវិទ្យាល័យ Montreal

## ទីផ្សារអចលនទ្រព្យនៅក្នុងសេដ្ឋកិច្ចកម្ពុជា

ក្នុងរយៈពេល២០ឆ្នាំកន្លងមក វិស័យអចលនទ្រព្យនិងសំណង់បានក្លាយជាកម្លាំងចលករនៃកំណើនសេដ្ឋកិច្ចកម្ពុជា។ នៅឆ្នាំ២០១៧ អចលនទ្រព្យនិងសំណង់ ដែលរួមទាំងសេវាកម្មទាក់ទងនឹងវិស័យអចលនទ្រព្យ បានចូលរួមចំណែកស្មើរតែមួយភាគបីនៃផលិតផលក្នុងស្រុកសរុប (World Bank Group, ២០១៨) ដែលស្មើរតែស្មើនឹងការចូលរួមចំណែករបស់វិស័យកសិកម្ម។

ការកើនឡើងនូវតម្រូវការក្នុងស្រុកសម្រាប់លំនៅឋាន ក្នុងចំណោមក្រុមមនុស្សដែលមានកម្រិតសេដ្ឋកិច្ចសង្គម ពីមធ្យមទៅខ្ពស់ បានធ្វើឱ្យមានការកើនឡើងយ៉ាងឆាប់រហ័សនៃការអភិវឌ្ឍវិស័យអចលនទ្រព្យរវាងផ្នែកទី២នៃទសវត្សឆ្នាំ១៩៩០និងទសវត្សឆ្នាំ២០០០។ ប្រការនេះបានបណ្តាលឱ្យមានគម្រោងសាងសង់លំនៅឋានថ្មីរាប់រយកន្លែង ជាពិសេសនៅតាមជាយតំបន់ទីក្រុង។ ប៉ុន្តែ ចាប់តាំងពីពាក់កណ្តាលទសវត្សឆ្នាំ២០០០ មកលំនៅឋាននិងដីធ្លីបានក្លាយជាការវិនិយោគទុនដោយប្រថុយប្រថាន(Fauveaud, ឆ្នាំ២០១៥)។ ការអនុម័តច្បាប់ថ្មីក្នុងឆ្នាំ២០១០ ដែលមានការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអាគារសហកម្មសិទ្ធិដល់ជនបរទេសចាប់ពីខាងលើជាន់ទី១ឡើងទៅ បានបង្កើនការវិនិយោគទុនដោយប្រថុយប្រថាននិងការកើនឡើងយ៉ាងឆាប់រហ័សនៃតម្លៃលំនៅឋាននិងដីធ្លី។

## លក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃអចលនទ្រព្យ-ហិរញ្ញវត្ថុ

ការរីកចម្រើនយ៉ាងឆាប់រហ័សនៃវិស័យអចលនទ្រព្យ ត្រូវបានតភ្ជាប់ជាមួយនឹងវិស័យហិរញ្ញវត្ថុ។ ទី១- អត្រានៃប្រាក់ឱ្យខ្ចីនៅជំពាក់ ដូចជា ឥណទានមានទ្រព្យបញ្ចាំ(mortgage)បានកើនឡើងយ៉ាងខ្លាំងក្នុងរយៈពេល២០ឆ្នាំកន្លងមក។ បំណុលឯកជន ប្រាក់កម្ចី និងមូលបត្របំណុលបានកើនឡើងពី៦,៣៨% នៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ២០០០ រហូតដល់ជិត១០០%នៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ២០១៨។ គ្រាន់តែចន្លោះឆ្នាំ២០១៤និង២០១៧ តែមួយ ភាគរយនៃប្រជាជនដែលមានអាយុចាប់ពី១៥ឆ្នាំឡើងទៅ ដែលមានប្រាក់ឱ្យខ្ចី

នៅជំពាក់សម្រាប់ផ្ទះសម្បែងបានកើនឡើងពី១២% ទៅ ១៦%។[8] ការថយចុះនៃអត្រាការប្រាក់ ព្រមទាំងការកើនឡើងនៃចំនួនប្រជាជនប្រើប្រាស់សេវាកម្មធនាគារ បានអនុគ្រោះដល់កំណើននៃបំណុលផ្ទាល់ខ្លួន ជាពិសេសសម្រាប់ការទិញផ្ទះ។ កំណើនបំណុលគ្រួសារបានពង្រីកវិសាលភាពលើវិស័យហិរញ្ញវត្ថុដែលបង្កើនហានិភ័យនៃការប្រឈមនឹងការប្រែប្រួលសេដ្ឋកិច្ច(World Bank Group, ២០១៩)។ ក្រៅពីនេះ ការធ្វើពិពិធកម្មនៃលទ្ធភាពទទួលបានឥណទានមានទ្រព្យបញ្ចាំ ត្រូវបានលើកទឹកចិត្តដោយវិសាលគមដ៏ធំនៃស្ថាប័នហិរញ្ញវត្ថុ ដូចជាទីភ្នាក់ងារឥណទានខ្នាតតូច ក៏ដូចជា ធនាគារបានផ្តល់ជូននូវប្រាក់កម្ចីមានទ្រព្យបញ្ចាំដែលបង្កើតដោយអ្នកអភិវឌ្ឍន៍បរទេស។ ស្ថាប័នទាំងនេះច្រើនតែប្រើការអនុវត្តការផ្តល់ប្រាក់កម្ចីហួសប្រមាណ(predatory lending) ដើម្បីទាក់ទាញអតិថិជនដែលគ្មានលទ្ធភាពក្នុងការសងប្រាក់សងគ្រប់។ ប៉ុន្តែ ពួកគេក៏ប្រាថ្នាចង់ទទួលបានអត្ថប្រយោជន៍ពីការប្រថុយប្រថានលើអចលនទ្រព្យផងដែរ។

ទី២- វិស័យឧស្សាហកម្មសំណង់និងអចលនទ្រព្យកំពុងពឹងផ្អែកកាន់តែខ្លាំងលើការវិនិយោគបរទេស។ ការវិនិយោគផ្ទាល់ពីបរទេស(FDI) បានកើនឡើងច្រើនជាងដប់ដងក្នុងចន្លោះឆ្នាំ១៩៩៨និងឆ្នាំ២០១៧ (Fauveaud, ២០២០)។ FDI ក្នុងវិស័យសំណង់ អចលនទ្រព្យ និងកន្លែងស្នាក់នៅ តំណាងឱ្យស្មើរតែមួយភាគបីនៃ FDIសរុបក្នុងឆ្នាំ២០១៤ តួលេខនេះហាក់ដូចជានៅតែមាន មិនមានការប្រែប្រួលចាប់តាំងពីពេលនោះមក (National Bank of Cambodia, ២០១៦)។ «នៅឆ្នាំ២០១៥ គឺ៣០ភាគរយនៃក្រុមហ៊ុនដែលកំពុងប្រតិបត្តិការសកម្មក្នុងវិស័យសាងសង់គឺក្រុមហ៊ុនបរទេស(National Bank of Cambodia, ២០១៦)។ នៅចន្លោះឆ្នាំ ២០១០និងឆ្នាំ២០១៥ មាន២៨ភាគរយនៃលម្ហការសាងសង់សរុប ត្រូវបានផលិតដោយក្រុមហ៊ុនបរទេស។ នៅចន្លោះឆ្នាំ២០០០និងឆ្នាំ២០១៥ ប្រទេសកូរ៉េខាងត្បូង ចិន និងជប៉ុន គឺជាវិនិយោគិនបរទេសធំទី៣ក្នុងវិស័យសំណង់។ ដោយឡែកសម្រាប់វិស័យអចលនទ្រព្យ ប្រទេសចិន ជាវិនិយោគិនបរទេសទីមួយនៅចន្លោះឆ្នាំ ២០១០និងឆ្នាំ២០១៥ បន្ទាប់មក គឺប្រទេសជប៉ុន សិង្ហបុរី កូរ៉េខាងត្បូង តៃវ៉ាន់ និងម៉ាឡេស៊ី។ [...] ប្រទេសចិនបានក្លាយជាអ្នកផ្គត់ផ្គង់ទីមួយនៃការវិនិយោគផ្ទាល់ពីបរទេសដែលជាសាជីវកម្មនិងមិនមែនសាជីវកម្មនៅក្នុងវិស័យអចលនទ្រព្យនៅកម្ពុជា»(Fauveaud, ២០២០)។ ក្នុងឆ្នាំ២០១៨ FDI សុទ្ធ សរុបតំណាងឱ្យ១៣% នៃផលិតផលក្នុងស្រុកសរុបនៅក្នុងប្រទេសកម្ពុជា។ នៅក្នុងឆ្នាំដដែល FDI តំណាងឱ្យ៦% នៅប្រទេសវៀតណាម ២% នៅប្រទេសថៃ១,៨% នៅប្រទេសឥណ្ឌូណេស៊ីនៃផលិតផលក្នុងស្រុកសរុបរបស់ពួកគេ។ បើប្រៀបធៀបទៅនឹងសេដ្ឋកិច្ចប្រទេសនៅអាស៊ីអាគ្នេយ៍ សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាពឹងផ្អែកជាពិសេសទៅលើការវិនិយោគបរទេសដែលបង្កើនភាពប្រឈមចំពោះការប្រែប្រួលនៃសេដ្ឋកិច្ចពិភពលោក។

ទី៣- ទីផ្សារលំនៅឋានត្រូវបានស្រូបទាញដោយការវិនិយោគបរទេស ដែលមិនមែនជាសាជីវកម្ម។ ឧទាហរណ៍ គេប៉ាន់ស្មានថាអ្នកទិញជាជនបរទេសកាន់កាប់យ៉ាងតិច៦៥%នៃឯកតាខុនដូ(condo units) (National Bank of Cambodia, ២០១៦)។ ទោះជាយ៉ាងណាក៏ដោយ អត្រានេះលាក់បាំងនូវទិដ្ឋភាពនៃវិសមានភាពរបស់ភាពជាម្ចាស់ខុនដូ។ ឯកតាលំនៅឋានជាច្រើននៅក្នុងគម្រោងលំនៅឋានលំដាប់ខ្ពស់ដែលសាងសង់ដោយអ្នកអភិវឌ្ឍន៍បរទេសភាគច្រើន ត្រូវបានទិញដោយវិនិយោគិនបរទេស ខណៈដែលគម្រោងលំនៅ

---

[8] https://globalfindex.worldbank.org

ឋានលំដាប់ថ្នាក់កណ្តាលត្រូវបានទិញជាចម្បងដោយអតិថិជនក្នុងស្រុក។ ទោះជាដូចនេះក្តី មួយផ្នែកធំនៃទីផ្សារខុនដូត្រូវបានរចនាឡើង ដើម្បីទាក់ទាញអ្នកទិញជាជនបរទេសដែលកំពុងស្វែងរកភាគលាភជួលខ្ពស់និងយុទ្ធសាស្ត្រត្រឡប់(ការទិញនិងការលក់ឯកតាខុនដូក្នុងរយៈពេលខ្លី)។ អ្នកអភិវឌ្ឍន៍បរទេស ដោយមានជំនួយពីភ្នាក់ងារអចលទ្រព្យអន្តរជាតិ កំពុងលក់ឯកតាខុនដូនៅក្នុងប្រទេសដើមរបស់ពួកគេ។ លើសពីនេះទៅទៀត ការអភិវឌ្ឍនៃទីផ្សារលំនៅឋានសកលឪជីថល អនុគ្រោះដល់ការជ្រៀតចូលកាន់តែច្រើននៃការវិនិយោគបរទេស។ ទីភ្នាក់ងារអចលនទ្រព្យក្នុងស្រុកកំពុងមានការជួញដូរកាន់តែច្រើនឡើងជាមួយអ្នកទិញជាជនបរទេស។ ពួកគេខ្លះបានរាយការណ៍ថាភាគច្រើននៃវិនិយោគិនបរទេសទាំងនេះ នឹងមិនដែលឈានជើងចូលក្នុងប្រទេសកម្ពុជាទេ។ ទាំងអស់នេះបង្ហាញពីរបៀបដែលការវិនិយោគអចលនទ្រព្យបរទេសដោយប្រថុយប្រថាននៅកម្ពុជា កំពុងបង្កើនហានិភ័យនៃការបង្កើតពពុះអចលនទ្រព្យ។

ទី៤- ក្របខណ្ឌច្បាប់ដែលត្រូវបានគេសន្មតថាធ្វើឱ្យមានភាពប្រសើរឡើង ដើម្បីគ្រប់គ្រងនិងត្រួតពិនិត្យការវិនិយោគបរទេសក្នុងវិស័យអចលនទ្រព្យនៅតែមិនគ្រប់គ្រាន់។ នៅលើផ្នែកនៃវិនិយោគិនបុគ្គល អតិបរមានៃ ៧០% នៃឯកតានៅក្នុងគម្រោងអចលនទ្រព្យ អាចត្រូវបានលក់ទៅឱ្យម្ចាស់ជាជនបរទេស។ ចំពោះផ្នែកខាងសាជីវកម្មវិញ អ្នកវិនិយោគបរទេសមិនអាចមានសិទ្ធិជាម្ចាស់ដីនិងត្រូវវិនិយោគជាមួយសមភាគីក្នុងស្រុក។ ទោះយ៉ាងណាក៏ដោយ វិធីសាស្ត្រជាច្រើនត្រូវបានគេប្រើប្រាស់ដើម្បីបញ្ចៀសក្របខណ្ឌច្បាប់ទាំងនេះ ដូចជា ការបង្កើតក្រុមហ៊ុនបញ្ចូលគ្នាដែលមានមូលដ្ឋានក្នុងស្រុក ការទិញសញ្ជាតិខ្មែរឬការទិញដីតាមរយៈរចនាសម្ព័ន្ធអ្នកតំណាង។ យុទ្ធសាស្ត្រច្បាប់យ៉ាងពេញនិយមទាំងនេះ ដែលត្រូវបានចងក្រងជាឯកសារដោយក្រុមហ៊ុនអចលនទ្រព្យនិងក្រុមហ៊ុនស្របច្បាប់ក្នុងស្រុក[9] អនុញ្ញាតឱ្យវិនិយោគិននិងអ្នកអភិវឌ្ឍន៍បរទេស ដើម្បីធ្វើឱ្យប្រាកដនូវការគ្រប់គ្រងស្ទើរតែទាំងស្រុងលើទ្រព្យសម្បត្តិអចលនទ្រព្យនៅកម្ពុជា។ ជាលទ្ធផល ក្រុមហ៊ុនអចលនទ្រព្យកម្ពុជាដែលកំពុងបង្កើតភាពជាដៃគូជាមួយក្រុមហ៊ុនបរទេស កំពុងបាត់បង់ស្វ័យភាពហើយត្រូវប្រឈមនឹងឆន្ទៈនិងយុទ្ធសាស្ត្រសេដ្ឋកិច្ចរបស់ភាគីទីបី។ ក្រៅពីនេះ សកម្មភាពរបស់អ្នកអភិវឌ្ឍន៍អចលនទ្រព្យនិងវិនិយោគិនបរទេសមានទំនាក់ទំនងយ៉ាងធំធេងជាមួយទីផ្សារហិរញ្ញវត្ថុពិភពលោក។ ក្រុមហ៊ុនទាំងនេះវិនិយោគចំណែកដ៏ច្រើននៃដើមទុនរបស់ពួកគេនៅក្នុងទីផ្សារហិរញ្ញវត្ថុនិងចំពោះអ្នកដែលត្រូវបានចុះបញ្ជីជាសាធារណៈ ភាគទុនិករបស់ពួកគេភាគច្រើនជាក្រុមហ៊ុនហិរញ្ញវត្ថុ(ឧទាហរណ៍ ធនាគារ ក្រុមហ៊ុនធានារ៉ាប់រង ក្រុមហ៊ុនគ្រប់គ្រងទ្រព្យសកម្ម មូលនិធិសោធននិវត្តន៍)។ ស្ថានភាពបែបនេះបង្កើនភាពប្រឈមដល់ក្រុមហ៊ុនកម្ពុជានិងទីផ្សារអចលនទ្រព្យនៅកម្ពុជាចំពោះការធ្លាក់ចុះនិងវិបត្តិសេដ្ឋកិច្ចពិភពលោក។

## ភាពងាយរងគ្រោះខាងសេដ្ឋកិច្ចសង្គមដែលមានការកើនឡើង

ភាពងាយរងគ្រោះខាងសេដ្ឋកិច្ចដែលកំពុងកើនឡើងទាំងនេះ បង្កគ្រោះថ្នាក់ដល់ផ្នែកទាំងអស់នៃសេដ្ឋកិច្ចកម្ពុជា។ វិស័យសំណង់និងវិស័យអចលនទ្រព្យ ក៏ដូចជាសកម្មភាពពាក់ព័ន្ធរបស់ទាំងនេះ ពឹងផ្អែកលើកម្លាំង

[9] https://www.globalpropertyguide.com/Asia/Cambodia/Buying-Guide

ពលកម្មដ៏ច្រើន។ នៅឆ្នាំ២០១៩ សហជីពសំណង់(construction syndicates)ប៉ាន់ស្មានថាមានកម្មករប្រមាណ ២០០ ០០០នាក់ កំពុងបម្រើការងារនៅក្នុងវិស័យសំណង់នៅក្នុងប្រទេស។[10] ខណៈដែលក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចាត់ទុកថាវិស័យនេះជួលកម្មករប្រមាណ ៧០ ០០០នាក់ ក្នុងមួយថ្ងៃៗ។[11] ចំនួនបែបនេះគឺពិតជាស្ថិតនៅក្រោមភាពជាក់ស្តែង ពីព្រោះចំនួនកម្មករជាច្រើនមិនបានចុះឈ្មោះជាផ្លូវការទេ។ ដូចគ្នានេះផងដែរ សកម្មភាពអចលនទ្រព្យនិងសំណង់ត្រូវការសម្ភារៈសំណង់(បេតុង ឥដ្ឋ លោហៈ) សេវាកម្មទាក់ទងនឹងវិស័យសំណង់និងអចលនទ្រព្យ(ការគ្រប់គ្រងគម្រោង ការវាយតម្លៃ គណនេយ្យវត្ថុ ហិរញ្ញវត្ថុ ធនាគារ ភ្នាក់ងារអចលនទ្រព្យ អ្នកសំអាត សន្តិសុខ ជាដើម) ស្ថាបត្យករ រចនាការនិងសិប្បករ និងអ្នកម៉ៅការបន្តជាច្រើនរាប់មិនអស់ មិនថាសម្រាប់ការសាងសង់ឬសម្រាប់ការគ្រប់គ្រងគម្រោងទេ។ វិស័យទាំងអស់នេះ ផ្តល់ការងារដល់កម្មកររាប់ពាន់នាក់។ ជាងនេះទៅទៀត វិស័យសំណង់និងអចលនទ្រព្យមានទំនាក់ទំនងយ៉ាងខ្លាំងជាមួយវិស័យទេសចរណ៍ដែលបានចូលរួមចំណែកដល់ជិត១ភាគ៣នៃផលិតផលក្នុងស្រុកសរុបរបស់កម្ពុជានៅឆ្នាំ២០១៧។[12] ម្យ៉ាងទៀត វិស័យសំណង់និងអចលនទ្រព្យរួមមាន ការផ្តល់ការងារជាច្រើននិងចំណែកសំខាន់នៃកម្លាំងពលកម្មដែលធ្វើការដោយផ្ទាល់ឬដោយប្រយោលនៅក្នុងឧស្សាហកម្មទាំងនេះ។

លក្ខខណ្ឌការងារមិនច្បាស់លាស់និងបទដ្ឋានទាប សម្រាប់សុខភាពនិងសុវត្ថិភាពរបស់កម្មករបង្កើនភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ចសង្គមនៅក្នុងវិស័យឧស្សាហកម្មសំណង់និងវិស័យដែលពាក់ព័ន្ធនឹងវិស័យនេះ។ ក្រុមសហជីព បានប៉ាន់ប្រមាណថាមានកម្មករចន្លោះពី ១ ០០០នាក់ ទៅ ១ ៥០០នាក់បានស្លាប់រៀងរាល់ឆ្នាំក្នុងការបំពេញការងាររបស់ពួកគេ។ ពិសេសស្ត្រីនៅតែងាយរងគ្រោះនៅក្នុងវិស័យឧស្សាហកម្មសំណង់ ដោយសារពួកគេប្រឈមមុខនឹងការកេងប្រវញ្ចនិងការបៀតបៀនច្រើនជាងបុរស។ ក្រៅពីនេះ ការសិក្សាអំពីឧស្សាហកម្មធ្វើឥដ្ឋបានបង្ហាញថា វិស័យនេះពឹងផ្អែកយ៉ាងខ្លាំងទៅលើការកេងប្រវញ្ចកម្លាំងពលកម្ម ជាពិសេសប្រជាជនដែលងាយរងគ្រោះបំផុត ដូចជា ស្ត្រី កុមារ និងជនចំណាកស្រុក។ ក្រុមហ៊ុនអភិវឌ្ឍន៍អចលនទ្រព្យក្នុងស្រុកនិងអន្តរជាតិល្បីៗជាច្រើន កំពុងប្រើប្រាស់រោងចក្រឡឥដ្ឋដែលអនុវត្តការកេងប្រវញ្ចមនុស្ស(Brickell et al., ២០១៨)។

ជាលទ្ធផល សម្រាប់អចលនទ្រព្យដែលប្រថុយប្រថាន ហិរញ្ញវត្ថុនីយកម្មនៃសេដ្ឋកិច្ចកម្ពុជានិងការពឹងផ្អែករបស់កម្ពុជាលើ FDI បង្កើនភាពងាយរងគ្រោះជាទូទៅនៃគ្រួសារជាច្រើន ដែលពាក់ព័ន្ធដោយផ្ទាល់ឬដោយប្រយោលនៅក្នុង(ឬប៉ះពាល់ដោយ) ផ្នែកសេដ្ឋកិច្ចទាំងនេះ។ ការធ្លាក់ចុះសេដ្ឋកិច្ចឬវិបត្តិសេដ្ឋកិច្ច ឬការផ្ទុះឡើងនូវពពុះអចលនទ្រព្យណាមួយ អាចបណ្តាលឱ្យមានការដកចេញនូវការវិនិយោគបរទេស ការធ្លាក់ចុះនៃសកម្មភាពអចលនទ្រព្យនិងសំណង់ និងការធ្លាក់ចុះនៃតម្លៃដីធ្លីនិងផ្ទះ ការបាត់បង់ការងារឬការធ្លាក់ចុះនៃលក្ខខណ្ឌការងារនិងការកើនឡើងនៃការជំពាក់បំណុលសម្រាប់ទាំងតួអង្គសាជីវកម្មនិងមិនមែនសាជីវកម្មអចលនទ្រព្យ។ ឥទ្ធិពលដូមីណូនេះ ទីបំផុតនឹងអាចនាំឱ្យមានវិបត្តិសេដ្ឋកិច្ចធ្ងន់ធ្ងរនិងការលិចលង់នៃផ្នែកដ៏ធំនៃប្រជាជនកម្ពុជា ដូចករណីនៅបណ្តាប្រទេសអាស៊ីអាគ្នេយ៍ផ្សេងទៀតក្នុងកំឡុងវិបត្តិឆ្នាំ១៩៩៧-១៩៩៨។ អវត្តមាននៃ

---

[10] https://southeastasiaglobe.com/cambodias-construction-boom-a-bust-for-workers/

[11] https://www.construction-property.com/govt-to-focus-on-construction-and-real-estate-labour-with-extended-un-programme/

[12] https://wttc.org

លំនៅឋានសាធារណៈ ក៏រារាំងការសាងសង់«បណ្ដាញ»សង្គមសម្រាប់ប្រជាជនដែលងាយរងគ្រោះបំផុតនិងបន្សល់ទុកសម្រាប់រដ្ឋ ដើម្បីត្រួតពិនិត្យនិងគ្រប់គ្រងនូវទីផ្សារលំនៅឋានឱ្យកាន់តែប្រសើរឡើង។

ភាពងាយរងគ្រោះខាងសេដ្ឋកិច្ចសង្គមដែលទាក់ទងនឹងការប្រែប្រួលនៃសេដ្ឋកិច្ចទីក្រុង មិនត្រឹមតែប៉ះពាល់ដល់គ្រួសារនៅតាមទីក្រុងប៉ុណ្ណោះទេ។ ប៉ុន្តែប៉ះពាល់ដល់គ្រួសារនៅជនបទផងដែរ។ ការងារដែលទាក់ទងនឹងផលិតកម្មទីក្រុង ក៏ផ្ដល់ការងារដល់កម្មករជនបទតាមរដូវកាលដ៏ច្រើនសន្ធឹកសន្ធាប់និងជាកត្តាជំរុញសម្រាប់ការធ្វើចំណាកស្រុកទៅកាន់ទីក្រុង។ ដូច្នេះ ភាពងាយរងគ្រោះខាងសេដ្ឋកិច្ចសង្គម តំណាងឱ្យបញ្ហាជាប្រព័ន្ធដែលត្រូវការវិធីសាស្ត្រគ្រប់ជ្រុងជ្រោយ។

## សេចក្ដីសន្និដ្ឋាន : ការត្រួតពិនិត្យឱ្យកាន់តែប្រសើរនូវទីផ្សារអចលនទ្រព្យ ដើម្បីកាត់បន្ថយភាពងាយរងគ្រោះខាងសេដ្ឋកិច្ចសង្គម

ហានិភ័យជាច្រើនទាក់ទងជាមួយការអភិវឌ្ឍនៃទីផ្សារអចលនទ្រព្យមួយ ដែល (១)ប្រថុយប្រថានខ្ពស់ (២)ពឹងផ្អែកយ៉ាងខ្លាំងទៅលើការវិនិយោគបរទេស និង(៣)បទប្បញ្ញត្តិដែលមានភាពទន់ខ្សោយ បង្កើនចំនួនភាពងាយទទួលរងគ្រោះចំពោះវិបត្តិជាប្រព័ន្ធ។ ដូច្នេះ ការអនុវត្តនៃនយោបាយសម្រាប់ការកាត់បន្ថយភាពងាយរងគ្រោះនិងហានិភ័យ មានភាពចាំបាច់ណាស់។ គំនិតផ្ដួចផ្ដើមមួយចំនួនអាចត្រូវបានអនុវត្តតាមទិសដៅនេះ ដូចជា៖

១- បង្កើតទីភ្នាក់ងារមួយដែលនឹងចងក្រងជាឯកសារនិងបោះពុម្ពផ្សាយព័ត៌មាននិងស្ថិតិអំពីការវិនិយោគអចលនទ្រព្យសាជីវកម្មនិងមិនមែនសាជីវកម្ម បង្កើតឡើងដោយអ្នកពាក់ព័ន្ធទាំងក្នុងស្រុកនិងក្រៅស្រុក

២- កំណត់ការកើនឡើងនៃតម្លៃដីធ្លីនិងផ្ទះ តាមរយៈការគ្រប់គ្រងតម្លៃលក់

៣- ការពារការអនុវត្តការវិនិយោគដែលប្រថុយប្រថានបំផុត តាមរយៈការកំណត់ភាពរហ័សនៃប្រតិបត្តិការអចលនទ្រព្យបុគ្គល(យុទ្ធសាស្ត្រត្រឡប់)

៤- ទប់ស្កាត់ការត្រួតត្រានៃទ្រព្យសម្បត្តិអចលនទ្រព្យ(ជាពិសេសដីធ្លី) ដោយក្រុមហ៊ុនបរទេសក្នុងការបណ្ដាក់ទុនរួមគ្នានិងរចនាសម្ព័ន្ធអ្នកតំណាង

៥- ដាក់កម្រិតលើការជំពាក់បំណុល ការត្រួតពិនិត្យការទទួលបានប្រសើរជាងមុននូវប្រាក់កម្ចីមានទ្រព្យបញ្ចាំនិងការហាមឃាត់ការអនុវត្តការផ្ដល់ប្រាក់កម្ចីហួសប្រមាណ

៦- គាំទ្រដល់ផលិតកម្មនៃលំនៅឋានដែលមានតម្លៃទាបនៅគ្រប់តំបន់របស់ទីក្រុង និង

៧- ធ្វើឱ្យប្រសើរឡើងនូវបទប្បញ្ញត្តិនិងការត្រួតពិនិត្យលក្ខខណ្ឌការងារនៅក្នុងវិស័យឧស្សាហកម្មសំណង់និងវិជ្ជាជីវៈដែលពាក់ព័ន្ធ។

# ឯកសារយោង

Asian Development Bank. (2009). The Economics of Climate Change in Southeast Asia: A Regional Review. Mandaluyong City, Philippines.

APUR. (2019). *Phnom Penh, extension et mutations*.

Baker, J.L., Kikutake, N., Lin, SX., Caldwell Johnson, E., Yin, S., & Ou, N. (2017). Urban Development in Phnom Penh. World Bank Group.

Bébé, C., Mehta, L., McGrannahan, G., Canno, T., Gupte, J., & Tanner, T. (2018). Resilience as a policy narrative: potentials and limits in context of urban planning. *Climate and Development, 10*(2), 116-133. doi: http://www.tandfonline.com/action/showCitFormats?doi=10.1080/17565529.2017.1301868

Becerra, S. (2012). "Vulnérabilité, risques et environnement : l'itinéraire chaotique d'un paradigme sociologique contemporain". *VertigO - la revue électronique en sciences de l'environnement*, n° Volume 12 Numéro 1 (juin). https://doi.org/10.4000/vertigo.11988.

Beckwith, L., & Keo, P. (2020). The Discourse and Practice of Resilience Policy in Phnom Penh. In D. Sanderson, & L. Bruce, *Urbanization at Risk in the Pacific and Asia: Disasters, Climate Changes and Resilience in Built-Environment* (pp. 171-185). New York: Routelege.

Bennett, N. J., Blythe, J., Tyler, S. & Ban, N.C. (2016). Communities and change in the Anthropocene: understanding social-ecological vulnerability and planning adaptations to multiple interacting exposures. *Regional Environmental Change*. 16(4): 907–926.

Birkmann, J. (2006). Measuring vulnerability to natural hazards: Towards disaster resilient societies. New York: United Nations University.

Blaikie P., Cannon T., Davis, I. & Wisner, B. (1994). *At Risk: Natural Hazards, People's Vulnerability and Disasters.* London: Routledge.

Blancot C., Fauveaud G., Luco F., Ngo N., & Prigent L. (eds), (2020). Resilient Cities: Rethinking the challenges of urban reconstruction. Phnom Penh: AIMF/APUR/CKS.

Blanchon, D., Moreau, S., & Veyret, Y. (2009). "Comprendre et construire la justice environnementale". *Annales de geographie* n° 665-666 (1): 35-60. https://doi.org/10.1080/00045608.2014.944452.

Brenner, N., & Elden, S. (2009). *Henri Lefebvre, state, space, and world: selected essays.* (G. Moore, N. Brenner, & S. Elden, Trans.) Minneapolis and London: University of Minnesota Press.

Brickell, K. (2014). ""The Whole World Is Watching": Intimate Geopolitics of Forced Eviction and Women's Activism in Cambodia". *Annals of the Association of American Geographers* 104 (6): 1256-72.

Brickell, K., Parsons, L., Natarajan, N., & Chann, S. (2018). *Blood Bricks: Untold Stories of Modern Slavery and Climate Change from Cambodia*. Retrieved from London:

Brugman, J. (2014). *Community Site Planning Mannual: A Comprehensive Process for Community Infrastructure and Housing Upgrading.* Phnom Penh and Melbourne: Community Empowerment and Development Team (CEDT) and Engineers Without Border (EWB).

Bulkerley, H. (2013). *Cities and Climate Change.* London and New York: Routledge.

Campbell, L. (2016). Stepping back: understanding cities and their systems. ALNAP working paper. Overseas Development Institute, London.

COHRE, & CMDP. (2009). *Community Mapping Training Manual: A how-to-manual for community activists in Cambodia to realize their housing rights.* Phnom Penh: Center for Housing Rights and Evictions (COHRE) and Community Managed Development Partner (CMDP).

da Silva, J., Kernaghan, S., & Lugue, A. (2012). A system approach to meeting the challenges of urban climate change. *International Journal of Urban Sustainable Development, 4*(2), 125-145.

Daniere, A., & Garschagen, M. (2019). *Urban Climate Resilience in Southeast Asia.* (A. Daniere, & M. Garschagen, Eds.) Gewerbestrasse: Springer.

Davis. M. (2006). *Planet of Slums…*

de Boer, J., Muggah, R., & Patel, R. (2016). Conceptualizing City Fragility and Resilience. United Nations University Centre for Policy Research. Working Paper 5.

Derks, A. (2008). *Khmer Women on the Move: Exploring Work and Life in Urban Cambodia.* Honolulu: University of Hawai'i Press.

Duru-Bellat, M. (2014). *Pour une planète équitable, l'urgence d'une justice globale*. Seuil, La République des idées. Paris. http://www.seuil.com/ouvrage/pour-une-planete-equitable-marie-duru-bellat/9782021158854.

Eisenbruch, M. (2017). Mass fainting in garment factories in Cambodia. Transcult Psychiatry 54(2):155-178. doi: 10.1177/1363461517703918.

Esposito, A. (2018). *Urban Development in the Margins of a World Heritage Site: In the Shadow of Angkor.* Amsterdam: Amsterdam University Press.

Fauveaud, G. (2014). Mutations of real estate actors' strategies and modes of capital appropriation in contemporary Phnom Penh. *Urban Studies, 51*(16), 3479-3494.

Fauveaud, G. (2015). *La production des espaces urbains à Phnom Penh. Pour une géographie sociale de l'immobilier*. Paris: Publications de la Sorbonne.

Fauveaud, G. (2020). The New Frontiers of Housing Financialization in Phnom Penh, Cambodia: The Condominium Boom and the Foreignization of Housing Markets in the Global South. *Housing Policy Debate*, 1-19. doi:https://doi.org/10.1080/10511482.2020.1714692

Federal Ministry for Economic Cooperation and Development, Germany (2018). *Leaving no one behind in Cambodia: The ID Poor poverty identification mechanism Case Studies on leaving no one behind.* OECD.

Friend, R., & Moench, M. (2015). Rights to urban climate resilience: moving beyond poverty and vulnerability. *Wiley Periodicals, 6*, pp. 643-651.

Friend, R., & Thinphanga, P. (2016). *Framework for Vulnerability Assessment in Urbanizing Asia: A guidebook for Urban Climate Resilience in Southeast Asia (UCRSEA)Partnership.* Bangkok: Thailand Environment Institute (TEI), Thailand. https://www.thaicityclimate

Flower, B., Fortnam, M., Kol, L., Sasin, P., Godfrey Wood, R. (2018). Using participatory methods to uncover interacting urban risks: A case study of three informal settlements in Phnom Penh, Cambodia. *Environment and Urbanization.* 30(1): 301-316.

Garnock, B., & Choeun, L. (2016). *CEDT Technical Processes Manual: Understanding Detailed Design and Cost-Estimation for Housing and Infrastructure.* Phnom Penh and Melbourne: Community Empowerment and Development Team (CEDT) and Engineers Without Borders (EWB).

Ghorra-Gobin, C. (2020). ""La ville intelligente" : qu'est-ce à dire ? | Cairn.info". *Tous Urbains*, n° 29: 12-15.

Graham, S. & Marvin, S. (2001). *Splintering Urbanism: Networked Infrastructures, Technological Mobilities and the Urban Condition*. London: Routledge.

Green, D., & King, R. (2010). The Global Economic Crisis and Developing Countries. Oxfam Research Report.

Grumbine, R.E., Dore, J. & Xu, J. (2012). Mekong hydropower: drivers of change and governance challenges. *Frontiers in Ecology and the Environment.* 10(2): 91-98.

Harvey, D. (2008). *Géographie de la domination.* Les Prairies Ordinaires. Paris.

Healey, P. (2010). *Making Better Places: The Planning Project in the Twenty-First Century.* London: Plagrave Macmillan.

Jamil, S. (2013). Connecting the Dots: The Urban Informal Sector and Climate Vulnerabilities in Southeast Asia's Megacities. NTS Alert No. AL13-1. Consortium of Nontraditional Security Studies in Asia.

Kanbur, R., & Zhuang, J. (2013). Urbanization and Inequality in Asia. *Asian Development Review*, *30*(1), 131–147.

Krellenberg, K., Welz, J., Link, F., & Barth, K. (2017). "Urban Vulnerability and the Contribution of Socio-Environmental Fragmentation: Theoretical and Methodological Pathways." *Progress in Human Geography* 41(4):408–31.

Lawreniuk, S. (2016). The ties that bind: Rural-urban linkages in the Cambodian migration system. In K. Brickell & S. Springer (eds)., *The Handbook of Contemporary Cambodia*. (202-211). London: Routledge.

Lebel, L., Manuta, J., & Garden, P. (2011). Institutional Traps and vulnerability to changes in climate and flood regimes in Thailand. *Regional Environmental Change, 11*, 45-58.

Lefebre, H. (1991). *The Production of Space.* Oxford and Cambridge: Blackwell.

Lefebvre, H. (2016). *Marxist Thought and the City.* (R. Bononno, Trans.) Minneapolis and London: University of Minnesota Press.

LICADHO, CYN, EC, & STT. (2020). *Smoke on the Water: A social and human rights impact assessment of the destruction of the Tompoun/Cheung Ek wetland.* Phnom Penh: Cambodia Leaque for the Promotion and Defense of Human Rights (LICADHO), Cambodia Youth Network (CYN), Equitable Access (EC) and Samakum Teang Tnaut (STT).

Limthongsakul, S., Nitivattananon, V., & Dwiananto Arifwidodo, S. (2017). Localized Flooding and Autonomous Adaptation in Peri-Urban Bangkok. *Environment and Urbanization* 29(1):51–68.

Matyas, D & Pelling.M. (2014). Positioning resilience for 2015: the role of resistance, incremental adjustment and transformation in disaster risk management policy. *Disasters* 39(1): 1–18.

Cambodia Ministry of Planning (2012). IDPoor Atlas: Identification of poor households: Cambodia. Results from data collection rounds 4 (2010) and 5 (2011). Phnom Penh.

MOE/NCSD. (2017). Lexicon of Climate Change. Phnom Penh: Ministry of Environment (MOE)/National Council for Sustainable Development (NCSD).

MOE, & GGGI. (2019). *Phnom Penh Sustainable City Plan 2018-2030.* Phnom Penh: National Council for Sustainable Development (NCSD), Ministry of Environment (MOE), Phnom Penh Municipality, Global Green Growth Institute (GGGI).

Molyvann, V. (2003). *Modern Khmer Cities .* Phnom Penh: Reyum.

Moreno, E., Arimah, B., Otieno, R., Mbeche-Smith, U., Klen-Amin, A., Kamiya, M., Stren, R., McCarney, P., Tipple, G., Balakrishnan, S., Cast.n-Broto, V., Pieterse, E., Stiftel, B., McCord Smith, S., Roberts, B., Kanaley, T., & Cohen, M. (2016). Urbanization and Development: Emerging Futures. *UN Habitat World Cities Report 2016.*

Nam, S. (2011). Phnom Penh: From the politics of ruin to the possibilities of return. *Traditional Dwellings and Settlements Review, 23*(1), 55-68.

Natarajan, N., Brickell, K., & Parsons, L. (2019). "Climate Change Adaptation and Precarity across the Rural–Urban Divide in Cambodia: Towards a 'Climate Precarity' Approach."

National Bank of Cambodia. (2016). Report on foreign direct investment survey results 2014. Retrieved from National Bank of Cambodia: https://www.nbc.org.kh/download_files/other_reports/english/Report-on-FDI-Survey-Result-2014_NBC_ENG.pdf

Nitivattananon, V.,Thanh Tu, T., Rattanapan, A. & Asavanant, J. (2012). Vulnerability and resilience of urban communities under coastal hazard conditions in Southeast Asia. D. Hoornweg, M. Freire, M.J. Lee, P. Bhada-Tata, B. Yuen (eds.), *Cities and Climate Change: Responding to an Urgent Agenda*. Washington, D.C.: The World Bank.

Oxford Poverty and Human Development Initiative OPHI (2013). *OPHI Country Briefing: Cambodia.* OPHI Country Briefing

Patel, R., Sanderson, D., Sitko, P., & De Boer, J. (2020). "Investigating Urban Vulnerability and Resilience: A Call for Applied Integrated Research to Reshape the Political Economy of Decision-Making." *Environment and Urbanization* 32(2):589–98.

Paling, W. (2012). Planning a Future for Phnom Penh: Mega Projects, Aid Dependence and Disjointed Governance. *Urban Studies, 49*(12), 2889-2912.

Peduzzi, P. (2014). "Sand, Rarer than One Thinks". *Environmental Development* 11: 208-18. https://doi.org/10.1016/j.envdev.2014.04.001.

Pelling, M. (2003). *The Vulnerability of Cities: Natural Disasters and Social Resiliences.* London: Earthscan Publications.

People In Need (2015). *Phnom Penh Multiple Indicator Assessment of the Urban Poor*. UNICEF.

Percival, T. (2016). Urban Megaprojects and City Planning in Phnom Penh. In K. Brickell, & S. Springer, *The Handbook of Contemporary Cambodia* (pp. 181-190). London, New York: Routledge.

Pierdet, C. (2012). Spatial and social resilience in Phnom Penh, Cambodia since 1979. South East Asia Research, 20(2), 263-281.

Po, S. & Heng, K. (2019). *Assessing the Impacts of Chinese Investments in Cambodia: The Case of Preah Sihanoukville Province A Working Paper on China-Cambodia Relations Pacific Forum.* Working Paper; Vol. 19, WP4.

Praparpun, Y. (2010). Women Paying the Price: The impact of the global economic crisis on women in Southeast Asia. Oxfam GB.

Räsänen, T., Koponen, J., Hannu, L., & Matti, K. (2012). "Downstream Hydrological Impacts of Hydropower Development in the Upper Mekong Basin", *Water Resources Management*, vol. 26, n° 12, p. 3495-3513.

RGC. (2018). *Cambodia Sustainable Development Goals (CSDGs) Framework 2016-2030.* Phnom Penh: Royal Government of Cambodia (RGC).

RGC. (2019). *National Strategic Development Plan 2019-2023.* Phnom Penh: Royal Government of Cambodia (RGC).

Royal Government of Cambodia (2004), *Cambodia Socio-Economic Survey 2003-04, Household Survey 2004,* National Institute of Statistics.

Res, P., Bylander, M. (2021). "Microfinance in Times of COVID: Consumer Protection and the Loan Restructuring Process in Cambodia"

Royal Government of Cambodia (2012). *Cambodia Millennium Development Goals progress report 2011.* Ministry of Planning.

Royal Government of Cambodia (2013). *Poverty in Cambodia-a new approach; redefining the poverty line*. Ministry of Planning.

Sassen, S., & Dotan, N. (2011). "Delegating, Not Returning, to the Biosphere: How to Use the Multi-Scalar and Ecological Properties of Cities." *Global Environmental Change* 21(3):823–34.

Schneider, H. (2011). "The Conflict for Boeng Kak Lake in Phnom Penh, Cambodia." Pacific News #36, 4-10.

Simon, D., Arfvidsson, H., Anand, G., Bazaz, A., Fenna, G., Foster, K., Jain, G., Hansson, S., Evans, L. M., Moodley, N., Nyambuga, C., Oloko, M., Ombara, D. C., Patel, Z., Perry, B., Primo, N., Revi, A., Van Niekerk, B., Wharton, A., Wright, C. "Developing and testing the Urban Sustainable Development Goal's targets and indicators – a five-city study." *Environment and Urbanization*, 28(1), 49–63.

Stavrides, S. (2016). *Common Space: The city as Commons.* London: Zed Books.

STT. (2019). *The Last Lakes: Facts and Figures.* Phnom Penh: Samakum Teang Tnaut (STT).

Tacoli, C., McGranahan, G., Satterthwaite, D. (2015) Urbanisation, Rural-Urban Migration and Urban Poverty. *Human Settlements Working Paper.* London: IIED.

Tyler, S., & Moench, M. (2012). A framework for urban climate resilience. *Climate and Development, 4*(4), 311-326.

UN-Habitat. (2019). "UN-Habitat: Sustainable Development Goal". 2019.

United Nations. (2014). *World Urbanization Prospects* [The 2014 Revision]. Department of Economic and Social Affairs.

United Nations. (2018). *World Urbanization Prospects* [The 2014 Revision]. Department of Economic and Social Affairs.

United Nations. (2019). "Cambodia: Sustainable Development Knowledge Platform". 2019. https://sustainabledevelopment.un.org/memberstates/cambodia.

United Nations Cambodia (2019). *United Nations Development Assistance Framework 2019-2023.*

Véron, J. (2018). "Les défis de l'urbanisation dans les pays du Sud". *Revue internationale et strategique* N° 112 (4): 119-27.

Wetterberg, A. (2011). *Public–private partnership in labor standards governance: Better factories Cambodia.* Public Administration and Development-Wiley Online Library.

World Bank Group. (2020). "GDP growth (annual %) - Cambodia | Data". 2020. https://data.worldbank.org/indicator/NY.GDP.MKTP.KD.ZG?locations=KH.

World Bank Group. (2007). East Asia Environment Monitor 2007: Adapting to Climate Change. Washington, DC: World Bank.

World Bank Group (2006). *Cambodia Halving Poverty by 2015? Poverty Assessment 2006.* Report No. 35213-KH.

World Bank Group. (2017). *Urban Development in Phnom Penh.* Washington DC and Phnom Penh: World Bank Group.

World Bank Group. (2019). *Cambodia Economic Update. Recent Economic Developments and Outlook*. Retrieved from Phnom Penh: http://documents.worldbank.org/curated/en/843251556908260855/pdf/Cambodia-Economic-Update-Recent-Economic-Developments-and-Outlook.pdf

World Bank Group (2020). *Cambodia Country presentation.* https://www.worldbank.org/en/country/cambodia/overview

World Food Program (WFP 2019). *Urban Vulnerability in Phnom Penh*. United Nations.

Yamada, T. (2019). Cambodia's Changing Landscape: Rhetoric and Reality. In A.-H. Lim, & F. Cilbulka, *China and Southeast Asia in the Xi Jinping Era* (pp. 65-85). Lanham, Boulder, New York and London: Lexington Books.

Yuen, B., & Kong, L. (2009). Climate Change and Urban Planning in Southeast Asia. S.A.P.I.EN.S. [Online] 2(3).